ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"

**សាធារណៈ**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩**

**សវនាការលើអង្គសេចក្តី (លើកទី១៣)**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវ៉ែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង

លោក ម៉ាត្ទូ គ្រីស្ពារ

*(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាចាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌឺ បេ៊ត

*(Mr. Alexander Bates)*

លោក ពេជ្រ សម្បត្តិ

លោក ស្ទូអាត ហ្វដ *(Mr. Stuart FORD)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**មេធាវីការពារជនជាប់ចោទ កាំង ហ្គេក អ៊ាវ ៖**

លោក ការ សាវុត្ថ

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms.Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក យុង ផានិត

លោក គឹម ម៉េងឃី

លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វែ៉នណឺ

*(Mr. Alain Werner)*

លោក ហ្វីលីព កាណុន

*(Mr. Philippe Cannone)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# ខ្លឹមសារ

## សាក្សី

**សាក្សី ៖** ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ........ ទំព័រ ២
សួរដោយ លោក តាន់ សេណារ៉ុង ផ្តើមពី ........ ទំព័រ ២១
សួរដោយ លោក អាឡិចសាន់ឌឺ ប៊ែត ផ្តើមពី ........ ទំព័រ ២៩

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អាឡិចសាន់ឌឺ ប៊េត | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន័ | បារាំង |
| លោក ហ្វីលីព កាណុន | បារាំង |
| ចៅក្រម ស៊ីលយ៉ាខាតវ៉ាយថ៍ | អងគ្លេស |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោក តាន់ សេណារ៉ុង | ខ្មែរ |
| លោក គង់ ពិសី | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធាអង្គជំនុំជម្រះ) | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:១០:00]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តសវនាការ ពិភាក្សាដេញដោលលើអង្គហេតុ ការបង្កើតមន្ទីរសន្តិបាលស-២១ និងគុកនៅមន្ទីរពេទ្យឆ្កួតតាខ្មៅ ។

ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី ដែលត្រូវចូលរួមនៅក្នុងដំណើរការសវនាការនៅថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ភាគីដែលបានចូលរួមក្នុងដំណើរការនីតិវិធីក្នុងថ្ងៃនេះ មានវត្តមានគ្រប់ចំនួនអស់ហើយ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីចាត់បញ្ចូលនូវរបាយការណ៍ អំពីស្ថានភាពវត្តមាន អវត្តមានភាគីត្រូវចូលរួមក្នុងសវនាការនៅថ្ងៃនេះទៅក្នុងប្រតិចារឹក ។

ជាកិច្ចបន្តអង្គជំនុំជម្រះសូមប្រកាស នូវសេចក្តីសម្រេចទៅលើសំណើសុំរបស់មេធាវីក្រុម១ ដែលបានសុំពីថ្ងៃម្សិលមិញ ដូចតទៅនេះ៖

អង្គជំនុំជម្រះសម្រេច បដិសេធនូវសំណើរបស់មេធាវីក្រុម១ ដែលបានសុំឲ្យរឹតត្បិតនូវសកម្មភាពរបស់មេធាវីការពារក្តីជនជាប់ចោទ ក្នុងការប្រាស្រ័យទាក់ទង មិនឲ្យធ្វើអន្តរាគមន៍កែតម្រូវលើសក្ខីកម្មរបស់ជនជាប់ចោទក្នុងអំឡុងពេលជំនុំជម្រះ ។ ដោយហេតុថា វិធានផ្ទៃក្នុងមិនបានហាមឃាត់មេធាវីការពារជនជាប់ចោទមិនឲ្យផ្តល់ប្រឹក្សាដល់ជនជាប់ចោទ ឬពិភាក្សាជាមួយជនជាប់ចោទនៅពេលណាក៏បានទៀតនោះទេ ។

ជាកិច្ចបន្ត អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទមកកាន់ឈើរាំងរង់ក្រចកសេះនៅទីនោះ ។

មុននឹងបន្តកិច្ចពិភាក្សាដេញដោល អង្គជំនុំជម្រះសូមរំឭកដល់ភាគីចូលរួមថា កិច្ចពិភាក្សាដេញ

ដោលនៅពេលនេះ គឺយើងធ្វើសវនាការលើអង្គហេតុនៃការបង្កើតមន្ទីរសន្តិបាលស-២១ និងបញ្ហាពាក់ព័ន្ធទៅនឹងគុកនៅពេឡូឆ្លូតនៅតាខ្មៅ ដែលមានការពាក់ព័ន្ធជិតដិតទៅនឹងការបង្កើតនៃមន្ទីរសន្តិបាល ស-២១ តែប៉ុណ្ណោះ ។ ចំពោះអង្គហេតុផ្សេងទៀត យើងនឹងធ្វើសវនាការតាមលំដាប់លំដោយនៃកាលវិភាគដែលយើងបានកំណត់ទុករួចហើយ ។ តាមលំដាប់លំដោយរហូតដល់ទីបញ្ចប់ ដែលមានសរុបប្រាំពីរអង្គហេតុនោះ ។ អ៊ីចឹង សូមមានការចាប់អារម្មណ៍លើចំណុចនេះ យើងចៀសវាងការច្របូកច្របល់ទៅនាំឲ្យមានការគ្រប់គ្រង ការដឹកនាំសវនាការ ក៏ដូចជាការពិភាក្សាដេញដោលមានការច្របូកច្របល់ ហើយអាចធ្វើឲ្យមានការតាំងសំណួរដដែលៗ នៅពេលដែលយើងធ្វើសវនាការនូវអង្គហេតុលើកក្រោយ ។ នេះសូមឲ្យមានការចាប់អារម្មណ៍លើចំណុចនេះ ។

ហើយជាកិច្ចបន្តនេះ គឺតើអស់លោក លោកស្រីជាចៅក្រមនោះមានសំណួរអ្វីត្រូវសួរដល់ជនជាប់ចោទទាក់ទិនជាមួយនឹងអង្គហេតុ ដែលបានកំណត់ធ្វើសវនាការនាពេលនេះដែរឬទេ? បើមានសូមអញ្ជើញ ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

[០៩:១៤:២៧]

**សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** សូមអរគុណលោកប្រធាន ។ ខ្ញុំចង់ឲ្យជនជាប់ចោទធ្វើការបញ្ជាក់មួយចំនួនចំពោះសកម្មភាពរបស់គាត់ មុនពេលដែល ស-២១ ចាប់ផ្តើមដំណើរការ ។ គាត់បានលើកឡើងកាលពីម្សិលមិញ គឺជនជាប់ចោទបានលើកឡើងកាលពីម្សិលមិញ លោកបានមកភ្នំពេញនៅខែមិថុនា ឆ្នាំ១៩៧៥ ដើម្បីតាមដាន និងចូលរួមនៅក្នុងវគ្គបង្រៀន វគ្គអប់រំ ។ ហើយលោកក៏បានលើកឡើងថា លោកនៅក្នុងទីក្រុងភ្នំពេញបន្ទាប់ពីការអប់រំនិងបណ្តុះបណ្តាលនេះ ហើយលោកអាចប្រាប់ដែរឬទេបន្ទាប់ពីពេលនោះ គឺលោកត្រូវបានគេផ្តល់ឲ្យទទួលខុសត្រូវក្នុងការចាត់ចែងមន្ទីរសន្តិសុខនៅក្នុងទីក្រុងភ្នំពេញ ឬក៏មានមូលហេតុណាមួយដែរឬទេ ដែលតម្រូវឲ្យលោកនៅក្នុងក្រុងភ្នំពេញ?

**ជនជាប់ចោទ៖**

**ឆ៖** លោកចៅក្រមជាទីគោរព ។ ខ្ញុំមកដល់ភ្នំពេញព្រឹកថ្ងៃ២១ អានេះបើតាមខ្ញុំចាំ ។ ឯចំណែកថ្ងៃ២៤ ខ្ញុំបាទចូលវគ្គនយោបាយ ។ សូមបញ្ជាក់ថា វគ្គនយោបាយ មេខទ្ទេសនាមឯកសារបួនថ្ងៃ ២៤, ២៥, ២៦, ២៧ ក្រៅពីនោះ បន្ទាប់ពីនោះ យើងខ្ញុំនាំគ្នាពិភាក្សាឯកសារតាមក្រុម ដើម្បីរកមើលជម្រៅ

ខ្លឹមសារនយោបាយក្នុងឯកសារនុ៎ង ។ បន្ទាប់មកទៀត សិក្ខាកាមម្នាក់ៗត្រូវធ្វើៗប្រវត្តិរូបបដិវត្តន៍ ហើយនិងជីវទស្សនបដិវត្តន៍ៗ ។ (សូមទោសណ៎ាលោកអ្នកបកប្រែ) ជីវទស្សនបដិវត្តន៍ បារាំងហៅថា *កុងសេស្យុងដឺមុងដ៍ដឺវីវ្ហូហ្សេនែរ* ។

ខ្ញុំសុំតទៅទៀត យើងខ្ញុំត្រូវត្រៀមលោកទស្សនបដិវត្តន៍ ហើយនិងជីវទស្សន-- (សុំទោស) ជីវទស្សនបដិវត្តន៍ៗ ហើយនិងប្រវត្តិរូបប្រហែលជាបីថ្ងៃ ហើយទើបបាននាំគ្នាឆ្លង ដែលហៅថា ឆ្លងហ្នឹង គឺយើងអានប្រវត្តិរូបរបស់យើងឲ្យមិត្តនៅក្នុងក្រុមគេស្តាប់ ហើយដល់ទៅឲ្យគេលើកសំណួរ ហើយយើងឆ្លើយដោះស្រាយសំណួរ ។

[០៩:១៩:១០]

សរុបមកវិញ ក្នុងពេលរៀនម្តងៗ យើងត្រូវចំណាយពេលប្រហែលជា១០ថ្ងៃ ទៅ១២ថ្ងៃ ។ ខ្ញុំនិយាយនេះដើម្បីជូនជ្រាបអំពីរបៀបរបបរៀនសូត្រនៅក្នុងរបបកុម្មុយនីស្ត តែប៉ុននុ៎ងទេ ។ សរុបមកវិញយើងខ្ញុំមកហ្នឹងមានគ្នា៤នាក់សុទ្ធតែបក្ខជននោះ មិនមែនតែ២នាក់ទេ ។ មកខ្ញុំមកបង ម៉ម ណៃ មក មិត្តស៊ុំ ហើយនិងមិត្តមាស ខ្មោចមិត្តមាស បក្ខជនទាំងអស់ ។ ដល់រៀនរួចហើយ មិត្តស៊ុំ សុំច្បាប់ទៅតាមរកប្រពន្ធកូននៅសៀមរាប ។ ខ្ញុំឲ្យ មិត្តមាស ត្រឡប់ទៅអមលាំងវិញ មិនដឹងថាបង ម៉ម ណៃ ទៅដែរ ឬក៏នៅជាមួយនឹងខ្ញុំនៅភ្នំពេញ ខ្ញុំភ្លេចបាត់ទៅហើយ ។

ខ្ញុំសូមបញ្ជាក់ណាស់បកប្រែច្រឡំហើយ អ្នកដែលនៅជាមួយនឹងខ្ញុំមិនដឹងជាបង ម៉ម ណៃ ឬក៏ ម៉ម ណៃ ទៅអមលាំងជាមួយ មិត្តមាស ។

ខ្ញុំនៅទីនោះមិនទាន់មានភារកិច្ចអីទេ នៅរង់ចាំភារកិច្ច ។ ដល់ក្រោយមកបានៗ ខ្ញុំឃើញ ណាត គាត់ហៅខ្ញុំចេញពីស្ថានីយ៍រថភ្លើង មកនៅសេនាធិការដ្ឋានចាស់របស់ *សុសស្តែនហ្វ៊ែកណង់ដេស* ព្រោះ ណាត គាត់តាំងទីនៅហ្នឹង ។

**ស៖** មកដល់ត្រឹមកម្រិតនេះ ខ្ញុំចង់ឲ្យធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់ទាក់ទងទៅនឹងប្រវត្តិរូបរបស់លោកផ្ទាល់ ហើយនិងអំពីជីវទស្សនបដិវត្តន៍របស់លោកផ្ទាល់ ដែលលោកបានធ្វើនៅពេលនោះ ។ លោកបានជម្រាបប្រាប់យើងថា នៅពេលដែលលោកចាកចេញពីម-៣១ លោកបានៗមានការស្អប់ខ្ពើមនឹងអ្វីដែលបានកើតមាននៅទីនោះ ។ ហើយលោកក៏បានប្រាប់ពួកយើងផងដែរថា លោកបានដឹងអំពីចម្លើយសារភាពដែលត្រូវបានទទួលនៅម-១៣ នោះ គឺមិនឆ្លុះបញ្ចាំង ឬក៏បញ្ចាំងតែមួយចំណុចប៉ុណ្ណោះអំពីការពិត ។ ហើយខ្ញុំចង់រំឭកប្រាប់លោកថា លោកបាននិយាយពីពេលមុនរួចមកហើយថា លោកមាន

ទំនាក់ទំនងនៅក្នុងគ្រួសាររបស់លោក មានទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាល លន់ នល់ ។

ហើយគឺធាតុផ្សំអស់ទាំងហ្នឹង តើមានឆ្លុះបញ្ចាំងនៅក្នុងជីវទស្សន៍បដិវត្តន៍របស់លោក ឬក៏នៅក្នុងប្រវត្តិរូបបដិវត្តន៍របស់លោកដែរឬទេ?

**ឆ៖** សូមៗអរគុណលោកចៅក្រម ដែលបានលើកបញ្ហានេះយកមកឲ្យខ្ញុំរាយការណ៍បញ្ជាក់ ។ ជីវទស្សន៍បដិវត្តន៍ ហើយនិងប្រវត្តិរូបបដិវត្តន៍ គេធ្វើក្រោយពីរៀនសូត្រ ទៅតាមខ្លឹមសារនៃវគ្គរៀនសូត្រ ។ ចំណែកជីវទស្សនបដិវត្តន៍ ខ្ញុំអត់មានប៉ានសរសេរថា ខ្ញុំធុញទ្រាន់នឹងការងារនយោបាយ (អូ! សូមទោស) ការងារសន្តិបាលនោះទេ ។ ខ្ញុំសរសេរតាមខ្លឹមសារ (ខ) ដែលគេឲ្យ ។ (ខ) ដែលគេឲ្យកាលនោះបើតាមខ្ញុំចាំ គេអបអរសាទរនឹងជ័យជម្នះ ១៧ មេសា ។

[០៩:២៤:៤៣]

(ខ) ដែលគេឲ្យយើងចាប់អារម្មណ៍ពេលនោះ គឺយើងចាប់អារម្មណ៍យ៉ាងម៉េចចំពោះមហាជ័យជម្នះ ១៧ មេសា នេះមួយ ។ ហើយ (ខ) ទីពីរ គេឲ្យយើងខំរៀនលះបង់ស្វនតួ លះបង់បុគ្គលដើម្បីសមូហភាព ។ ហើយ (ខ) ទីបី យើងតាំងចិត្តប្តេជ្ញាសម្រុកយ៉ាងម៉េច? ដើម្បីរួមចំណែកកសាងសង្គមនិយម ហើយនិងធ្វើបដិវត្តន៍សង្គមនិយមតទៅទៀត ។

ដូច្នេះ ប្រវត្តិរូបរបស់ខ្ញុំដែលទាក់ទងជាមួយនឹងឪពុកមាខ្ញុំ ដែលគាត់ទៅបានក្មួយលោកតា លន់ នល់ ធ្វើជាប្រពន្ធនោះ ។ ខ្ញុំអត់មានរាយការណ៍នៅក្នុងប្រវត្តិរូបរបស់ខ្ញុំទេ ពីព្រោះក្នុងប្រវត្តិរូបនោះ គេតែនិយាយអំពីបងប្អូនបង្កើត ម្តាយបង្កើត ម្តាយក្មេក ឪពុកក្មេងហើយនិងប្រពន្ធ ។ ឯចំណែកឪពុកមាខ្ញុំ ដែលទៅបានក្មួយលោកតា លន់ នល់ នោះជីទួតមួយជាមួយនឹងម្តាយខ្ញុំរួចទៅហើយ ។ ខ្ញុំបានជម្រាបលោកចៅក្រមពីមុនថា ខ្ញុំអត់បានសរសេរក្នុងប្រវត្តិរូបជាផ្លូវការទេ ។ តែជាមួយបក្ខជនជារៀមច្បងខ្លះ ខ្ញុំបានិយាយពីរឿងនុ៎ង ដើម្បីបង្ហាញមោទនភាពរបស់ខ្ញុំថា ខ្ញុំសុខចិត្តនៅជាប់គុកជាជាងទៅផ្សារភ្ជាប់ខ្លួនជាមួយ លន់ នល់ ។

សរុបមក ការធុញទ្រាន់របស់ខ្ញុំ ការតក់ស្លុតនឹងការងារនគរបាលបែបលក្ខណៈមិនវិទ្យាសាស្ត្រ បែបនេះ ខ្ញុំអត់មានបានសរសេរចូលក្នុងជីវទស្សន៍បដិវត្តន៍ទេ ។ ឯចំណែក ការទាក់ទងរបស់ខ្ញុំជាមួយនឹងឪពុកមាខ្ញុំ ក៏ខ្ញុំគ្មានបានសរសេរនៅក្នុងប្រវត្តិរូបខ្ញុំដែរ ។ ឯចំណែក មិត្តភក្តិជិតស្និទ្ធវិញ ការងារដែលខ្ញុំធុញទ្រាន់នឹងនគរបាល ក៏ខ្ញុំអត់ប៉ាននិយាយដែរ ។ សូមបញ្ចប់ប៉ុណ្ណោះ ។

**ស៖** ដូច្នេះ ប្រសិនបើខ្ញុំយល់ដឹងមិនខុសនោះ គឺថានៅចន្លោះខែមិថុនា និងខែសីហា ឆ្នាំ១៩៧៥ នៅពេលដែលអង្គប្រជុំហ្នឹង កើតមានឡើងដែលនិយាយអំពីការបង្កើតស-២១ នោះ ។ គឺថា លោកមិនមានសកម្មភាពអីជាក់លាក់ ក្រៅពីកម្មវិធីការចូលរួមបណ្តុះបណ្តាលនោះទេ ហើយឬក៏ទាក់ទងនឹងការសរសេរប្រវត្តិរបស់លោក ។ ហើយមានន័យថា នៅពេលនោះ តើលោកមិនទាន់ចាប់ផ្ដើមធ្វើការងារជានគរបាល នៅពេលនោះនៅឡើយទេឬ?

[០៩:២៩:00]

**ឆ៖** អរគុណ។ លោកចៅក្រមដែលបានបញ្ជាក់ សូមពិតរាយការណ៍ជម្រាបតទៅទៀតថា ក្នុងរយៈកាលនុំ្នង ដូចខ្ញុំបានជម្រាបអ៊ីចឹង មិនដឹងជាខ្ញុំនៅភ្នំពេញម្នាក់ឯង ឬក៏ពីរនាក់បង ម៉ម ណៃ មិនច្បាស់ ។ ខ្ញុំ-- អើវាកម្សត់បីបួនឆ្នាំហើយ មកដល់ភ្នំពេញ បាននេះបាននោះហូប នៅតែហូបនៅអគ្គ-សេនាធិការហ្នឹង អត់ប៊ានដើរចេញទេ ។ នៅហូបនៅអីរង់ចាំភារកិច្ច ប៉ុន្តែមានពេលមួយនោះ ខ្ញុំទៅអមលាំង ជិះម៉ូតូទៅអមលាំង ទៅលេងអមលាំង ទៅអើតមើលអមលាំង ។

សរុបមក បើតាមខ្ញុំរំឭកឃើញ វាអត់មានការងារនគរបាល ឬការងាររៀនសូត្រអីពិសេសទេ ដើរតែមើល-- ដើរតែមើលតែរបៀបដែលក្នុង *អេតាម៉ាហ្សរ់* របស់ លន់ នល់ ហ្នឹង គេរក្សា *អេទីកែត* គេយ៉ាងម៉េច? គេដាក់ស្លាកស្នីគេយ៉ាងម៉េច? រៀបចំចាត់ចែងកិច្ចការប្រយុទ្ធរបស់គេយ៉ាងម៉េច នៅអាជាន់ក្រោមៗក្នុងដីនោះ?

**ស៖** លោកពន្យល់យ៉ាងម៉េច? លើកលែងតែខ្ញុំយល់ច្រឡំ លោកទៅរកព័ត៌មាន ហើយលោកទៅកន្លែងគ្រប់គ្រងបុគ្គលិកនៅកន្លែង លន់ នល់ ។ ប្រហែលជាខ្ញុំយល់ច្រឡំលើបញ្ហាហ្នឹង ហើយថាតើលោកទៅស្រាវជ្រាវអ្វីទៅទីស្នាក់ការ លន់ នល់? ហើយលោកបានរកឃើញឯកសារជាក់លាក់ណាមួយទាក់ទងទៅនឹងការធ្វើទារុណកម្ម ឬក៏សៀវភៅលើបញ្ហាទារុណកម្មដែរឬទេ?

**ឆ៖** ក្រោយថ្ងៃ១៥ សីហា ឆ្នាំ១៩៧៥ ពេលនុំ្នង មិត្តស៊ុំ បានប្រពន្ធមកហើយ មេឲ្យត្រឡប់ទៅនៅឧស្សាហកម្មវិញ តាមសំណូមពររបស់មិត្តស៊ុំ ។ ចំណែកឯខ្ញុំ--

**ស៖** សូមលោកបញ្ជាក់ឈ្មោះឡើងវិញ ដោយសារការបកប្រែមិនទាន់ចេញបានឈ្មោះច្បាស់។

*(សូមអភ័យទោស អ្នកបកប្រែស្តាប់អត់ឮពីចៅក្រម ដូច្នេះសូមឲ្យលោកធ្វើការបញ្ជាក់)*

**ឆ៖** មិត្តស៊ុំ ត្រឡប់មកពីរកប្រពន្ធវិញហើយ មេឲ្យទៅនៅឧស្សាហកម្មតាមសំណូមពរ ។ ឯចំណែកខ្ញុំ ចាត់ចែងឲ្យ មិត្តមាស នាំកម្លាំងពីអមលាំងយកមកដាក់នៅភ្នំពេញ ។ ចំណែកខ្ញុំ ហើយនិង

បង ម៉ម ណៃ ដើររុកតត្រុករើឯកសារតាមផ្ទះ និងតាមស្ថាប័នសាធារណៈ ។ ផ្ទះឯកជនអ្នកដឹកនាំធំៗ គឺខ្ញុំទៅរុករើនៅផ្ទះ លន់ នល់ អស់ពីរថ្ងៃ ។

ចំណែកសេនាធិការរបស់ *សុសស្តែន* ខ្ញុំនៅនោះស្រាប់ ឃើញឯកសារនៅនោះស្រាប់ ប៉ុន្តែអត់យកទេ ណាត គេប្រមូលទុក ។ ឯចំណែកផ្ទះ ឆន សុខុម ក្រសួងការបរទេសនោះ មេប្រមូលទុកហើយប្រគល់មកឲ្យខ្ញុំទុក ។ ខ្ញុំទៅរើស្ថាប័នសាធារណៈ គឺមានអគ្គនាយកដ្ឋានប៉ូលិសនេះមួយ *គុយហ្សេអាអា* (QGAA) នេះពីរ ហើយន័ *ស៊ីប្រា* (CEPRA) នេះបី ហើយ *អាហ្សីកាស៊ី* (AJKC) នេះបួន ។ ឯចំណែកឯកសារ អំពីទារុណកម្មដែលលោកចៅក្រមសួរខ្ញុំនោះ ខ្ញុំយកពីៗ អគ្គនាយកដ្ឋានប៉ូលិស ដែលភាសាសាមញ្ញគេហៅ ប៉េហ្ស៊ី (PJ) នោះ ។

**ស៖** ខ្ញុំក៏ចង់ចោទសួរចំពោះការបំភ្លឺៗ តួនាទីផ្ទាល់របស់លោកនៅក្នុងមន្ទីរស-២១ ។ យើងបាននិយាយថា កន្លែងមួយចំនួនត្រូវបានប្រើប្រាស់ ប៉ុន្តែទីតាំងចុងក្រោយ ចំពោះខ្ញុំ គឺវាមានលក្ខណៈពីរបែប៖ ទីមួយ គឺការប្រើប្រាស់អាគារសាលា ។ ហើយទីពីរ គឺនិងទីកន្លែងរបស់សាលា ។

ថាតើលោកជាអ្នកស្នើសុំឲ្យប្រើទីកន្លែងនោះ ឬក៏ជាសេចក្ដីសម្រេចរបស់ថ្នាក់លើរបស់លោក? ថាលោកបានស្នើសុំការយល់ព្រម ពីថ្នាក់ដែរឬទេចំពោះករណីនេះ?

**ឆ៖** លោកចៅក្រមជាទីគោរព! ស្ថានទីរបស់ស-២១ ចុងក្រោយនេះ គឺដំបូង ណាត យកមកទីតាំងដោយសារមេដេញពី ប៉េហ្ស៊ី មិនឲ្យមកនៅនុ៎ង ។

ដូច្នេះ និយាយពីទំហំដីទាំងអស់នោះ វាជាកេរតំណែលតាំងពី ណាត គាត់នៅម្ល៉េះ ។ បានន័យថា ខាងជើងទល់នឹងផ្លូវលេខ៣១០ ខាងត្បូងហួសផ្លូវលេខ៣៦០ បន្តិចទៅ ខាងកើតគឺនៅត្រឹមផ្លូវមុនីវង្ស ខាងលិចអត់ហួសពីផ្លូវ១៦៣ ទេ ។

ដូច្នេះ កេរដំណែលនេះវារៀបចំតាំងពីសម័យ ណាត មក មេក៏អនុញ្ញាតដែរ ។ ពីព្រោះវាកំបាំងពីភ្នែកអ្នកជំនាញការចិន ។ ចំណែក គំនិតផ្ដើមរបស់ខ្ញុំ ហើយដែលខ្ញុំសុំអនុញ្ញាតមេយល់ស្របគឺប្ដូរកន្លែងឃុំឃាំងមកនៅក្នុងស្ថានទីរបស់វិទ្យាល័យពញាយ៉ាត ។ នេះជាគំនិតផ្ដើមរបស់ខ្ញុំ ហើយមេអនុញ្ញាត ។ ឯចំណែក ជើងឯក ខ្ញុំសម្រេចៗអត់មានសុំយោបល់មេទេ ដូចក្រោយមកខ្ញុំបានរាយការណ៍ជូនគាត់ជាព័ត៌មានដែរ ។ ចំណែក *សែលល័រ អាំងឌីវីឌុយអែល* តូចៗហ្នឹង ខ្ញុំសម្រេចហើយ អត់ទាំងបានរាយ-ការណ៍ជូនគាត់ផង ។

ដល់ចុងបញ្ចប់ខ្ញុំសុំអនុញ្ញាតរាយការណ៍បន្ថែមមួយ ដែលក្នុងអង្គសវនាការនេះខ្ញុំមិនទាន់ដែល

បានរាយការណ៍ ។ នៅពេលថ្ងៃ១៥ សីហា ១៩៧៥ នេះ មេចង្អុលទិសឲ្យខ្ញុំទៅរៀបចំមន្ទីរនគរបាលឯភូមិកប់ស្រូវ ខាងជើងភ្នំពេញ ។ ខ្ញុំអត់ស្គាល់កប់ស្រូវ ។ ខ្ញុំរកមិនឃើញ គាត់ថាចាំឲ្យ មិត្តចន ជូនទៅ។ មិត្តចន រវល់ការងារបម្រើរត់ខ្វែងដៃចុះឡើង អត់បានជូនទៅ ។ សូមបញ្ជាក់ថា មិត្តចន នេះជានីរសាររបស់មេប្រចាំការនៅនឹងស្ថានីយ៍រថភ្លើងហ្នឹងឯង ។ ចុងបញ្ចប់បាន១ ណាត គាត់ចាប់ផ្តើមជ្រើសរើសកន្លែងដែលខ្ញុំដាក់អក្សរ “B” ខាងលិចសារមន្ទីរទួលស្លែងបច្ចុប្បន្ននេះបន្តិច ។ អ៊ា១ សូមទោសអ៊ា១ សូមទោសណាខ្ញុំរាយការណ៍ច្រឡំអំមិញ ។ ឥឡូវដល់ចុងបញ្ចប់ ឆ្នាំ១៩៦៨ *(ស៊ិក)* ពូ នួន ហៅខ្ញុំទៅធ្វើការ គាត់ប្រាប់ថាមិត្តទៅនៅកប់ស្រូវ រើកន្លែងមិត្តទៅ ។

ខ្ញុំសូមបញ្ជាក់ម្តងទៀត នៅឆ្នាំ១៩៧៨ ពូនួន គាត់ហៅខ្ញុំទៅធ្វើការ នួនជា ហើយគាត់រំឭកឡើងវិញ គាត់ថាមិត្តទៅនៅកប់ស្រូវ កន្លែងដែលអង្គការចង្អុលឲ្យមិត្ត ។ ខ្ញុំប្រកែក ខ្ញុំថាទេទៅអាម៉េចជើងឯកអដ្ឋិធាតុមួយគគោក ខ្ញុំទៅចោលម៉េចបាន អ្នកណាទៅថ្កើះកកាយ? ខ្ញុំនៅជើងឯង ។ អដ្ឋិធាតុ *ស្កឺឡែត* (Scellete) សូមបញ្ជាក់១ ខ្ញុំសូមបញ្ជាក់បកប្រែហ្នឹងមិនត្រឹមត្រូវទេ ។ ខ្ញុំទាមទារសុំនៅជើងឯក ពីព្រោះឆ្អឹងខ្មោចដែលយើងសម្លាប់គេនោះ នៅច្រើនណាស់ ។ ដូច្នេះ ខ្ញុំទៅចោលម៉េចបាន? ពូនួនគាត់នៅស្ងៀម ដល់ហើយខ្ញុំទៅធ្វើការលើកក្រោយបានគាត់ប្រាប់ថា អង្គការសុខចិត្ត ។

សូមបញ្ចប់សេចក្តីរាយការណ៍ត្រឹមប៉ុណ្ណេះ ។

**ស៖** ថាតើទីតាំងរបស់វិទ្យាល័យត្រូវបានប្រើប្រាស់ជាស្ថានទីសម្រាប់សួរចម្លើយ និងធ្វើទារុណកម្មដែរឬទេ? ហើយវាបានបង្កើតជាបញ្ហាណាមួយចំពោះលោកដែរ ឬទេ? ថាតើលោកមានអារម្មណ៍យ៉ាងម៉េចដែរ? វាគឺជាទីកន្លែងសាមញ្ញដូចទីកន្លែងដទៃទៀត ឬយ៉ាងម៉េច?

**ឆ៖** លោកចៅក្រម ទស្សនៈនយោបាយរបស់ខ្ញុំបាទនៅពេលនោះ ឃើញវិទ្យាល័យស៊ីសុវត្ថិ ហើយនិងសាលាបឋមសិក្សាទួលស្លែងនេះគ្រាន់តែជាអគារមួយដូចអគារផ្សេងទៀត ។ ហើយជាអគារមួយដែលសម្រួលដល់ការឃុំឃាំង ក៏ប៉ុន្តែ ឥឡូវនេះមិនមែនមើលឃើញអ៊ីចឹងទេ ។ ការយកសាលារៀនមកធ្វើគុក ធ្វើកន្លែងសួរចម្លើយ ធ្វើទារុណកម្ម ជាទីប្រមាថមើលងាយធំណាស់ដល់មនុស្សជាតិ ដល់អរិយធម៌ ដល់វប្បធម៌ ដល់អរិយធម៌មនុស្សជាតិ ។

[០៩:៤៨:០៥]

**ស៖** ចំពោះកងពល៧០៣ ហើយនិងពេទ្យឆ្កួតនៅតាខ្មៅ ប្រហែលខ្ញុំមិនសូវយល់ត្រឹមត្រូវចំពោះការលើកឡើងកាលពីម្សិលមិញ ។ ហើយខ្ញុំជឿថា លោកបានលើកឡើងអំពីសកម្មភាពរបស់

ការិយាល័យ ឬក៏មន្ទីរនេះ គឺបានបញ្ចប់នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៦ ។ ថាតើលោកមានន័យថា នៅពេលនោះហើយដែលអគារនេះបានផ្តល់ជូនទៅមន្ទីរ ក្រសួងសង្គមកិច្ចវិញ ឬយ៉ាងម៉េច?

**ឆ៖** សំណួររបស់លោកដូចតទៅ ។ មន្ទីរពេទ្យឆ្កួតតាខ្មៅ ណាត គាត់ប្រើតាំងពី១៧ មេសា រហូតមក ។ បើតាមការសរុបព័ត៌មាន ហើយនិងវិភាគបច្ចុប្បន្ននេះ គុកនេះប្រើរហូតដល់ខែប្រាំមួយ ឆ្នាំ១៩៧៦ ទើបគាត់បង្ហើយកម្មេចអ្នកនៅជាប់គុកនុំងអស់ ។ ឯចំណែក ការប្រគល់ជូនទៅក្រសួងសង្គមកិច្ច ឬក៏ដើមឆ្នាំ១៩៧៧ ឬក៏ចុងឆ្នាំ១៩៧៦ ប៉ុន្តែបើតាមការវិភាគមិនមែនចុង១៩៧៦ គឺដើម ៧៧ ឆមាសទីមួយឆ្នាំ១៩៧៧ ។ សូមរាយការណ៍បញ្ចប់អំពីបញ្ហាគុកតាខ្មៅបន្ថែមប៉ុណ្ណេះ ។

**ស៖** មានចំណុចខ្លះដែលខ្ញុំមិនទាន់យល់ច្បាស់ តើគុកហ្នឹងជាផ្នែកមួយរបស់ស-២១ ឬក៏អត់ទេ? ហើយតើអ្នកណាគេជាអ្នកគ្រប់គ្រងមន្ទីរនោះ មន្ទីរ០៣នោះ បន្ទាប់ពី ណាត ចាកចេញទៅនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ជាផ្លូវការអាមន្ទីរ០៣ នេះវាត្រូវបញ្ចប់ថ្ងៃទី១៥ សីហា ១៩៧៥ ។ ក៏ប៉ុន្តែ ណាត ដូចជារាងច្រេចច្រូច មិនព្រមប្រើឈ្មោះមន្ទីរស-២១ ចាប់តាំងពី១៥ សីហា ១៩៧៥ មកទេ ។ ឯកសារដែលនៅសល់ មានឯកសារមួយបញ្ជាក់ថា រហូតដល់ថ្ងៃ៣០ វិច្ឆិកា ឬក៏ថ្ងៃ១ ធ្នូ ហើយ ណាត នៅតែស៊ីញ៉េ ០៣ ។ ដូច្នេះ គាត់ប្រើឈ្មោះហ្នឹងក្រៅផ្លូវការ ឯចំណែកឈ្មោះជាផ្លូវការ ត្រូវចាប់ផ្តើមតាំងពីថ្ងៃទី១៥ សីហា ឆ្នាំ១៩៧៥ ។

សរុបមក អគុកតាខ្មៅនេះ គាត់គ្រប់គ្រងតាំងពី១៥ សីហា រហូត១១មកដល់គាត់ចេញ ហើយ គាត់ត្រូវបង្ហើយ៣ខែមកក្រោយទៀត ។ ថ្ងៃគាត់ចេញ សូមបញ្ជាក់លោកចៅក្រមម្តងទៀត ប្រហែលជា នៅក្នុងខែមីនា ឆ្នាំ១៩៧៦ ។ សូមបញ្ចប់ប៉ុណ្ណេះ ។

[០៩:៥៣:១២]

**ស៖** វាដូចជានៅតែស្រពិចស្រពិលនៅឡើងទេសម្រាប់ខ្ញុំ ពីព្រោះលោកបាននិយាយថា មន្ទីរនេះចាប់ផ្តើមនិងបន្តប្រតិបត្តិការទៀតរហូតដល់ខែមិថុនា ឬក៏ខែកក្កដា ឆ្នាំ៧៦ បើតាមខ្ញុំនៅចាំ ។ អ៊ីចឹង តើនៅពេលនុំង តើអ្នកណាគេជាអ្នកគ្រប់គ្រងមន្ទីរ០៣ហ្នឹង បន្ទាប់ពីខែមីនា ឆ្នាំ៧៦ ពីព្រោះលោកបាន និយាយថា ណាត ហ្នឹង បានចាកចេញពីខែមីនា ទៅហើយ ។ អ៊ីចឹង តើអ្នកណាគេមានការទទួលខុសត្រូវទៅលើមន្ទីរនេះ? ហើយតើអ្នកណាគេត្រូវបានសួរ ដើម្បីឱ្យធ្វើការបោសសម្អាតនៅទីតាំងនុំង ឬក៏ត្រូវការគាស់សាកសព ហើយនិងប្រគល់កន្លែងនុំងឱ្យទៅខាងក្រសួងសង្គមកិច្ចវិញ តើលោកអ្នកធ្វើកិច្ចការនោះឬ?

**ឆ៖** លោកចៅក្រមជាទីគោរព! មន្ទីរ-០៣ នោះ ណាត គាត់នៅគ្រប់គ្រងពីលើ ចំណែកមនុស្ស ដែលរត់ការងារប្រចាំថ្ងៃជាប់ជានិច្ចគឺ មិត្តហ៊ា ។ មិត្តហ៊ា រត់សព្វកន្លែង គាត់ប្រើគ្នាសព្វកន្លែងអ៊ីចឹង ។ នៅពេលដែល ណាត គាត់ចេញទៅខែ៣ ដូចខ្ញុំបានជម្រាបលោកចៅក្រមពីមុនមកហើយ គាត់បាន ប្រាប់ខ្ញុំឲ្យរក្សាទុកគុកតាខ្មៅប្រើការ ។ ខ្ញុំក៏មិនបានជាគិតគូរអីទេ ខ្ញុំជឿថា ពេលនោះ ហ៊ា នៅតែគ្រប់ គ្រង អ្នកជាប់ទោសនៅអាតាខ្មៅហ្នឹងរហូត ។ ហើយនៅពេលដែល ណាត គាត់ចេញទៅ គាត់ត្រឡប់ មក សុំអនុញ្ញាតមេត្រឡប់មកជួប ហ៊ា ដើម្បីបង្ហើយការងារចាស់ ។ សូមបញ្ជាក់ថា មេហ្នឹង គឺមេទាំង អស់គ្នា ទាំងខ្ញុំ ទាំងណាត គឺលោកគ្រូ សុន សេន ហ្នឹង ។

ដូច្នេះ ណាត ចុះឡើងៗរហូតដល់ប្រហែលជាក្នុងខែ៦ ឆ្នាំ១៩៧៦ បានៗចប់ឈប់មក ។ ដូច្នេះ គុកនៅតាខ្មៅនោះ វាដំណើរការដូចខ្ញុំបានជម្រាបលោកចៅក្រមហើយ ចាប់តាំងពីថ្ងៃទី១៧ មេសា រហូតដល់ខែមិថុនា ឆ្នាំ១៩៧៦ ។ អ្នកដែលនៅគ្រប់គ្រងផ្ទាល់រត់ការងារប្រចាំថ្ងៃជាប់គឺ មិត្តហ៊ា ។ ឯចំណែក ណាត គាត់នៅពីលើ ជាអ្នកគ្រប់គ្រងបញ្ជាពីលើ ។

នេះជាប្រវត្តិដែលមិនស្រួលប៉ុន្មានទេ មិនស្រួលយល់ប៉ុន្មានទេ មិនចុះសម្រុងគ្នាប៉ុន្មានទេ រវាង ០៣ និង ស-២១ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមរំឭកដល់ជនជាប់ចោទថា ដោយការសួរនេះជាសំណួរជាភាសាបារាំង ហើយ ដែលចៅក្រមបារាំងសួរ ហើយលោកបានស្តាប់ជាភាសារាំង ហើយឆាប់ឆ្លើយភ្លាមនឹងសំណួរនាំឲ្យ ការបកប្រែហ្នឹងមានបញ្ហា ។ អ៊ីចឹង សូមឲ្យបង្អង់បន្តិចនៅពេលដែលមានសំណួរ ដើម្បីឲ្យការបកប្រែ ហ្នឹងបានបកប្រែឲ្យច្បាស់លាស់ ។ ហើយទីពីរ នៅពេលដែលលោកឆ្លើយចប់ សូមបិទមេក្រូផង ។ សូមអញ្ជើញ លោក ហ្សង់ម៉ាក បន្តទៀត ។

[០៩:៥៧:៤៣]

**សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** សូមអរគុណលោកប្រធាន ។ ខ្ញុំនៅតែមិនទាន់យល់ឲ្យបានច្បាស់លាស់ តើអ្នកណាគេ ជា អ្នកសម្រេចបញ្ជូនប្រជាជន ឬក៏មនុស្សមកស-២១ ឬក៏បញ្ជូនមកមន្ទីរ០៣ នោះ? តើមានភាពផ្សេង គ្នាទេរវាងស្ថាប័នទាំងពីរនេះ? តើមន្ទីរ០៣ជាកន្លែងសម្រាប់ធ្វើការប្រហារជីវិត ហើយមិនមែនជាកន្លែង សម្រាប់ធ្វើការសួរចម្លើយទេនោះ? សូមលោកបញ្ជាក់ត្រង់ចំណុចនេះមើល៍?

**ឆ៖** ដំបូងខ្ញុំសូមរាយការណ៍ជូនអំពីរឿងអ្នកដែលសម្រេចបញ្ជូនមនុស្សមក០៣ ។ អ្នកដែលសម្រេចបញ្ជូនមនុស្សមក០៣ បើតាមខ្ញុំមើលទៅ សំខាន់គឺមេមែនហើយ ក៏ប៉ុន្តែតួនាទីរបស់ ណាត ដើរទៅសុំមនុស្សពីជនបទមកមាន ។ ដូច្នេះ រឿងមនុស្សចូលទៅមន្ទីរ០៣ ច្របូកច្របល់បន្តិច ។ សូមបញ្ជាក់ជូនលោកចៅក្រមថា សូម្បីតែខ្ញុំទៅធ្វើជាអនុប្រធានហ្នឹងហើយក៏ដោយ ក៏ ណាត នៅតែសម្រេចចិត្តចាប់មនុស្សនៅក្នុងកងពល១២ ដោយអត្តនោម័តិ ។

ដូច្នេះ រឿងចាប់មនុស្សចូលមន្ទីរ-០៣ មុនដែល ណាត គាត់ចេញទៅច្របូកច្របល់ណាស់ មិនដឹងជាអ្នកណាខ្លះគាត់សម្រេច អ្នកណាខ្លះមេសម្រេច ។ ខ្ញុំសូមបញ្ជាក់ថា រយៈកាលនោះគឺរយៈកាលគេសម្រិតសម្រាំងទាហានចាស់ អ្នករាជការចាស់របស់ លន់ នល់ ។ ដូច្នេះ អ្នកដែលចាប់ស្រឡះដៃបន្តិច អ្នកដែលចាប់មនុស្សបញ្ចូលទៅសម្លាប់ បញ្ចូលទៅស្អី ស្រឡះដៃបន្តិចជំនាន់នោះ ។ ដែលគត់មត់មែនទែន គឺចាប់តាំងពីខ្ញុំឡើងធ្វើជាប្រធាន គឺគ្មានអ្នកណាប៉ានបញ្ជូនមនុស្សមកស-២១ ដោយមិនឆ្លងកាត់តាមខ្ញុំទេ ហើយគ្មានអ្នកណាប៉ានបញ្ជូនមកស-២១ ។ គ្មានអ្នកណាមួយឆ្លងកាត់មកដល់ខ្ញុំ ដោយមិនឆ្លងកាត់តាមមេទេ គឺសុទ្ធតែឆ្លងកាត់តាមមេទាំងអស់ ។

ដូច្នេះសរុបមកវិញ បើច្បាស់លាស់មែនទែន គឺចាប់តាំងពីខ្ញុំឡើងធ្វើប្រធាន ។ តាំងពីខ្ញុំឡើងធ្វើជាប្រធានមក វាច្បាស់លាស់មែនទែន គឺគ្មានអ្នកណាប៉ានបញ្ជូនមនុស្សមកខ្ញុំដោយផ្ទាល់ទេ គឺសុទ្ធតែសុន សេន បញ្ជូនមកឲ្យខ្ញុំ ។ នេះជាសភាពការណ៍ពិត។ ឯចំណែកឯការរាយការណ៍ពីលើកមុន ប៉ុន្មានឃ្លាមុន គឺវារដិបរដុបមិនច្បាស់ទេ ។ អាច្បាស់ គឺមួយឃ្លាចុងក្រោយនេះ គឺទាល់តែមេឲ្យមកខ្ញុំ បាន ស-២១ ទទួលបាន គ្មានអ្នកណាប៉ានបញ្ជូនមកឲ្យខ្ញុំក្រៅពីមេទេ ។ សរុបមកវិញ សភាពការណ៍ក្រោយ ១៧ មេសា ច្របូកច្របល់ណាស់ ។ ការចាប់ចង និងការសម្លាប់មនុស្សងាយណាស់ ។ ចំណែក ពីថ្ងៃខែមីនា ឆ្នាំ១៩៧៦ មកគឺទាល់តែខាងលើបញ្ជូនមក បាន ស-២១ ទទួលបាន ។

**ស៖** ខ្ញុំគិតថា យើងនឹងនិយាយអំពីរចនាសម្ព័ន្ធ ស-២១ នៅពេលក្រោយ ។ លោកបាននិយាយអំពីការបង្កើតមួយចំនួនដែលខ្ញុំគិតថា បានកើតមានឡើងនៅ ស-២១ ហើយការបង្កើតបែបហ្នឹងមិនមានទេនៅម-១៣ កាលពីមុននោះ ជាពិសេសគឺទំនាក់ទំនងតាមប្រព័ន្ធទូរស័ព្ទ ហើយនិងតាមប្រព័ន្ធវ៉ៃអង្គុលីលេខអីជាដើម ។ អ៊ីចឹងតើសេវាវ៉ៃអង្គុលីលេខនៅម-១៣ នោះមានទេ? ដូចថាខាងផ្នែកថតរូបនៅម-១៣ ជាដើម ថាតើមានដែរឬទេ? ហើយនិងមានមធ្យោបាយសម្រាប់ធ្វើការកត់ត្រានៅម-១៣ នោះពីព្រោះខ្ញុំដឹងថាមានការកត់ត្រាចម្លើយនៅម-១៣ ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើនៅពេលចាប់ផ្តើមការបង្កើត

ផ្នែកផ្សេងៗនោះ គឺជាគំនិតរបស់លោក ឬក៏រឿងចំណុចអស់ទាំងហ្នឹងមានកើតមានទូវស្ថាប័នផ្សេងៗរួចទៅហើយ ហើយអ៊ីចឹងតើការអនុវត្តហ្នឹងអនុវត្តដោយរបៀបណាទៅ?

**ឆ៖** លោកចៅក្រមជាទីគោរព! របស់ទាំងអស់នេះគ្មានទេ នៅជំនាន់ អឹម-១៣ (ម-១៣) ។ សូម្បីតែក្រដាសសរសេរហ្នឹង ក៏ទៅសុំក្រដាសកាសែតរបស់គេយកមកហែកសរសេរនឹងខ្មៅដៃ ។ មកដល់ស-២១ វាជាជយភណ្ឌដែលភ្នំពេញបែក ជាកេរដំណែលរបស់កងពល៧០៣ ម៉ាស៊ីនថត ជាងថតប្រដាប់ថត ទាំងអស់ហ្នឹងសុទ្ធតែជាកេរដំណែលរបស់កងពល៧០៣ ។ ជាងថតក៏ជាកេរដំណែលមកពីខាងកងពល៧០៣, ម៉ាស៊ីនវាយអក្សរក៏មកពីកងពល៧០៣, ក្រដាសសរសេរ, សៀវភៅសរសេរ, ថ្នាំពេទ្យ, ស្រោមសំបុត្រល្អៗ រហូតយកបានទាំង*ហ្វូតូកូពី* ប្រដាប់*ហ្វូតូកូពី* មួយគ្រឿងផង, ប្រដាប់បញ្ចាំងកុនខ្នាត ៣៦មីលីម៉ែត្រ ពីរគ្រឿងផង ហើយ-- អូ! ច្រើនណាស់ រាប់មិនអស់ទេ ។ មានអាប្រដាប់មួយនោះសម្រាប់ធ្វើចារ*ស្តង់ស៊ីលអេឡិចត្រូនិច* ក៏មានដែរ ។ ដូច្នេះ សុទ្ធតែជារបស់ដែលបានមក ។ ដូច្នេះ គឺប្រើប្រាស់តែរបស់ចាស់នៃអ្នកភ្នំពេញទាំងអស់ លើកលែងតែរបស់មួយទេ ដែលមេឱ្យមកខ្ញុំថ្មី គឺទូរស័ព្ទដែលខ្ញុំប្រើជាមួយនឹងមេ ដែលមានចុច*ប៊ូតុង* ទៅ ហើយវាបំបែក*ប្រេហ្វកង់* នុំងដែលមេឱ្យថ្មី ។

[១០:០៧:៣៦]

**ស៖** អ៊ីចឹងសំណួរចុងក្រោយទាក់ទងនឹងព្រៃស ។ តើការចូលរួមរបស់លោកមានដល់កម្រិតណាដែរ ទាក់ទងទៅនឹងព្រៃស? តើលោកជាអ្នកធ្វើសេចក្តីសម្រេចក្នុងការប្រើអគារមួយចំនួន ឬមួយយ៉ាងម៉េច? តើលោកជាអ្នកសម្រេចក្នុងការរៀបចំរចនាសម្ព័ន្ធផ្ទៃក្នុងនៅព្រៃស ឬក៏យ៉ាងម៉េច? ដូច្នេះមានន័យថា តើការចូលរួមរបស់លោកត្រឹមកម្រិតណាដែរទាក់ទងនឹងព្រៃសនោះ?

**ឆ៖** លោកចៅក្រមជាទីគោរព! ព្រៃសនេះវាស្ថិតនៅក្រោមអំណាចគ្រប់គ្រងរបស់ខ្ញុំទាំងស្រុង ។ វាគ្រាន់តែខ្ញុំអត់មានពេល ក៏បណ្តោយឱ្យមិត្តហ៊ឺ និងមិត្តហ៊ុយ គេធ្វើការ លើកលែងតែករណីពិសេសខ្លះដែលខ្ញុំត្រូវអន្តរាគមន៍ ។ ដូចជាថ្ងៃមួយនោះ មេឱ្យសាកល្បងយកយុទ្ធជនខាងបូព៌ាសាមសិបប្លាយនាក់យកមកអប់រំ ។ អប់រំហើយមួយខែហ្នឹង នឹងអាលបញ្ចូលទៅកងរថក្រោះដែលរៀបចំបង្កើតថ្មី ។ កងរថក្រោះ វាបញ្ចូលមកកងរថក្រោះដែលទើបបង្កើតថ្មី ។ អង្គភាព-- មនុស្សជាងសាមសិបនាក់នេះហើយ សូមបញ្ជាក់ មនុស្សជាងសាមសិបនាក់នេះ មកពីអង្គភាពកងពលបូព៌ា ហើយមេយកមកឱ្យអប់រំដើម្បីបញ្ចូលទៅក្នុងកងរថក្រោះ ដែលនឹងបង្កើតថ្មី ។ សូមអរគុណ ។

ដូច្នេះ មានតែករណីពិសេសអ៊ីចឹងទេ ដែលខ្ញុំបានចូលរួមចំណែក ។ ដោយឡែកតែកាលណាត្រូវចាប់មនុស្សមក ដែលចាប់មនុស្សនៅក្រោមការគ្រប់គ្រង ក្នុងការអប់រំ គេពិគ្រោះគ្នាគេពីរនាក់មកសុំយោបល់ខ្ញុំ ។ ខ្ញុំមានសិទ្ធិសម្រេចដោយមិនធានាឆៅមេ គ្រាន់តែរាយការណ៍ជូនជាព័ត៌មាន ។

[១០:១១:០១]

ក៏ប៉ុន្តែករណីដោយឡែកខ្លះ ក៏ត្រូវការខ្ញុំសុំយោបល់មេដែរ ។ ឧទាហរណ៍ដូចជា មាននៅសល់ឯកសារមួយនិយាយពីបងប្អូនរបស់ សុខ ហើយនិងបងប្អូនរបស់ ម៉ៃ លន់ អាហ្នឹងខ្ញុំត្រូវសុំយោបល់មេ ។ ព្រោះហ្នឹងមេផ្តាំផ្តាច់ឲ្យសុំយោបល់គាត់សិន មុននឹងសម្រេច ។ នេះនិយាយអំពីមនុស្សដែលអប់រំសាថ្មី បានន័យថា គ្នាវាជាពាក់កណ្តាលអ្នកទោស ពាក់កណ្តាលប្រជាជន ។ ក៏ប៉ុន្តែ បុគ្គលិករបស់ស-២១ នៅព្រៃស មុននឹងចាប់គេត្រូវតែមេសម្រេច ។ ឯចំណែក ផែនការបង្កបង្កើនផលយ៉ាងម៉េច? ចាត់ចែងកម្លាំងយ៉ាងម៉េច ស្អីយ៉ាងម៉េច គេម្ចាស់ការធ្វើទេ ។ ក៏ប៉ុន្តែ គេត្រូវតែទទួលខុសត្រូវចំពោះមុខបក្សដាច់ខាតគ្មានបាតុភាពរើកម្លាំងគ្រប់គ្រង ហើយរត់ទេ ។ បើសិនជារើកម្លាំងគ្រប់គ្រងហើយរត់ គឺអ្នកឯងទទួលខុសត្រូវចំពោះមុខបក្សហើយ ចំពោះមុខខ្ញុំ ចំពោះមុខបក្សពីខាងលើទៀត ។ ក្នុងករណីដែលមានមនុស្សរត់ មនុស្សបះបោរ ហើយរត់ ។ មិនកែលកងទេ ទាំងអស់ភាគច្រើនណាស់បះបោរ ហើយរត់ អាហ្នឹងទទួលខុសត្រូវចំពោះមុខបក្សហើយ (អ្នកនៅព្រៃស) ។ ខ្ញុំត្រឹមប៉ុណ្ណេះហើយ ។

**ចៅក្រម ហ្សង់ម៉ាកឡាវែន៖**

ខ្ញុំអត់មានសំណួរផ្សេងទៀតទេ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់ជនជាប់ចោទបន្ថែមទៀតទេ? មានសូមអញ្ជើញលោកធូ មណី ។

**ចៅក្រម ធូ មណី៖**

**ស៖** លោកបានបញ្ជាក់ពីម្សិលមិញដែរថា មន្ទីរស-២១ ធ្លាប់នាំជនជាប់ទោស អ្នកទោសពីគុកតាខ្មៅ យកមកធ្វើការសាកសួរចម្លើយនៅក្នុងមន្ទីរស-២១ ។ អ៊ីចឹងតើលោកអាចបញ្ជាក់បានទេ ថាតើគុកតាខ្មៅ មានកន្លែងសម្រាប់សួរចម្លើយដែរ?

**ឆ៖** គុកតាខ្មៅនេះ ខ្ញុំដឹងរឿងតិចណាស់ ។ ខ្ញុំ, ណាត នាំចូលទៅម្តង ទៅវាក់នឹងមិត្តធី ខ្ញុំដកខ្លួនថយ ។ ក្នុងឋានៈជាអនុប្រធានខ្ញុំអត់ចង់ដឹងពួកិច្ចការអីទេ ។ ដូចខ្ញុំបានជម្រាបអង្គជំនុំជម្រះជាហូរ

ហែមកហើយថា ខ្ញុំអត់ចង់ធ្វើការងារនគរបាលនេះទេ ខ្ញុំចៀសជាអតិបរិមា មិនឲ្យដឹងឮរឿងអីច្រើនពេក ។ និយាយនេះវាជារឿងពិត មិនមែនជារឿងខ្ញុំចង់គេចទេ ។ ប៉ុន្តែ ព័ត៌មាននេះ រឿងនេះខ្ញុំវាមិនដឹងច្បាស់មែន ។

[១០:១៥:៣៥]

គ្រាន់តែសន្និដ្ឋានថា នៅពេលដែលសួរចម្លើយ យើងខ្ញុំសួរនៅ “A”, (ចំណុច A ដែលយើងខ្ញុំគូរនៅលើផែនទី) តាមពិតអ្នកទោសភាគច្រើនគេឃុំឃាំងនៅតាខ្មៅឯណោះ គេយកបន្តិចបន្តួចយកមកសួរនៅ “A” ។ ដល់ក្រោយមក កន្លែងសួរចម្លើយទៅសួរនៅប៉េហ្សី ហើយនិងកន្លែងអប់រំ កងសួរចម្លើយនៅប៉េហ្សី (PJ) ក៏អ្នកទោសភាគច្រើនគេឃុំនៅនុំង ដោយមិត្តហ៊ី ទទួលខុសត្រូវរត់ចុះរត់ឡើងតាមបញ្ជាណាត ។

ហើយដល់ស-២១ នេះ វាត្រឡប់ពី *“PJ”* មកដល់កន្លែង “A” ដដែលហ្នឹងវិញក៏អ្នកទោសភាគច្រើន បើតាមខ្ញុំសន្និដ្ឋានក៏នៅតែតាខ្មៅ, ពេទ្យឆ្កួត ។ ដូច្នេះ តាខ្មៅពេទ្យឆ្កួតនេះ វាដាក់អ្នកទោស បើតាមខ្ញុំស្មានដូចជាគ្មានកន្លែងសួរ ព្រោះកម្មាភិបាលសួរនៅភ្នំពេញទាំងអស់ ។ ដំបូងសួរនៅកន្លែងអក្សរ “A” ដែលខ្ញុំដាក់អក្សរ “A” នុំង ហើយដល់ក្រោយមកខ្ញុំប្រមូលទាំងអស់ទៅចូលក្នុងវិទ្យាល័យពញាយ៉ាត ។

សរុបមកសូមជម្រាបលោកចៅក្រមថា តាមកាលវិភាគនិងតាមការសន្និដ្ឋានក្នុងពេលបច្ចុប្បន្ននេះ តាខ្មៅគ្មានកន្លែងសួរទេ ។

**ស៖** លោកក៏បានបញ្ជាក់កន្លងមកដែរថា គុកតាខ្មៅនេះអាចបង្កើតឡើងប្រហែលជាពីរ ឬបីថ្ងៃក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ប៉ុន្តែ អង្គភាពស-២១ នេះបានបង្កើតឡើងនៅប្រហែលជាក្នុងថ្ងៃទី ១៥ ខែសីហា ឆ្នាំ១៩៧៥ ដូច្នេះ គុកតាខ្មៅនេះ វាបានកើតឡើងមុនពេលដែលមន្ទីរស-២១ នេះកើតឡើង ។ ដូច្នេះ តើលោកអាចបញ្ជាក់បានទេថា តើក្នុងអំឡុងពេលអនុវត្ត ឬក៏ដំណើរការគុកតាខ្មៅនេះ មានការសួរចម្លើយអីដែរមុនដែលពេលគេកើតស-២១ ដើម្បីនាំអ្នកទោសយកមកសួរនៅស-២១ នេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! រឿងសួរចម្លើយនៅគុកតាខ្មៅ មិនដឹងជាយ៉ាងម៉េចទេ ។ ក៏ប៉ុន្តែនៅពេលដែលទន្ទឹមគ្នានឹងមុននឹងកកើត មុននឹងពេលដែលខ្ញុំចូលទៅរួមជាមួយនឹងគេកកើតទៅជាស-២១ នេះ ណាត នាំខ្ញុំទៅគុកពិសេសម្តង ។ ចូលទៅគុកពិសេសនេះ របស់ដែលខ្ញុំចាប់អារម្មណ៍ដំបូងគេហ្នឹង គឺ មិត្តហ៊ី អង្គុយនៅលើជើងម៉ាខាងក្រៅ គេអានសេចក្តីសារភាព ។ សូមបញ្ជាក់ថា ខ្ញុំ និង

មិត្តហ៊ា ហ្នឹងក៏អត់ទៅណាឆ្ងាយពីគ្នាដែរ ។ ធ្លាប់ជាប់គុកជាមួយគ្នានៅឆ្នាំ១៩៦៨ ជំនាន់ លន់ នល់ គាត់ចាប់ខ្ញុំដាក់គុក ។

[១០:១៩:១៣]

ខ្ញុំឃើញ ។ ដូច្នេះ ណាត នាំខ្ញុំតទៅទៀត ចូលទៅក្នុងកន្លែងសួរចម្លើយ ទៅដល់ឃើញគេអង្គុយតុអីស្អាតបាត ប៉ុន្តែជើងជាប់ខ្នោះ ។ ណាត ប្រាប់ខ្ញុំថា ស ភន អ្នកដែលជាប់គុកនៅនុ៎ង អ្នកដែលកំពុងតែអង្គុយសរសេរនុ៎ង ។ ឆ្លងតាមសភាពការណ៍ដែលខ្ញុំឃើញនេះ ខ្ញុំសូមសន្និដ្ឋានថា នៅតាខ្មៅ ប្រហែលជាគេមិនសួរទេ គេមកសួរនៅវីឡាស្តេចក្រុមព្រះ មុន្នីរ៉េត ។ ដល់កកើត-- ដល់ស-២១ ចូលទៅក្នុងកិច្ចប្រតិបត្តិការពេញលេញ គេលុបចោលអាកន្លែងសួរចម្លើយនៅវីឡាស្តេចក្រុមព្រះស៊ីសុវត្ថិមុន្នីរ៉េត គេយកមកសួរនៅត្រង់កន្លែង “A” ដែលខ្ញុំសរសេរហ្នឹង ។

សរុបមកតាខ្មៅ ពេទ្យឆ្កួត វានៅជាកន្លែងឃុំឃាំងតាំងពី ១៧មេសា រហូតមកដល់ប្រហែលជាក្នុងខែមិថុនា ១៩៧៦ ទើបបានចប់ ។ ចំណែកកន្លែងសួរចម្លើយ បើតាមការវិភាគ និងការសន្និដ្ឋានគឺនៅ វីឡាស្តេចក្រុមព្រះ ស៊ីសុវត្ថិ មុន្នីរ៉េត ដំបូង ។ បន្ទាប់មកវានៅកន្លែង “A” បន្ទាប់មក ទៀតវាទៅ *“PJ”* បន្ទាប់មកវាមកពី *“PJ”* មកន្លែង “A” វិញ ។ បានចុងបញ្ចប់ទាំងអស់ ប្រមូលដាក់ទៅកន្លែង “B” គឺវិទ្យាពញាយ៉ាត នេះឯង ។ សូមអស់ប៉ុណ្ណេះ ។

**ស៖** ក្រោយពីអង្គភាពមន្ទីរស-២១ បង្កើតឡើងគេនាំអ្នកទោសពីតាខ្មៅ យកមកសួរចម្លើយនៅដូចលោកបានបញ្ជាក់ថា នៅត្រង់ចំណុច “A” នៃផ្នែកមួយរបស់មន្ទីរស-២១ ។ អ៊ីចឹងតើនៅពេលដែលគេសួរចម្លើយអ្នកទោសចប់ តើគេមានដែលកម្ទេចអ្នកទោសនៅក្នុងអង្គភាពស-២១ ដែរ?

**ឆ៖** សូមជម្រាបលោកចៅក្រមថា រឿងកម្ទេចខ្ញុំមិនសូវជាយកចិត្តទុកដាក់ទេ ។ ខ្ញុំនិយាយនេះមិនមែនមានន័យថា គេអ្នកកម្ទេច គេជាឧក្រិដ្ឋជនទេ ក៏ប៉ុន្តែអានេះ វាជាសកម្មភាពឧក្រិដ្ឋដែលបក្សតម្រូវឲ្យគេធ្វើ គេត្រូវតែធ្វើ ។ បើគេមិនធ្វើ វាខុសចំពោះមុខខ្ញុំ វាខុសចំពោះមុខបក្ស ខ្ញុំនៅទទួលខុសត្រូវពីលើគេ ។ នេះយើងនិយាយតាមជាក់ស្តែង ។ ក៏ប៉ុន្តែ បើនិយាយពីជាក់ស្តែងទៀត ប្រហែលជាអាចមានអ្នកដែលគេសម្លាប់នៅនឹងត្រង់កន្លែង “A” ប្រហែលជាមាន ។ ពីព្រោះអី? ខ្ញុំសូមនិយាយរឿងមួយនៅពេលដែលចាប់ផ្តើមចាប់ដៃគ្នាដំបូងស-២១ ចូលទៅក្នុងការចាប់ដៃគ្នាសហប្រតិបត្តិគ្នាធ្វើសកម្មភាពហើយ រវាង៧០៣ និងស-២១ ។ ថ្ងៃមួយមេបញ្ជា អង្គាល់នោះ ដូចជា ណាត គាត់ចេញហើយ មិត្តឌុចឲ្យគេកម្ទេច នង សួន ហើយនិង សួស នៅ ហៅ ឈូក ។ គាត់បញ្ជាក់ទៀត កម្ទេចប្រហែលជាម៉ោង

ប្រាំភ្លឺ "មិត្ត, ទៅមើលគេកម្ទេច" ។

[១០:២៣:០០]

បញ្ហានេះកន្លងមកហើយ វាអត់ទាន់មានពេលចង់នឹងនិយាយ ឥឡូវខ្ញុំនិយាយ៖

ការកម្ទេចបែប៧០៣ ខុសពីការកម្ទេច បើតាមខ្ញុំយល់ របស់មន្ទីរ១៣ ហើយនិងកន្លែងផ្សេងទៀត គេមានមោទនភាពណាស់ ។ គេថាកម្ទេចដោយយកចាក់កាំបិត តាមអាត្រង់នេះ ។ វាធានាក្នុងរឿងស្លាប់ប្រាកដ ។ ថ្ងៃនុ៎ង ខ្ញុំទៅមើលតាមបញ្ហាមេ ដោយខានមិនបាន ។ មិត្តហ៊ី គាត់ចាត់ចែង គាត់ដាក់ដោតហ្វាមួយមក ។ មនុស្សដែលត្រូវកម្ទេចតែពីរនាក់ហ្នឹងទេ នង សួន ហើយនិង សួស នៅ ហៅ ឈូក ថ្ងៃខែ ខ្ញុំអត់ចាំទេ ។ ដូច្នេះ សកម្មភាពនេះបញ្ជាក់ថា មានមនុស្សមួយចំនួនត្រូវកម្ទេចនៅកន្លែង "A" នៃបច្ចុប្បន្នទីកដី-- នៃទីកដី ស-២១ ពេលនោះ ។

តមកទៀត នៅពេលដែលកម្ទេច លី ផែល ហៅ ផែន បីថ្ងៃហើយ ស្រាប់តែ បងខៀវ លោកគ្រូ សុន សេន ប្រាប់មក មិត្តឌុច គាស់ៗខ្មោចអាផែន ឲ្យគេ ថតបញ្ជូនមកខ្ញុំ ។ ខ្ញុំខឹងដែរអង្គាល់នោះ ល្ងួចជេរក្នុងពោះ ប៉ុន្តែមិនហ៊ានធ្វើអីគេ ខ្ញុំជេរមិនឲ្យនរណាឮទេ ។ បើមិនទុកចិត្តដដែល ប្រើខ្ញុំធ្វើស្អី? ប៉ុន្តែគាស់នៅតែគាស់អ៊ីចឹង គាស់ហើយថត ។ ដូច្នេះ ខ្មោច លី ផែន ក៏កប់នៅក្នុងកន្លែង "A" នេះ របស់មន្ទីរស-២១ ។ គេសម្លាប់ដោយវ៉ៃ ឬក៏គេសម្លាប់ដោយចាក់ ខ្ញុំអត់ច្បាស់ទេ អត់ចង់ដឹង ចង់ឮអីទេ ។

សូមបញ្ជាក់ថា ខ្មោចដែលស្លាប់បីថ្ងៃ មិនហើមកក្លាក់កក្លេះអីប៉ុន្មានពេកទេ ប៉ុន្តែគ្រាន់តែចោលក្លិនស្អុយ យើងខ្ញុំប្រើ *ក្រេហ្ស៊ីល* អស់បីដប ។ បន្ទាប់មកទៀត មិនសុខមិនសាប់ មេប្រើខ្ញុំឲ្យទៅត្រួតពិនិត្យទៅជើងឯក ប្រើបីដង បានខ្ញុំទៅ ។ នេះរឿងនៅជើងឯង វាជារឿងមួយដែលបាននិយាយគ្នាហូរហែមកហើយ ខ្ញុំសូមកាត់ខ្លីប៉ុណ្ណេះ ។

នឹកឡើងឃើញសកម្មភាពអស់នេះ បានជាហេតុផលមួយនាំឲ្យខ្ញុំវិភាគនិងសន្និដ្ឋានថា មេទុកចិត្តខ្ញុំ ។ មេមិនទុកចិត្ត ណាត មិនមែនត្រឹមតែទុកចិត្ត ណាត មិនទុកចិត្តដល់ខាងក្រោមទៅទៀត ។ បានថា មើលទៅរឿងចាស់ វាទៅជាអ្នកណាផ្សេងបាត់អស់ទៅហើយ ។ នេះខ្ញុំសូមបញ្ជាក់ថា កន្លែង ស-២១ ត្រង់អក្សរ "A" នេះ នៅភ្នំពេញម្តុំអក្សរ "A" អានេះពិតជាមានសម្លាប់មនុស្ស ដែលខ្ញុំបានដឹង បានដឹងឮចុះដែលខ្ញុំមិនឃើញ មិនដឹងឮប៉ុន្មាន នៅត្រង់ណាខ្លះ ខ្ញុំអត់ហ៊ាននិយាយទេ ។ សូមបញ្ចប់ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងដប់មួយខ្វះដប់នាទីចូលវិញដើម្បីបន្ត

ដំណើរការសវនាការ ។

*[សវនាការសម្រាកពីម៉ោង ១០:២៧ នាទី ដល់ម៉ោង ១០:៥៩ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ លោកមេធាវីមានបញ្ហាអីទៅ? សូមអញ្ជើញ ។

**លោក អាឡាំង វែនណឺ៖**

ខ្ញុំសូមការអនុញ្ញាតដើម្បីលើកអំពីបញ្ហាបន្ទាន់ដ៏ខ្លីមួយ បើសិនជាលោកប្រធានអនុញ្ញាត ។

**ប្រធានអង្គជំនុំ៖**

ខ្ញុំអនុញ្ញាត សូមអញ្ជើញ ។

**លោក អាឡាំង វែនណឺ៖**

សូមអរគុណលោកប្រធាន ។ លោក លោកស្រីចៅក្រម កាលពីថ្ងៃទី២៣ នោះ គឺថាលោកបានផ្តល់សេចក្តីជូនដំណឹងមួយ អំពីការរៀបចំកាលបរិច្ឆេទសវនាការ ហើយលោកចៅក្រមបានបង្ហាញថា លោកនឹងផ្តល់ដំណឹងដល់ភាគីពាក់ព័ន្ធ នៅថ្ងៃសវនាការពីថ្ងៃ១ ដល់ថ្ងៃទី៥ ខែមិថុនា តើលោកប្រធានអាចផ្តល់ឲ្យពួកយើងអំពី ថាតើនៅពេលហ្នឹងថ្ងៃសវនាការហ្នឹង មានដំណើរការយ៉ាងដូចម្តេច នៅក្នុអំឡុងពេលនោះ? បើសិនជាអាច តើលោកប្រធានអាចផ្តល់ឲ្យយើងមុនរយៈពេលសម្រាកពីរអាទិត្យនៅសប្តាហ៍ក្រោយនេះបានទេ? ហើយដូចនេះដែរ បើសិនជាពួកយើងអាចទទួលបាន អំពីជូនដំណឹងនៅក្នុងអំឡុងពេលសម្រាកពីរសប្តាហ៍ នៅសប្តាហ៍ក្រោយហ្នឹង តើលោកអាចផ្តល់កាលវិភាគ សម្រាប់ខែមិថុនា ឬក៏កក្កដាដែរទេ? ឬក៏ខែសីហាហ្នឹងថា តើនៅក្នុងអំឡុងពេលខែ-- ពីរបីខែហ្នឹងសាលសវនាការនឹងត្រូវការសម្រាកដែរ ឬក៏យ៉ាងម៉េចនោះ? សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ដែលបានចាប់អារម្មណ៍បញ្ហានេះ ។ អង្គជំនុំជម្រះសូម ជម្រាបដល់ ភាគីថា បញ្ហាកាលវិភាគដំណើរការសវនាការនេះ អង្គជំនុំជម្រះធានាដល់ភាគីទាំងអស់ នៅក្នុងការកំណត់ជាមុននូវកាលបរិច្ឆេទនៃដំណើរការសវនាការប្រចាំសប្តាហ៍ក៏ដូចជាប្រចាំខែដែរ គឺយើងកំណត់យ៉ាងតិចមុន១៥ថ្ងៃ ទៅបីសប្តាហ៍ ។ បានន័យថាទៅ ២០ ឬ ២១ថ្ងៃ ដើម្បីងាយស្រួលភាគីទាំងអស់ចូលរួមក្នុងការសិក្សាស្រាវជ្រាវ ដើម្បីធ្វើការពិភាក្សាដេញដោលនៅក្នុងពេលសវនាការ ។

ហេតុផលសប្តាហ៍នេះ ដោយសារការដែលយើងបានគ្រោងទុកនូវកាលវិភាគក្នុងការដំណើរការសវនាការកន្លងមកវាមិនបានត្រឹមត្រូវទាំងអស់ទេ ។ ឧទាហរណ៍៖ ម-១៣ យើងគ្រោងមួយសប្តាហ៍ អ៊ីចឹង សម្រាប់តែវាមានសាក្សីមួយចំនួនកិលមកត្រូវធ្វើជាមួយនឹងការបង្កើតស-២១ ។ ឧទាហរណ៍ អ៊ីចឹង ។ ហើយបញ្ហាឥឡូវនេះ យើងកំពុងធ្វើការអភិវឌ្ឍន៍នូវកម្មវិធីរបស់យើងជាបន្តបន្ទាប់ ដើម្បីយើងថាថ្ងៃព្រហស្បតិ៍ អាចព្រឹក ឬក៏យ៉ាងយូររសៀលថ្ងៃព្រហស្បតិ៍ យើងនឹងបញ្ចេញនូវកាលវិភាគនេះសម្រាប់ចុងខែឧសភាព្រមទាំងខែមិថុនាផង ។ ហើយនិងជាបន្តបន្ទាប់ យើងធានាថា អង្គជំនុំជម្រះធានាថានឹងកំណត់កាលបរិច្ឆេទក្នុងការដំណើរការសវនាការអង្គហេតុនីមួយៗហ្នឹង ក្នុងការធ្វើសក្ខីកម្មជនជាប់ចោទ និងសាក្សីគឺយើងនឹងធ្វើជាបន្តបន្ទាប់ យើងមិនអាចគ្រោងសរុបឲ្យត្រូវបានទេ តាមស្ថានភាពនៃដំណើរការដែលយើងអនុវត្តកន្លងមក ។ អ៊ីចឹងប៉ុន្មានថ្ងៃនេះ យើងបានចាត់ចែងបញ្ហាហ្នឹងហើយប៉ុន្តែរង់ចាំព័ត៌មាននៅសប្តាហ៍នេះមើល៍ថា តើយើងធ្វើសវនាការតាមផែនការគ្រោងទុកនោះ វាត្រូវ ឬក៏មានការ អាចថានៅសេសសល់ប៉ុន្មាន? ដើម្បីយើងព្យាករណ៍ដាក់នូវកាលវិភាគសវនាការនៅសប្តាហ៍ទីបីនៃឧសភានោះ វាសមស្រប កុំឲ្យខុសច្រើនពេក តែប៉ុណ្ណឹងទេ ។

[១១:០៣:៥៧]

**លោក អាឡាំង វែនណឺ៖**

សូមអរគុណហើយលោកប្រធាន ។ ហើយជាបន្ថែមទៅលើចំណុចនេះ ប្រសិនបើជាគោលការណ៍លោកប្រធានអាចប្រាប់ដល់ភាគីពាក់ព័ន្ធនេះទេ គឺថាមិនមែនលម្អិតដល់ដំណើរការកាលបរិច្ឆេទនោះទេ។ ប៉ុន្តែបើសិនជានៅខែកក្កដា ឬក៏ខែសីហាហ្នឹង តើអង្គសវនាការហ្នឹងត្រូវការឈប់សម្រាកទេ សម្រាប់ខែទាំងពីរហ្នឹង? គឺថាខ្ញុំមិនចង់ដឹងព័ត៌មានលម្អិតពីកាលបរិច្ឆេទទេ គ្រាន់តែចង់ដឹងថាតើសវនាការហ្នឹងនឹងត្រូវការឈប់សម្រាកទេនៅខែកក្កដា និងខែសីហា នោះ?

**ប្រធានអង្គជំនុំ៖**

អរគុណ ។ បញ្ហានេះក៏យើងនឹងផ្តល់ព័ត៌មានដែរ ប៉ុន្តែជាគោលការណ៍រួម-- ផែនការនៃដំណើរការសវនាការ យើងបានជម្រាបជូនរួចហើយ ។ ហើយប្រសិនបើសវនាការ ថ្ងៃធ្វើការក្នុងមួយសប្តាហ៍ប្រាំថ្ងៃពេញ គឺយើងធ្វើការសវនាការបួនថ្ងៃ ហើយទុកមួយថ្ងៃសម្រាប់ពិភាក្សាគ្នា ហើយធ្វើកិច្ចការផ្សេងទៀត ។ ហើយប្រសិនបើសវនាការសម្រាប់មួយសប្តាហ៍ហ្នឹង ឈប់មួយថ្ងៃ ឈប់សម្រាកបុណ្យ ឬក៏សម្រាកបុណ្យទានផ្សេងៗនោះមួយថ្ងៃ គឺសវនាការ គឺយើងធ្វើតែបីថ្ងៃទេ យើងទុកមួយថ្ងៃសម្រាប់

ពិភាក្សាធ្វើការងារផ្សេងៗ ។ ហើយបញ្ហា គឺយើងកំពុងតែប្រមើលមើល៍នៅក្នុងអំឡុងពេលនៃការបទពិសោធន៍ដំណើរការប្រព្រឹត្តទៅប៉ុន្មានសប្តាហ៍កន្លងមកនេះឃើញថាក៏មានបញ្ហាដែរ របស់អង្គជំនុំជម្រះរហូតដល់យើងបានផ្អាកដំណើរការសវនាការមួយពេល ដើម្បីទៅជជែកពិភាក្សា រកមធ្យោបាយដើម្បីរកដំណោះស្រាយជូនទៅសំណើរបស់ភាគីដែលបានស្នើសុំ ។

អ៊ីចឹងប្រសិនបើជាទៅមុខទៀត យើងនឹងព្យាករណ៍មើលថាប្រសិនបើមានបញ្ហាច្រើន ដូចអ្វីដែលយើងដំណើរការកន្លងមកនេះប្រហែលជាអង្គជំនុំជម្រះនឹងមានការកែប្រែទៅលើដំណើរការសវនាការអាចកាត់បន្ថយមើលទៅមួយសប្តាហ៍បីថ្ងៃអីជាដើម អាហ្នឹងទៅតាមលទ្ធភាពជាក់ស្តែង ។ ប៉ុន្តែបញ្ហាជារួមគឺអង្គជំនុំជម្រះនឹងជម្រាបជូនជាទូទៅអំពីកាលបរិច្ឆេទហ្នឹង បើមានបំណងអ៊ីចឹងយើងនឹងជម្រាបទូទៅតែម្តង អំពីថាត្រូវធ្វើសវនាការ ហើយមិនធ្វើសវានាការដូចដែលយើងបានជម្រាបកន្លងមកនេះ ។ ដូចជាសម្រេចថា ថ្ងៃពី ថ្ងៃ១ ដល់ថ្ងៃ១៥ មិនធ្វើសវនាការដូច្នេះ ។

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកានេះ ជូនទៅសហព្រះរាជអាជ្ញាដើម្បីធ្វើការ។ អញ្ជើញលោក ហ្សង់ស្វ័រ រូ ។

[១១:០៦:៤០]

**លោក ហ្សង់ស្វ័រ រូ៖**

ឥឡូវនេះយើងនិយាយអំពីកាលបរិច្ឆេទនៃសវនាការ មុននឹងយើងបន្តទាក់ទងដល់សវនាការលើអង្គសេចក្តី ខ្ញុំសូមជូនដំណឹងដល់អង្គចៅក្រមទាំងអស់ថា ខ្ញុំត្រូវចាកចេញភ្នំពេញនៅល្ងាចនេះ ។ ដូច្នេះហើយខ្ញុំមិនអាចចូលរួមអង្គសវនាការនៅថ្ងៃស្អែកនិងថ្ងៃខានស្អែកបានទេ ។ កាលពីរសៀលម្សិលមិញខ្ញុំបាននិយាយតាមទូរស័ព្ទជាមួយនឹងចៅក្រមនៅអង្គបុរេជំនុំជម្រះសម្រាប់តុលាការពិសេសនៅប្រទេស *ឡេបាណុន* ទាក់ទងទៅនឹងវិធាន៧ ទាក់ទងនឹងលក្ខន្តិកៈពិសេសរបស់តុលាការនោះ ពេលហ្នឹងចៅក្រមនៃអង្គជំនុំជម្រះ ។ គាត់នឹងធ្វើសវនាការនៅថ្ងៃស្អែកហ្នឹងនៅទីក្រុងឡាអេ ដើម្បីធ្វើការសម្រេចលើការពន្យារពេលការឃុំខ្លួនបណ្តោះអាសន្ន ឬក៏ធ្វើការដោះលែងឧត្តមសេនីយ៍ទាំងបួននាក់ ដែលត្រូវតែបានកំពុងជាប់ឃុំឃាំងហើយដើម្បីជាប្រយោជន៍ដល់អង្គបុរេ ដល់អង្គជំនុំជម្រះ ។ អ្នកជាប់ចោទទាំងអស់គឺគាត់ធ្វើការតវ៉ានឹងការឃុំខ្លួនដែលមានភាពចម្រូងចម្រាស់នេះ ហើយចៅក្រមនៃអង្គបុរេជំនុំជម្រះនោះត្រូវធ្វើសេចក្តីដើម្បីសវនាការដោយមិនអាចពន្យារបាន ។ ហើយក្នុងករណីខ្ញុំជាប្រធានក្រុមមេធាវីការពារក្តីនោះ អ៊ីចឹងខ្ញុំត្រូវចូលរួមនៅក្នុងសវនាការនោះ ។

ដូច្នេះ ខ្ញុំសូមសេចក្តីអនុគ្រោះពីលោកប្រធានដែលខ្ញុំត្រូវចាកចេញទៅនោះ ហើយដោយសារពេលវាមានរយៈពេលខ្លី ខ្ញុំមិនអាចមាននរណាម្នាក់ដើម្បីមកជំនួសខ្ញុំបានទេ គឺលោក ការ សាវុត្ថ បានប្រាប់ខ្ញុំថា គាត់រៀបចំដើម្បីតំណាងឲ្យកូនក្តីរបស់ខ្ញុំនៅក្នុងអំឡុងពេលពីរថ្ងៃនេះ ហើយខ្ញុំនឹងត្រឡប់មកវិញនៅខែឧសភា ។ សូមអរគុណលោកប្រធាន ។

[១១:០៩:២៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីក្រុមបី ។

**លោក ហ្វីលីព កាណុន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំនឹងនិយាយខ្លីទេ ។ ខ្ញុំមានចំណុចពីរ ដែលខ្ញុំចង់លើកឡើង ។ ទីមួយ ខ្ញុំចង់បង្ហាញអំពីការគាំទ្រទាំងស្រុងរបស់ខ្ញុំទៅលើអ្វីដែលខ្ញុំលោក អាឡាំង វ៉ែនណឺ បាននិយាយ ហើយលោកចៅក្រមបានឆ្លើយតបទៅនឹងសេចក្តីបារម្ភរបស់គាត់ ។ ប៉ុន្តែ ខ្ញុំចង់ធ្វើការបន្ថែមថា នៅពេលដែលយើងធ្វើសេចក្តីសំណើបែបនេះដល់អង្គសវនាការ គឺមិនមែនដើម្បីជាភាពងាយស្រួលនោះទេ ។ យើងធ្វើដូច្នេះ ដើម្បីឲ្យយើងអាចរៀបចំសំណុំរឿងរបស់យើងបាន ហើយមានពេលវេលាគ្រប់គ្រាន់ចាំបាច់ដើម្បីធ្វើការពិនិត្យសម្ភារៈឯកសារនានា ទៅតាមការកំណត់កាលបរិច្ឆេទនៃការសវនាការនោះជាមួយនឹងបញ្ហាផ្សេងៗដែលបានលើកឡើងនៅក្នុងអំឡុងពេលសវនាការផងដែរ ។

លោកប្រធាន ខ្ញុំមានសំណួរទីពីរ នៅពេលដែលយើងបានសម្រាកកាលពីថ្ងៃព្រហស្បតិ៍កន្លងទៅនេះ អង្គសវនាការបានធ្វើការប្រកាសថា នៅពេលរសៀលថ្ងៃនុ៎ង គឺត្រូវបានផ្អែក មិនមានសវនាការទេ ។ ពេលនុ៎ងលោកប្រធានបាននិយាយថា បើលោកមានអង្គប្រជុំដើម្បីធ្វើសេចក្តីសម្រេចទៅលើការប្រើឯកសាររបស់មជ្ឈមណ្ឌលកម្ពុជា (DC-Cam) លោកក៏បានបង្ហាញផងដែរថាសេចក្តីសម្រេចរបស់លោកនឹងធ្វើ នឹងជម្រាបប្រាប់មកដល់ពួកយើងនៅថ្ងៃច័ន្ទទី២៧ គឺថ្ងៃច័ន្ទម្សិលមិញនេះ ។ អ៊ីចឹង គឺថាយើងនឹងឈប់សម្រាកនៅថ្ងៃព្រហស្បតិ៍សប្តាហ៍នេះ រយៈពេលមួយរយៈធំ ។ ដូច្នេះ ខ្ញុំយល់ថា បើសិនជាការងាយសម្រួលដល់ការរៀបចំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងមេធាវីការពារក្តីនោះ គឺថាអ្វីដែលខ្ញុំសួរជាទូទៅខ្ញុំសួរ សូមឲ្យលោកប្រធាននិយាយថា បានឬក៏មិនបាន ។អ៊ីចឹង អ្វីដែលខ្ញុំចង់ដឹងនោះ គឺថាតើយើងគួរតែទន្ទឹង ឬក៏ប្រើឯកសារនោះ ឬមួយក៏យើងរង់ចាំសេចក្តីសម្រេចរបស់លោកប្រធានសិន ។

[១១:១២:២០]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ។ បញ្ហានេះ ខ្ញុំសូមជម្រាបថាអង្គជំនុំជម្រះ ការកំណត់ក្នុងការពិភាក្សាលើបញ្ហានោះ ប្រហែលជាអាចមានការភន់ច្រឡំក្នុងការនិយាយ ឬក៏ក្នុងការបកប្រែថា នឹងសម្រេចអំពីបញ្ហានុំងចេញនៅថ្ងៃច័ន្ទទី២៧ នោះ ។ ដោយហេតុផលនៃសេចក្តីសម្រេចនោះ មានលក្ខណៈស្មុគស្មាញ ហើយមានលក្ខណៈវែងដែលទាមទារឲ្យមានការសរសេរថែងអំពីយោងទៅច្បាប់និងវិធាន ហើយមានទាំងការយុត្តិសាស្ត្រអន្តរជាតិមួយចំនួនផង ។ នេះ គឺទាមទារការធ្វើហ្មត់ចត់មួយ ។ បញ្ហាទីពីរ ក្រោយពីធ្វើហើយយើងគណនាអំពីពេលវេលានៃការបកប្រែភាសា អ្នកបកប្រែភាសាមិនអាចជាធានាការក្នុងការបកប្រែបានទេ ។អ៊ីចឹងគោលបំណងនៃការជជែកពិភាក្សានោះ គឺដើម្បីមានឱកាសនៅក្នុងការជជែកឲ្យដាច់ស្រាច់អំពីគោលការណ៍នានា ដែលជាមូលដ្ឋានក្នុងការសម្រេចសេចក្តី ហើយបញ្ហាទីពីរគឺទើបចាប់ផ្តើមរៀបចំនូវឯកសារនោះ ហើយបន្ទាប់មក គឺទាមទារការបកប្រែ ។ អ៊ីចឹងសេចក្តីសម្រេចនោះនឹងប្រកាសនៅពេលដែលសម្រាកចូលឡប់មកវិញ គឺនៅសប្តាហ៍ទីបី នៃខែឧសភាឯណោះ ទើបយើងបានតាមគណនាពេលវេលាទៅ ដោយរង់ចាំទុកពេលឲ្យអ្នកបកប្រែភាសាគេបានបកប្រែភាសាត្រឹមត្រូវ។

បញ្ហាមួយទៀត គឺដោយសារយើងរៀបចំបន្ទាន់នោះ គឺក្នុងគោលបំណងនៅពេលដែលធ្វើដេញដោល សវនាការដេញដោលលើអង្គហេតុដទៃទៀតបន្ទាប់ៗនោះ ដែលកាន់តែមានបញ្ហាជ្រាលជ្រៅ និងស្មុគស្មាញនោះ យើងធ្វើកិច្ចការនេះជាមុន ដើម្បីឲ្យផ្តល់ឱកាសភាគីលើកឯកសារមក តាមវិធាន តាមការណែនាំសេចក្តីសម្រេចនោះ ។ អ៊ីចឹង ប្រហែលជាអាចមានការភាន់ច្រឡំលើបញ្ហានេះ គឺមិនមែនសម្រេចចេញ-- សេចក្តីសម្រេចនោះ ថ្ងៃ២៧នោះទេ ពីព្រោះវាមានលក្ខណៈស្មុគស្មាញនៃបញ្ហា ។

[១១:១៥:០០]

**លោក ហ្វីលីព កាណុន៖**

អ៊ីចឹង ខ្ញុំសូមទោសដែលសំណួររបស់ខ្ញុំហ្នឹង វាមានភាពស្មុគស្មាញ ។ ខ្ញុំចង់លើកនូវបញ្ហាលំបាកមួយទៀត គឺថាតើលោកប្រធានមានសំណួរអាម៉េចដែរ? ទាក់ទងទៅនឹងបញ្ហាបកប្រែនោះ មានន័យថានៅពេលនុំងឯងលោកចៅក្រមហ្នឹង នឹងផ្តល់សេចក្តីសម្រេចទាក់ទងទៅនឹងបញ្ហាបកប្រែដែរមែនទេ?

**ប្រធានអង្គជំនុំ៖**

នោះជាសំណើរបស់ភាគី ហើយអង្គជំនុំជម្រះបានកត់ត្រាយកទៅពិចារណាសម្រេច ។ ត្រង់ថា

របៀបក្នុងការសម្រេចយ៉ាងណានោះ វាអាស្រ័យទៅលើទំហំនៃសិទ្ធិរបស់អង្គជំនុំជម្រះថា តើអង្គជំនុំជម្រះប្រើសិទ្ធិរបៀបណាចំពោះការិយាល័យរដ្ឋបាលនោះ ។ ពីព្រោះលក្ខខណ្ឌនៃអង្គជំនុំជម្រះ វាជាការសំណុំរឿង វាជារឿងដោយឡែក តើអង្គជំនុំជម្រះមានសិទ្ធិបញ្ជាផ្នែកខាងរដ្ឋបាលកម្រិតណា ។

អ៊ីចឹង បញ្ហានេះយើងបានជជែកពិភាក្សារួចហើយ ហើយយើងបានគ្រោងនៅរបៀបវារៈនៃការធ្វើការងាររួចហើយ ឯកភាពគ្នាជាគោលការណ៍រួចហើយ នៅតែចេញលិខិតចុះហត្ថលេខាជាផ្លូវការបញ្ជូនទៅឲ្យរដ្ឋបាល ហើយនិងចម្លងជូនឲ្យភាគីតែប៉ុណ្ណោះ ។

[១១:១៦:៤០]

**លោក ហ្វ៊ីលីព កាណុន៖**

សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តសូមប្រគល់វេទិកានេះជូនទៅសហព្រះរាជអាជ្ញា ។ តើព្រះរាជអាជ្ញាមានសំណួរអ្វីត្រូវសួរដល់ជនជាប់ចោទទេ អំពីអង្គហេតុដែលជារបៀបវារៈនៃការពិភាក្សាដេញដោលនៅពេលនេះ? បើមានសូមអញ្ជើញ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ តំណាងសហព្រះរាជអាជ្ញានឹងមានសំណួរដូចខាងក្រោម៖

**ស៖** ចំពោះលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ដូចលោកបានជ្រាបស្រាប់ហើយថា បក្សកុម្មុយនីស្តកម្ពុជាបានសម្រេចនូវគោលដៅរបស់ខ្លួនយ៉ាងធំសម្បើម គឺបង្កើតមន្ទីរស-២១ ហើយនៅក្នុងនុំងដែរ នៅក្នុងខែមីនា ឆ្នាំ១៩៧៦ លោកក៏បានក្លាយទៅជាប្រធានមន្ទីរសន្តិសុខស-២១ ដែរ ។ តើនៅពេលនោះ និងពេលបន្តបន្ទាប់មកទៀត ដែលមានលោក សុន សេន ជាប្រធានរបស់លោកនុំង ហើយក៏ជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជាដែរនុំង មានដែលជម្រាបលោកពីគោលបំណងនិងទិសដៅ ចំពោះមុខ នៅអនាគតនៃការបង្កើតមន្ទីរស-២១ ហ្នឹងដែរទេ?

[១១:១៨:៣២]

**ឆ៖** អរគុណលោកព្រះរាជអាជ្ញា ខ្ញុំសូមគោរពឆ្លើយដូចតទៅ៖ ស-២១កកើត(សូមទោស) ស-២១ ដែលខ្ញុំចាប់ទទួលភារកិច្ចជាប្រធាននៅខែមីនា ១៩៧៦ នេះជារឿងពិត ។ ហើយមេខ្ញុំ គឺលោកគ្រូសុន សេន ក្នុងផ្ទៃបក្សគាត់មិនមែនជាបក្ខជនធម្មតាទេ ជាសមាជិកអចិន្ត្រៃយ៍មជ្ឈិមត្រៀម ជាបុគ្គលទី

ប្រាំពីររបស់បក្ស ។ ហើយឯកសារថ្ងៃ៩ តុលា ឆ្នាំ១៩៧៥ ប៉ុល ពត ប្រគល់ភារកិច្ចឲ្យគាត់ជាសេនាធិការផង និងជាអ្នកទទួលខុសត្រូវខាងការងារសន្តិសុខផង ។

ក្នុងរឿងបំពេញកិច្ចប្រតិបត្តិការនៅស-២១ នេះ មេខ្ញុំតែងតែនិយាយថា ភារកិច្ចរបស់ស-២១ មិនមែនជាភារកិច្ចធ្វើចារកម្មទេ តែជាភារកិច្ចប្រឆាំងចារកម្ម ដែលបារាំងគេហៅថា *កង់ត្រេះស្បូណាល់* ហ្នឹងខ្ញុំសូមរាយការណ៍ជូនលោកសហព្រះរាជអាជ្ញាប៉ុណ្ណេះ សូមជ្រាប ។

[១១:២០:០៨]

**ស៖** ចុះការងារបន្តបន្ទាប់មកទៀតនោះ ដែលលោកបានៗបន្តភារកិច្ចជាប្រធានមន្ទីរស-២១នុ៎ង តើលោកបានយល់ថាគោលបំណងជាក់ទេ? តំណាងសហព្រះរាជអាជ្ញាគ្រាន់តែសួរបញ្ជាក់ថា គោលបំណងពិតប្រាកដរបស់មន្ទីរស-២១ ចរិតលក្ខណៈរបស់មន្ទីរហ្នឹង? ដែលបង្កើតមន្ទីរហ្នឹង? ពីចរិតពិតរបស់មន្ទីរហ្នឹង លោកយល់ទេ? លោកគ្រាន់តែថា លោកបានយល់ពីចរិតរបស់មន្ទីរហ្នឹង ដែលបានបង្កើតហ្នឹង?

**ឆ៖** សូមអរគុណលោកព្រះរាជអាជ្ញា ខ្ញុំសូមគោរពឆ្លើយដូចតទៅ៖ ប្រវត្តិទាំងមូលរបស់មន្ទីរ ស-២១ ចែកជាពីរកំណាត់ ។ កំណាត់ទីមួយ នៅពេលដែលខ្ញុំធ្វើជាអនុប្រធាន ហើយនិងមុនដែលខ្ញុំធ្វើជា ដែលខ្ញុំមកចូលរួមទៅទៀត ជាប្រវត្តិសម្រិតសម្រាំងអ្នករដ្ឋការចាស់ទាំងទាហាន ទាំងស៊ីវិល ។ ចាប់តាំងពីខ្ញុំមកកាន់កាប់កិច្ចការជាប្រធាន ខ្ញុំជឿថាលោកព្រះរាជអាជ្ញានៅចាំឯកសារសំខាន់មួយហើយ សេចក្តីសម្រេចចិត្តថ្ងៃ៣០ មីនា ១៩៧៦ និយាយអំពីការសម្រិតសម្រាំងផ្ទៃក្នុងជួរ និងក្រៅជួរ ដែលគេប្រគល់ភារកិច្ចទៅឲ្យកម្មាភិបាលសំខាន់បួនក្រុម មានសិទ្ធិសម្រេច ។ បានន័យថា ក្នុងចំណោមបួនក្រុមនុ៎ង តែកាលណាគេសម្រេចឲ្យកម្ទេចហើយពួកអានៅខាងក្រោម គឺមន្ទីរនគរបាលផ្សេងៗ ឬក៏អង្គភាពផ្សេងៗត្រូវតែចាប់បញ្ជូនទៅមន្ទីរនគរបាលដាក់គុក ។ ដាក់គុកហើយសួរចម្លើយដោយធ្វើទារុណកម្ម ហើយកម្ទេច ខានមិនបាន យើងប្រឆាំងនឹងភារកិច្ចសម្រេចរបស់អាបួនក្រុមនេះ គឺយើងប្រឆាំងមាគ៌ា ហើយយើងត្រូវមានទោស ។

[១១:២២:២៨]

ដូច្នេះ ខ្ញុំសូមរំឭកឡើងវិញថាស-២១ ដែលខ្ញុំឡើងកាន់កាប់កិច្ចការជាប្រធានមិនបានប៉ុន្មានថ្ងៃទេ ខាងលើចេញអាឯកសារហ្នឹង ។ ចាប់តាំងពីពេលនោះមក ស-២១ ទទួលភារកិច្ចសម្រិតសម្រាំងផ្ទៃក្នុងបួនក្រុមហ្នឹងអ្នកណាខ្លះ? ខ្ញុំសូមរំឭកខ្លីៗជូនលោកព្រះរាជអាជ្ញា ទីមួយ គឺលេខាភូមិភាគ ទាំងអស់មាន

ប្រាំពីរនាក់ ។ ប្រាំពីរភូមិភាគ មិនមែនប្រាំមួយទេ ប្រាំពីរ ។ ទីពីរ គឺប្រធានគណៈកម្មាធិការមន្ទីរមជ្ឈិម មន្ទីរ៨៧០ ។ ទីបី គឺអចិន្ត្រៃយ៍មជ្ឈិមទទួលខុសត្រូវសម្រេចកម្មេចក្នុងតំបន់ឯករាជ្យ ។ ទីបួន គឺសេនាធិការ សម្រេចកម្ទេចនៅក្នុងជួរកងទ័ពមជ្ឈិម ។ ដូច្នេះ ឯកសារក៏មាន ឯកសារជាគ្រឹះរបស់បក្សកុម្មុយនីស្តកម្ពុជាក៏មាន ឯកសារជាភស្តុតាងដែលនៅសល់ក៏មាន វាបញ្ជាក់ថាតាំងពីពេលដែលខ្ញុំបាទកាន់កាប់កិច្ចការជាប្រធានស-២១ មក លែងមានភារកិច្ចសម្រិតសម្រាំងអ្នករាជការចាស់របស់សាធារណរដ្ឋខ្មែរទៀតហើយ គឺសម្រិតសម្រាំងផ្ទៃក្នុងរបស់ខ្លួនឯងនេះ ។ សូមអរគុណ សូមបញ្ចប់ ។

[១១:២៤:០០]

**ស៖** សំណួរបន្តមកទៀតមានដូចខាងក្រោម៖

នៅក្នុងដំណាក់កាលស៊ើបអង្កេតនោះ លោកបដិសេធថានៅមន្ទីរស-២១ មិនដែលមានការចាប់ខ្លួនទេ ប៉ុន្តែនៅក្នុងដំណាក់កាលសវនាការនេះវាហាក់ដូចជា លោកទទួលស្គាល់ថាមានការចាប់ខ្លួនរបស់មន្ទីរស-២១ ។ ឧទាហរណ៍ ដែលមានការចាប់ខ្លួនរបស់ ឈឹម សំអោក ហៅ ប៉ង់ នោះ ដែលនៅផ្ទះរបស់លោកហ្នឹង តើមែនទេ? ហើយទីមួយថា តើអ្នកធំចំនួនប៉ុន្មាននាក់ហើយ ដែលបានចាប់ខ្លួននៅផ្ទះរបស់លោកនោះ?

**ឆ៖** អរគុណលោកសហព្រះរាជអាជ្ញា ដែលលើកបញ្ហានេះ ដើម្បីឲ្យខ្ញុំបញ្ជាក់ ។ កន្លងរួចមកហើយមានការជជែកវែកគ្នានៅរយៈកាលស៊ើបអង្កេតពិត ពីព្រោះ *កង់សិប* របស់ពាក្យចាប់វាមិនត្រូវគ្នាបញ្ញត្តិរបស់ពាក្យចាប់នោះ *កង់សិប* របស់ពាក្យចាប់មិនត្រូវគ្នា ។

ខាងការិយាល័យព្រះរាជអាជ្ញាចូលចិត្តនិយាយថា ចាប់គឺស-២១ អ្នកសម្រេចផង ហើយទៅធ្វើសកម្មភាពផង នេះដែលខ្ញុំបដិសេធ ។ បើសិនជានិយាយថា អាប្អូនក្រុមនោះវាសម្រេច ស-២១ គ្រាន់តែជាអ្នកអនុវត្តសកម្មភាពធ្វើម៉េចឲ្យស្ងាត់ កុំឲ្យតដៃបាន កុំឲ្យរត់រួច ហើយបញ្ចូលគុកឲ្យបាន អាហ្នឹង ស-២១ មានធ្វើមែន ។ ទីមួយ ធ្វើលើ កុយ ធួន ។ ទីពីរ ធ្វើលើ ឈឹម សំអោក ហៅ ប៉ង់ ដូច្នេះ ស-២១ នេះ ក៏ដូចជាមន្ទីរនគរបាលផ្សេងទៀតដែរ និងអង្គភាពដើមរបស់គេសម្រេចភារកិច្ចទៅតាមបទបញ្ជារបស់អាប្អូនក្រុមនុ៎ង ហ្នឹងសូមបញ្ជាក់ប៉ុណ្ណេះ ។ សំខាន់គឺរឿងយើងមិនទាន់យល់គ្នាខាង *កង់សិប* របស់ពាក្យ ។

[១១:២៦:២៣]

**ស៖** អរគុណ សំណួរខាងក្រោមមានដូចតទៅ៖

នៅពេលដែលលោកឡើងជាប្រធានមន្ទីរស-២១ នោះ លោកបានឆ្លើយថា គ្មានអ្នកណាបញ្ជូនមកមន្ទីរស-២១ ដែលគ្មានឆ្លងកាត់ សុន សេន ទេ ។ អ៊ីចឹងក្នុងន័យនេះ បានបញ្ជាក់ថា លោកនុំងបានដឹងទាំងអស់នូវរាល់អ្នកដែលបញ្ជូនចូលមកមន្ទីរស-២១ មិនអ៊ីចឹង? ដែលក្នុងនោះដែរ តែលោកបានបដិសេធថា លោកមិនបានដឹងទេ ក្នុងករណីដែលចាប់ មានសាស្ត្រចារ្យមួយមកដែលមកពីបារាំងនេះឈ្មោះ ភីង តុន នោះ លោកថាលោកអត់ដឹងទេ មែនទេ?

**ឆ៖** លោកសហព្រះរាជអាជ្ញា ខ្ញុំទុកបញ្ហានេះនិយាយនៅពេលណាដែលយើងពិភាក្សាគ្នា ពីរឿងលោកគ្រូ ភីង តុន ជាមួយនិង ដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាបុត្រីច្បងរបស់លោកគ្រូ នេះគាត់នៅទីនេះទេ ។

**ស៖** តំណាងអយ្យការគ្រាន់តែចង់សួរបញ្ជាក់ថា លោកដឹង ឬមិនដឹងទេ? គ្រាន់តែថាពីពេលវេលារបស់លោក ។

**ឆ៖** បាទៗ ខ្ញុំសរសេរនៅក្នុងកំណត់ហេតុ ខ្ញុំដែលរាយាការណ៍ជូនអ្នកស្រី ភីង ហ្គោតសិនធីរីរួចហើយ វាជាបញ្ហាមួយដែលខ្ញុំមិនដឹងមែន គ្រូរបស់ខ្ញុំៗ ដែលខ្ញុំគោរព ។ ខ្ញុំពិតជាមិនដឹងមែន ហើយយើងចាំជជែកគ្នាល្អិតដល់ពេលនោះ ។

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញា ព្យាយាមក្នុងការរកមធ្យោបាយដើម្បីតាំងសំណួរឲ្យចំអង្គហេតុដែលដាក់មកធ្វើសវនាការ ពីព្រោះអង្គហេតុដែលយើងធ្វើសវនាការនេះ អង្គហេតុពាក់ព័ន្ធជាមួយនឹងការបង្កើតនៃមន្ទីរសន្តិសុខសន្តិបាលស-២១ ហើយនិងអាចពាក់ព័ន្ធជាមួយនិងតាខ្មៅ ។ បញ្ហាតាខ្មៅនេះ ដោយសារយើងមិនកំហិតដោយសារយើងអត់បានធ្វើសវនាការទៀតទេ អំពីប្រតិបត្តិការដោយសារតាខ្មៅនេះជាមូលហេតុដែលនាំឲ្យការកើតមុន ហើយជាមូលហេតុគួបផ្សំក្នុងការនាំឲ្យកកើតមន្ទីរសន្តិសុខស-២១ដែរ ។ ដោយសារតាខ្មៅហ្នឹងវាជាកេរដំណែលរបស់៧០៣ ។

[១១:២៩:00]

អង្គភាព ៧០៣ នេះបានមានគុកនៅតាខ្មៅស្រេច ហើយដល់ពេលបង្កើត ស-២១ ក៏បានបញ្ចូលជាបណ្ដើរៗពីតាខ្មៅមកក្នុងមន្ទីរស-២១ ។ អ៊ីចឹងហើយបានជាយើងធ្វើការអង្គហេតុនៃការពិភាក្សាដេញដោលនេះ ជាប់នឹងការបង្កើតមន្ទីរសន្តិសុខស-២១ ទៅនឹងគុកតាខ្មៅនោះ ។ អ៊ីចឹងកាលណា កាលបើយើងមានការធ្វេសប្រហែសអាចចូលជ្រៅទៅអង្គហេតុផ្សេងទៀត ដូចជា អង្គហេតុអនុវត្តគោលនយោ

បាយបក្សជាដើម ឬក៏ជម្លោះប្រដាប់អាវុធ ឬក៏សំខាន់គឺអាចភ័ន្តច្រឡំទៅកិច្ចប្រតិបត្តិការ ព្រោះនៅកិច្ចប្រតិបត្តិការជាអង្គហេតុធំ ហើយមានលក្ខណៈស្មុគស្មាញ ហើយក៏យើងចង់ឲ្យមានការច្បាស់លាស់នៅអង្គហេតុប្រតិបត្តិការដែរ ដែលមានតាំងពីការចាប់ខ្លួន ការចាប់បញ្ជូន ការឃុំឃាំង ការសួរចម្លើយធ្វើទារុណកម្ម និងការកម្ទេច ។ អ៊ីចឹង គឺអង្គហេតុនេះ ជាចម្បងគឺនៅអង្គហេតុដែលប្រតិបត្តិការស-២១ ។

[១១:៣០:០៦]

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** អរគុណលោកប្រធានអង្គជំនុំជម្រះ ដែលបានរំឭកដល់យើងខ្ញុំ ។ សំណួរបន្តទៅទៀត វាពាក់ព័ន្ធនឹងការបណ្តុះបណ្តាលដែលអង្គជំនុំជម្រះហ្នឹងបានសួរលោក ហើយលោកក៏បានឆ្លើយជាបន្តបន្ទាប់រួចមកហើយដែរ ។ តំណាងអយ្យការគ្រាន់តែចង់សុំសួរបញ្ជាក់ពីចរិតនៃការបណ្តុះបណ្តាលហ្នឹង តើឯកសារដែលយកមកបណ្តុះបណ្តាលនុ៎ង វាឯកសារអ្វីខ្លះ? និយាយពីឯកសារ តើឯកសារនោះ វាមានចរិត និយាយអំពីបញ្ហាពីសន្តិសុខហ្នឹងដែរ ឬទេ? ទីមួយ ។ ទីពីរ តើអ្នកដែលបណ្តុះបណ្តាលលោកហ្នឹង តើអ្នកណាដែលមកបណ្តុះបណ្តាលលោកក្នុងរយៈពេលដែលលោកអញ្ជើញមកពីក្នុងទីក្រុងភ្នំពេញដើម្បីបណ្តុះបណ្តាលនៅក្នុងថ្ងៃខែឆ្នាំដូចអង្គជំនុំជម្រះហ្នឹងបានសួរ ហើយលោកបានឆ្លើយពីមុនរួចមកហើយនុ៎ង ។

**ឆ៖** សូមជម្រាបលោកព្រះរាជអាជ្ញាជាទីគោរពដូចតទៅ អំពីការបណ្តុះបណ្តាល ។ ខ្ញុំទទួលការបណ្តុះបណ្តាលពីមេខ្ញុំរាល់ឆ្នាំតាមការវគ្គរៀនសូត្រនយោបាយ ។ ក្នុងមួយលើកៗឯកសារមានចែកជាបីប្រភេទ គឺឯកសារនយោបាយ ឯកសារសតិអារម្មណ៍ និងឯកសារចាត់តាំង ។ ហើយក្រោយពីឧទ្ទេសនាមហើយ ដូចខ្ញុំបានរាយការណ៍ជម្រាបលោកចៅក្រម ឡាវ៉ែន៍ មិញអ៊ីចឹង ត្រូវមានការពិភាក្សាគ្នាតាមក្រុមដើម្បីយល់ជម្រៅឯកសារនីមួយៗ រួចហើយបានយើងខ្ញុំធ្វើប្រវត្តិរូបបដិវត្តន៍ និងជីវទស្សនបដិវត្តន៍បង្ហាញគ្នាទៅវិញទៅមកក្នុងក្រុមរៀនសូត្រ ។ មួយឆ្នាំយើងខ្ញុំធ្វើម្តង ។ ចេញពីនោះមកមានកម្មាភិបាលមួយចំនួនយើងខ្ញុំត្រូវបញ្ជូនទៅរៀននៅសេនាធិការ ។ មិនមែនទៅរៀនជាមួយនឹងលោកគ្រូ សុន សេន ទេ ភាគច្រើនទៅរៀនជាមួយ មិត្តសោម ឈ្មោះដើម ពេជ្រ ឆន ជំនួយការសេនាធិការ ។ ឯចំណែកយើងខ្ញុំបើកវគ្គបង្រៀនកម្មាភិបាលមួយចំនួនដែលមិនបានបញ្ជូនទៅរៀននៅឯសេនាធិការ ដូច្នេះ ជាប់ជាប្រចាំរាល់ឆ្នាំ គេហៅថា "វគ្គសិក្សានយោបាយប្រចាំឆ្នាំ" ។ ក្រៅពីនោះ ខ្ញុំបានបើកវគ្គរៀនសូត្ររបៀបសួរចម្លើយនៅពេលដែលចាប់ផ្តើមបើកមន្ទីរស-២១ ភ្លាម ឲ្យពួកកម្មាភិបាលដែលជា

អតីតយុទ្ធជននិងកម្មាភិបាលកងពល-៧០៣ ខាងរបៀបសួរចម្លើយ ។ ឯកសារនេះ ខ្ញុំឃើញមិត្តម្នាក់គាត់កត់ ចំណាំងជើងរបស់គាត់ គាត់សរសេរថា "បញ្ជីស្ថិតិសន្តិបាលស-២១ នយោបាយសតិអារម្មណ៍ចាត់តាំង" តែតាមពិត ជាឯកសារដែលខ្ញុំឧទ្ទេសនាមអំពីរបៀបសួរចម្លើយនិងនយោបាយក្នុងការសួរចម្លើយ ។ សៀវភៅនោះមានចងក្រង គេចងក្រងស្អាតរបស់គេមិត្តនុ៎ង តែឥឡូវគាត់ស្លាប់បាត់ទៅហើយ ។ បើតាមខ្ញុំស្មានប្រហែលជាសៀវភៅរបស់មិត្ត អ៊ូ ផល្លី របស់មន្ទីរស-២១ ។ ដល់ក្រោយមកខ្ញុំបង្រៀនវគ្គខ្លីៗអ្នកដែលកត់ទាន់គឺបង ម៉ម ណៃ ។ ឯកសារបង ម៉ម ណៃ ដែលសហព្រះរាជអាជ្ញា (សូមទោស) សហចៅក្រមស៊ើបអង្កេតលោកប្រគល់ឲ្យខ្ញុំនៅខាងចុងសុទ្ធតែជាវគ្គ ដែលខ្ញុំបង្រៀនបណ្តុះបណ្តាលកម្មាភិបាលសួរចម្លើយអំពីរបៀបសួរចម្លើយ ។ ខ្ញុំបង្រៀននេះ ក៏អាស្រ័យដោយខ្ញុំបានទៅជួបមេជាញឹកញាប់ មេណែនាំមក ខ្ញុំយកមកបង្រៀន ។

សរុបមក និយាយមួយម៉ាត់ឯកសារនេះ វាចាក់ជម្រៅទៅខាងទស្សនៈវណ្ណៈនិងការតស៊ូវណ្ណៈហើយនិងផ្តាច់ការវណ្ណៈអធន ។ បើយើងមើលជាន័យខ្លឹមសារកុម្មុយនីស្តវាស្រួចស្រាវ ក៏ប៉ុន្តែបើយើងមើលមកខ្លឹមសារបច្ចុប្បន្ននេះ គឺជាខ្លឹមសារឧក្រិដ្ឋ មេរៀនឧក្រិដ្ឋដែលយើងបញ្ចេះគេឲ្យធ្វើអីចេះឲ្យធ្វើអីចុះទៅរកទិសឧក្រិដ្ឋ ។ ខ្ញុំសូមបញ្ចប់ ។

[១១:៣៥:០៥]

**ស៖** អរគុណលោក កាំង ហ្គេកអ៊ាវ ។ ដូចលោកបានជ្រាបស្រាប់ហើយថា មន្ទីរស-២១ វាមានអាគារ A, B, C, D ដូចដែលលោកបានចង្អុលបង្ហាញនៅក្នុង*ស្លាយ*កាលពីថ្ងៃបន្តបន្ទាប់មុន ។ នៅក្នុងនោះ វាមានអាគារដូចជា អាគារ "B" និង "C" វាមានសាងសង់នូវបន្ទប់តូចៗ ។ សំណួរសួរថាតើបន្ទប់តូចៗហ្នឹងត្រូវបានសាងសាង់ឡើងនៅពេលណា? ហើយក្រុមខាងណាដែលបានមកសង់បន្ទប់តូចៗសម្រាប់ដាក់មនុស្ស អ្នកទោសដែលឃុំឃាំងនុ៎ង? ហើយអ្នកណាអ្នកអនុម័តឲ្យធ្វើបន្ទប់តូចៗដើម្បីដាក់នុ៎ង? ពីព្រោះអីលោកធ្លាប់បានឆ្លើយហើយថា នៅក្នុងមន្ទីរស-២១ វាមានបន្ទប់ធំដែលដាក់អ្នកទោសជារួម និងដោយឡែក ។

**ឆ៖** សូមគោរពរាយការណ៍ជូនលោកព្រះរាជអាជ្ញាដូចតទៅ៖ នៅពេលដែលមេសម្រេចឲ្យខ្ញុំយកវិទ្យាល័យពញាយ៉ាតធ្វើជាកន្លែងឃុំឃាំង ។ ខ្ញុំមានការ-- អើ! យើងអង្គាល់នោះ ហៅថា "ដោរតិចទៅចុះ"ក៏បញ្ជាឲ្យ មិត្តហ៊ី ធ្វើអាបន្ទប់តូចៗហ្នឹង ដូចលោកព្រះរាជអាជ្ញាជ្រាបហើយ មិត្តហ៊ី ធ្លាប់ជាប់គុក ធ្លាប់ស្គាល់ប៉េហ្សី ធ្លាប់ស្គាល់*សែលុលអាំងឌីវីឌុយអែល* នៅក្នុង ប៉េហ្សី ដូច្នេះយើងខ្ញុំមិនបាច់

និយាយច្រើនទេ ថា មិត្តហ៊ា ធ្វើ*សែលុល* ហើយ ។ បាទ! បង ។ គេក៏ធ្វើទៅ ។ ខ្ញុំជាអ្នកសម្រេចហើយបញ្ជាទៅឲ្យ មិត្តហ៊ា ធ្វើ ។ ហើយសូមបញ្ជាក់ករណីនេះ ខ្ញុំអត់បានរាយការណ៍ជូនមេទេ ។ វាជាអំណាចឯករាជ្យរបស់ខ្ញុំក្នុងការចាត់ចែងកិច្ចការ ។ នេះសូមបញ្ជាក់ប៉ុណ្ណោះ ។

[១១:៣៧:៣២]

**ស៖** លោកធ្លាប់បានបញ្ជាក់ជាច្រើនដងហើយថា ដូចជូនអង្គជំនុំជម្រះនូវការសួរចម្លើយ នៅពេលដែលបង្កើតមន្ទីរស-២១ ហ្នឹងមានការបង្កើតក្រុមសួរចម្លើយ មានក្រុមស្លូត ក្រុមកាច ក្រុមអង្កៀម និងស្ត្រីជាដើម ។ តើលោកអាចប្រាប់បានទេថា តើរចនាសម្ព័ន្ធនិងរូបមន្តនៅក្នុងការសួរចម្លើយហ្នឹងមានៗអ្វីខ្លះដែលក្នុងការសួរចម្លើយអ្នកទោសនីមួយៗនុ៎ង? ក្នុងនោះដែរ លោកក៏បានធ្លាប់ឆ្លើយហើយនៅក្នុងកំណត់ហេតុដែលមានលេខ D20 ដែលលោកបានរៀបរាប់យ៉ាងក្បោះក្បាយនៅក្នុង-- នៅថៅក្រុមស៊ើបអង្កេត ។ តើនៅពេលនេះលោកអាចបញ្ជាក់បន្ថែមជូនអង្គជំនុំជម្រះពីរូបមន្តនៅក្នុងការសួរចម្លើយអ្នកទោសដែល នៅក្នុងសម័យកាលដែលលោកបានឆ្លើយនៅពេលនោះបានទេ?

**ឆ៖** ខ្ញុំ--

**ប្រធានអង្គជំនុំ៖**

លោក ហ្វ្រង់ស្វ័រ រូ ចង់និយាយអីនុ៎ង? អញ្ជើញ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន ខ្ញុំជឿថាសហព្រះរាជអាជ្ញាហាក់ដូចជាសួរលឿនពេក ដោយសារតែនៅពេលនេះអង្គជំនុំជម្រះសាលាដំបូង គឺមិនទាន់បានពិនិត្យពិស្តារទៅលើបញ្ហាទារុណកម្ម ។ ដូច្នេះហើយ យើងមើលតែលើរចនាសម្ព័ន្ធអង្គការលេខតែប៉ុណ្ណោះ ។ ហើយសហព្រះរាជអាជ្ញាបានចោទសំណួរដែលមិនគួរធ្វើការដេញដោលនៅក្នុងកម្មវត្ថុអង្គហេតុថ្ងៃនេះទេ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ការកត់សម្គាល់របស់លោកមេធាវីការពារក្តីជាការត្រឹមត្រូវ ។ អ៊ីចឹង សំណួរនេះ គឺចុងចោទមិនបាច់ឆ្លើយទេ ។ ហើយរំឭកលោកព្រះរាជអាជ្ញា គឺសូមបន្តសំណួរផ្សេងទៀត សូមរំឭកឡើងវិញថាសំណួរពាក់ព័ន្ធនឹងកិច្ចការទាំងឡាយនៃអង្គហេតុដែលទាក់ទិន្នជាមួយនឹងការបង្កើតមន្ទីរសន្តិសុខស-២១ ហើយនិងពាក់ព័ន្ធជាមួយនឹងគុកនៅពេទ្យឆ្កួតតាខ្មៅតែប៉ុណ្ណោះ ។ អ៊ីចឹង ឲ្យមានការប្រយ័ត្នប្រយែងហើយនិងបញ្ហាហ្នឹង ខ្ញុំបានរំឭកតាំងពីព្រឹកម្តងរួចហើយ ហើយមិញរំឭកទៀត ។ អ៊ីចឹង បើសិនជាមិន

ធ្វើការប្រាកចាកអំពីវិធានដែលយើងបានកំណត់នេះ នោះយើងនឹងមិនឲ្យសួរទេ នៅអង្គហេតុបន្តបន្ទាប់ទៀត ដែលយើងនឹងធ្វើសវនាការនៅពេលក្រោយ ។

[១១:៤០:៤១]

**សួរដោយ លោក តាន់ សេណារ៉ុង៖**

អរគុណៗដែលអង្គជំនុំជម្រះ ដែលបានរំឭកបន្ថែមទៀត ប៉ុន្តែតំណាងអយ្យការគ្រាន់តែចង់សួរបង្ហាញពីការបង្កើតនោះ ។ វាធម្មតាវាមានបង្កើតជាផ្នែកនៃការសួរចម្លើយ បើអ៊ីចឹងចង់ភ្ជាប់សាច់រឿងនុ៎ង ។ នៅក្នុងការបង្កើតការសួរចម្លើយហ្នឹងទេ ដែលមានក្រុមនីមួយៗហ្នឹង មិនមែនចង់សួរលម្អិតពីការធ្វើទារុណកម្មទេ ។

**ស៖** សំណួរបន្តទៅទៀត ពីបញ្ហានៅមន្ទីរស-២១ ហ្នឹងវាមានក្រុមអ្នកថតរូបដូចលោកធ្លាប់បានឆ្លើយបញ្ជាក់អង្គជំនុំជម្រះហ្នឹង ។ ថាតើ-- ក្នុងនៅដែរ លោកបានបញ្ជាក់ថាការថតរូបហ្នឹង វាមានសុទ្ធជាមនុស្សដែលសល់ពីក្រុម៧០៣ ហើយសម្ភារៈទាំងអស់នោះ គឺជាជយភណ្ឌនៅសម័យលន់នល់ ដែលបានបន្សល់ទុកហើយយកមកប្រើប្រាស់បន្តបន្ទាប់មកទៀត ។ សំណួរគ្រាន់តែចង់សួរ តើបន្តបន្ទាប់មកទៀតក្រុមអ្នកថតរូបនុ៎ង ដែលមានការយកទៅហ្វឹកហ្វឺនទៅហាត់បន្ថែមនៅក្នុងការយកមកប្រើប្រាស់--ដែលក្នុងការបង្កើតមន្ទីរស-២១ ហ្នឹងថែមទៀតទេ?

**ឆ៖** លោកព្រះរាជអាជ្ញាជាទីគោរព! ខ្ញុំសូមរាយការណ៍ជូនដូចតទៅ ។ រឿងម៉ាស៊ីនថតនេះហាងម៉ាស៊ីនថតរូបនៅផ្សារថ្មីណាស់ ដូច្នេះកងពល៧០៣ យកបានមួយពីរអី គេចែកទៅ ស-២១ តាមរយៈ ណាត ក៏ច្រើនដែរ ទាំងហ្វីលទាំងប្រដាប់ថតទាំងអីទាំងអស់ហ្នឹង ។ ឯចំណែកជាងថតរបស់ ស-២១ រៀនអំពីជាងថតរបស់៧០៣ មិត្តស្រ៊ាង ទៅរៀនពី មិត្តយេ ។ មិត្តយេ ជាងថតរបស់៧០៣ ។ ហើយក្រោយមកក៏បង្រៀនគ្នាគេ នៅក្នុងចំណោមគ្នាទេប៉ុននុ៎ងទេ គ្មានបានទៅបង្រៀនឯណាទៀតទេ ។ នេះសូមបញ្ជាក់ជូនត្រឹមប៉ុណ្ណេះដោយខ្លី ។

**លោក តាន់ សេណារ៉ុង៖**

សូមអរគុណលោក កាំង ហ្គេកអ៊ាវ ហើយខ្ញុំសូមបន្តសំណួរទៅជូនសហការីរបស់ខ្ញុំដែល នឹងបន្តនូវសំណួរជាច្រើនទៅលើលោក ។ អរគុណ លោកប្រធានអង្គជំនុំជម្រះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ ។

[១១:៤៣:២៩]

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណ លោកប្រធាន ។ ខ្ញុំនឹងព្យាយាមសួរលោក កាំង ហ្កេកអ៊ាវ ខ្ញុំនឹងសួរនូវសំណួរខ្លីៗមួយចំនួន ។ ហើយខ្ញុំសង្ឃឹមថា ជាជំនួយដល់អង្គសាលសវនាការហ្នឹង ប្រសិនបើលោកស្តាប់សំណួររបស់ខ្ញុំឲ្យបានច្បាស់លាស់ ហើយនិងឆ្លើយឲ្យបានខ្លីៗចំពោះសំណួរអស់ទាំងនោះ ។ សូមអរគុណ ។

**ស៖** ជាដំបូង ខ្ញុំសូមសួរលោកនូវសំណួរមួយទាក់ទងទៅសំណើរបស់លោកកាលពីខែឧសភាឆ្នាំ៧៥ដើម្បីឲ្យខ្លួនលោកចេញពីមន្ទីរសន្តិសុខ ហើយទៅខាងផ្នែកឧស្សាហកម្មវិញ ។ លោកបានជម្រាបប្រាប់យើងថា លោកបានធ្វើសំណើហ្នឹងទៅ ចេង អន ដែលជាលេខាតំបន់១៥ ។ តើនេះជាចំណុចត្រឹមត្រូវទេ?

**ឆ៖** សូមគោរពលោកព្រះរាជអាជ្ញា ។ ខ្ញុំសូមបញ្ជាក់ថា ការលើកឡើងរបស់លោកព្រះរាជអាជ្ញាត្រឹមត្រូវទាំងអស់ ។ រឿងពិតកាលណោះ ខ្ញុំពិតជាចង់រត់ចោលការងារនគរបាលនេះមួយលើកទៀត ។ លើកទីមួយខ្ញុំបានរាយការណ៍ហើយ ខ្ញុំចង់រត់ចោលការងារនគរបាលនេះនៅពេលឆ្នាំ១៩៧៣ ដែលពួកអ្នកទោសគេបះបោរ ឆក់កាំភ្លើងបានម្តងហើយ ដោយយកលេសទាមទារឲ្យបង វន គឺ វន វ៉េត ដាក់ទោសទណ្ឌខ្ញុំនឹងអាលខ្ញុំបានរួចចេញ តែគាត់មិនព្រមដាក់ទោស ។ ដល់ក្រោយនេះ ខែមេសា ថ្ងៃ៣០ ខ្ញុំបញ្ជូនអ្នកដែលនៅសល់ទៅមន្ទីរនគរបាលតំបន់-៣២ តាមបញ្ជា ។ ខ្ញុំទំនេរ ខ្ញុំមករង់ចាំភារកិច្ច ជួបបង ចេង អន គាត់ទៅប្រមូលកម្មករពីជនបទ យកចូលក្រុងភ្នំពេញវិញ ។ ពេលហ្នឹងខ្ញុំចង់ណាស់ ចង់គេចឲ្យផុតពីអាមន្ទីរនគរបាលនេះ ចង់ទៅនៅ ខាងឧស្សាហកម្មជាមួយបង ចេង អន ។ នេះគឺការពិតខ្ញុំសុំមែន ក៏ប៉ុន្តែខាងលើមិនព្រម ។ សូមបញ្ជាក់ថា នៅថ្ងៃដែលឧទ្ទេសនាមការកកើតមន្ទីរស-២១ នេះ សុន សេន និយាយមួយមាត់របៀបជាលក្ខណៈល្បួងចិត្តខ្ញុំ ។ អើ! មិត្តក៏នៅខាងសន្តិបាលតទៅទៀតទៅ ខ្ញុំក៏នៅខាងយោធាតទៅទៀតទៅ ។ ចប់ ។ មេនិយាយប៉ុណ្ណឹងមកយើងប៉ានតវ៉ា សម័យកុម្មុយនីស្តពិបាកណាស់ ។ ដូច្នេះសរុបមកវិញ ខ្ញុំសូម អរគុណលោកព្រះរាជអាជ្ញាដែលលើកយករឿងនេះមកសួរខ្ញុំ។ ខ្ញុំសូមបញ្ជាក់ថា ចិត្តថ្លើមខ្ញុំគឺពិតជាចង់រត់ ទៅខាងកម្មករមែន ទៅឧស្សាហកម្មមែន ។ សូមចប់ ។

**សះ** អ៊ីចឹងខ្ញុំចង់យល់ឲ្យបានច្បាស់ថា អ្វីដែលលោកបាននិយាយហ្នឹង អ្វីដែលលោកនិយាយប្រាប់ ចេង អន នោះគឺថា លោក ចេង អន ដែលជាប្រធានរបស់លោកហ្នឹង ។ តើពេលហ្នឹងលោកបាននិយាយថា ខ្ញុំមិនចង់ធ្វើការងារសន្តិសុខទៀតទេ ខ្ញុំអត់ចូលចិត្តទេ ឬមួយក៏លោកនិយាយផ្សេងពីនេះ? ឬមួយក៏លោកនិយាយថាខ្ញុំមិនចង់ចេញបញ្ជាឲ្យសម្លាប់មនុស្សទេ តើលោកអាចប្រាប់យើងបានទេ អ្វីទៅដែលជាអ្វីដែលលោកបាននិយាយ ឬក៏ស្នើទៅលោក ចេង អន នោះ?

[១៤:៤៧:២៦]

**ឆះ** លោកព្រះរាជអាជ្ញាជាទីគោរព! ខ្មែរមានពាក្យសុភាសិតមួយមាត់ គេថា "ចាំបាច់តែគេបកក្តាមបង្ហាញអាចម៍ហ្អេស?" ខ្ញុំនិយាយពាក្យខ្មែរនេះទៅប្រហែលជាលោកព្រះរាជអាជ្ញាយល់ ។ ខ្ញុំមិនបានជម្រាបបង ចេង អន ថាខ្ញុំស្អប់ការងារសន្តិសុខទេ ។ ខ្ញុំថាខ្ញុំចង់ទៅធ្វើការជាមួយបងខាងឧស្សាហកម្មណាស់បងអើយបង ។ ខ្ញុំហើយនិង ចេង អន មានមនោសញ្ចេតនាគ្នាពិតប្រាកដ ។ ខ្ញុំស្រលាញ់គាត់ជឿទុកចិត្តគាត់ គាត់ក៏ស្រឡាញ់ខ្ញុំជឿទុកចិត្តខ្ញុំដែរ ។ ប៉ុន្តែអើ! ជឿទុកចិត្តដូចខ្ញុំបានជម្រាប លោកចៅក្រមឡាវែន៍ ម្សិលមិញ គេស្រលាញ់ខ្ញុំជឿទុកចិត្តខ្ញុំ ក្នុងឋានៈខ្ញុំជា*ប៉ែកហ្សេ* មួយដ៏ស្មោះត្រង់ ។ សរុបមកវិញ ខ្ញុំសូមជម្រាបសហព្រះរាជអាជ្ញាថា របៀបនិយាយជាមួយនឹងខាងលើយើងខ្ញុំអត់ ដែលបាន "បកក្តាមបង្ហាញអាចម៍" ទេ ។ មិនលាតត្រដាងទាំងអស់ចិត្តយើងដែលស្អប់មន្ទីរនគរបាលទេជាមួយ បងវន ក៏ដោយ ខ្ញុំមិនដែលបាននិយាយថាបងអើយខ្ញុំស្អប់ការងារនគរបាលណាស់ទេ ។ ខ្ញុំថាបងអើយខ្ញុំធ្វើខុស បងដាក់ទោសខ្ញុំមក ហើយដេញខ្ញុំចេញពីនគរបាលទៅ ខ្ញុំធ្វើការងារនេះអត់កើតទេ។ យើងនិយាយអ៊ីចឹង ។ នេះខ្ញុំសូមបញ្ជាក់ជូនលោកព្រះរាជអាជ្ញាដោយស្មោះត្រង់ពេលនេះប៉ុណ្ណោះ ។

[១១:៤៨:៥២]

**សះ** សូមអរគុណ ។ អ៊ីចឹងបើតាមខ្ញុំយល់ហ្នឹង គឺដូចអ្វីដែលលោកនិយាយជាមួយគាត់ដូចជាសំណើឲ្យគាត់ហ្នឹងបញ្ជូនលោកទៅខាងឧស្សាហកម្មវិញ ហើយវាមិនមែនជាសំណើដើម្បីឲ្យលោកហ្នឹងបានចេញពីការងារសន្តិសុខទេ ដែលថាលោកមិនចូលចិត្តនោះ ថាតើនេះជាការយល់ដឹងត្រឹមត្រូវរបស់ខ្ញុំទេ?

**ឆះ** សូមគោរពលោកព្រះរាជអាជ្ញា សំណួរលោក ខ្ញុំយល់ជម្រៅមិនទាន់បានទេ ។ ឥឡូវខ្ញុំនិយាយពីជម្រៅចិត្តថ្មើមខ្ញុំនៅពេលនោះ ។ ឧស្សាហកម្មរបស់បង ចេង អន នៅក្រោមការគ្រប់គ្រងរបស់បងវន គឺ វន វេត មួយខ្សែទៅ ។ ឯចំណែក ការងារសន្តិសុខនេះ កាលនោះមិនទាន់ឃើញរូបរាង

ទេ ក៏ប៉ុន្តែវាជាការងាររបស់លោកគ្រូ សុន សេន មួយផ្នែកទៅទៀត ។ ខ្ញុំមុនថ្ងៃ១៧ មេសា ជាពិសេសមុនថ្ងៃ៣០ មេសា ខ្ញុំនៅក្រោមការគ្រប់គ្រងរបស់លោកគ្រូ សុន សេន ក៏ពិតមែន ក៏ប៉ុន្តែបង ចេង អន ក៏មានតួនាទីជាលេខាសាខារបស់ខ្ញុំៗ ។ ដូច្នេះ ខ្ញុំសុំគាត់ទៅនៅជាមួយនឹងគាត់ គឺខ្ញុំសុំបង ចេង អន ទៅនៅជាមួយនឹងគាត់ វាជាសំណូមពរមួយរបស់ខ្ញុំ មិនចាំទៅវ៉ៃថា អូ! ខ្ញុំស្អប់ការងារនគរបាលទេ គឺខ្ញុំសុំមកនៅជាមួយបង ។ យើងជ្រើសផ្លូវដើរមួយថ្មី ពេលដែលក្រសួងទើបនឹងកើតថ្មី ។ នេះសូមបញ្ជាក់ជូនលោកព្រះរាជអាជ្ញាប៉ុណ្ណោះ ។

**ស៖** អ្វីដែលលោកប្រាប់យើងនៅក្នុងសាលសវនាការហ្នឹង គឺថាតាមពិត គឺថាលោកហ្នឹងអល់អែកខ្លាំងណាស់ក្នុងការបំពេញភារកិច្ចរបស់លោកជាកម្មាភិបាលសន្តិសុខនោះ ។ ហើយសំណួររបស់ខ្ញុំចំពោះលោកគឺថា តើមេផ្ទាល់របស់លោកដែលជាលោក សុន សេន នោះបានដឹងអំពីភាពអល់អែករបស់លោកក្នុងការធ្វើការងារសន្តិសុខនេះដែរឬទេ?

**ឆ៖** ខ្ញុំជម្រាបលោកព្រះរាជអាជ្ញា ការងារខ្លះមេខ្ញុំក្តាប់បាន ។ សូមបញ្ជាក់ថាមេខ្ញុំ *លីសង់ស្យេ* ខាង*ស៊ីកូប៉េដាហ្គូ* ខាងចិត្តសាស្ត្រគរុកោសល្យ ។ ពូកែណាស់ ចូលចិត្តស្ទង់មើលទឹកចិត្តមនុស្ស ដូច្នេះរឿងអីក៏ដោយខ្ញុំមិនសូវហ៊ានលាក់ហ្នឹងគាត់ទេ ខ្លាចអាត្រង់ហ្នឹងមួយ ។ ប៉ុន្តែខ្ញុំជឿថា មេខ្ញុំដឹងចំណុចខ្សោយខ្ញុំច្រើនដែរ ។ ដូចចំណុចខ្សោយខ្ញុំមិនហ៊ានសម្លាប់មនុស្ស ចំណុចខ្សោយខ្ញុំមិនហ៊ានធ្វើទារុណកម្មមនុស្ស ក៏ប៉ុន្តែ គេក៏ដឹងថាចំណុចខ្លាំងខ្ញុំដែរ គឺត្រង់នឹងគេគ្មានលក្ខខណ្ឌទេ ។ ដូច្នេះ រឿងរាយការណ៍ខ្ញុំមិនហ៊ានរាយការណ៍ទេ ដូចខ្ញុំជម្រាបលោកព្រះរាជអាជ្ញារួចហើយ "មិនបកក្តាមបង្ហាញអាចម៍ទេ" ឬក៏ខ្មែរយើង គេនិយាយថា "មិនហែកពោះឲ្យក្អែកចឹក" ។

[១១:៥២:៥៨]

**ស៖** អ៊ីចឹង ខ្ញុំសូមនិយាយដោយវិធីផ្សេងមួយទៀត ដែលជាលើកចុងក្រោយទាក់ទងទៅនឹងចំណុចនេះ ។ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ម្តងទៀតទេថា លោកមិនដែលបានប្រាប់នរណាគេផ្ទាល់ទេថា លោកស្អប់ខ្ពើមការងារសន្តិសុខណាស់ ហើយដែលថាលោកអល់អែកក្នុងការធ្វើការងារនេះ តើនេះជាការយល់ត្រឹមត្រូវរបស់ខ្ញុំទេលោក?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា សូម្បីតែ មិត្តប៊ុន ហើយនិងបង ម៉ម ណៃ ហ្នឹង ក៏ខ្ញុំមិនដែលហ៊ានជម្រាបដែរ ប្រពន្ធខ្ញុំកាន់តែណាស់ទៀត ។ រឿងពីរដាច់ដោយឡែកពីគ្នា ការងារផ្សេងរបស់ខ្ញុំ ការងារគេ គេផ្សេង ។

**ស៖** អ៊ីចឹង គឺថា យើងបង្កើតនូវចំណុចមួយដែលថាលោកស្អប់ខ្ពើមការងាររបស់លោក ប៉ុន្តែលោកមិនបានបញ្ជាក់ឲ្យបានច្បាស់ ឬក៏ប្រាប់នរណាគេមួយថាលោកស្អប់ខ្ពើមការងាររបស់លោកទេ ។ អ៊ីចឹង សំណួរបន្តរបស់ខ្ញុំគឺថា តើលោកមានការចាប់អារម្មណ៍អ្វីទេ ទាក់ទងទៅនឹងការងារសន្តិសុខនោះ ឬថាលោកចង់ចាប់អារម្មណ៍យ៉ាងខ្លាំងបំផុតទៅលើការងារសន្តិសុខហ្នឹងដែរ ឬក៏អត់ទេ?

**ឆ៖** សំណួរនេះទូលាយណាស់ ខ្ញុំសូមសាកល្បងជម្រាបតាមចំណុចដូចតទៅ ។ ការងារសន្តិ-សុខនេះ ខ្ញុំដឹងហើយថា វាប៉ះពាល់ដោយអយុត្តិធម៌ទៅលើមនុស្សក្នុងការចាប់មនុស្ស ។ ខ្ញុំបានជម្រាបជាហូរហែមកតាមពិសោធន៍ ។ សំណួរសួរចម្លើយ បើសិនជាសួរឲ្យហ្មត់ចត់គិតគូរថ្លឹងថ្លែងស្រួលបួលសាច់រឿងដែលគេរាយការណ៍ ពិតយ៉ាងច្រើនហាសិបភាគរយ ។ យ៉ាងច្រើនបំផុតហើយហាសិបភាគរយ ។ ខ្ញុំនិយាយនេះ គឺខ្ញុំនិយាយតាមពិសោធន៍ដែលខ្ញុំខិតខំសួរឈ្មោះ ង៉ែត សំបុន ហៅ រំពេ ប្រហែលជាមួយខែជាង ក៏ប៉ុន្តែរឿងដែលមិនពិតក៏មានច្រើនដែរ ។ ឧទាហរណ៍ ង៉ែត សំបុន ហៅ រំពេ ឆ្លើយប្រាប់ខ្ញុំថាមេរបស់គាត់គឺ បាញ់ សាន ។ ខ្ញុំមិនជឿ ។ ដឹងថា មិត្តរំពេ បានទៅរៀន ក៏ប៉ុន្តែ មេមិនមែនបាញ់ សាន គេតំណាងរាស្ត្រ ក៏ប៉ុន្តែនិយាយអំពីឈ្មោះវិញ ខុសស្រឡះទាំងអស់ ឡាំ សៀក, មិញ ឡាំប៉េងសៀក អីហ្នឹងអ្នកនិពន្ធឥឡូវនៅរស់ហ្នឹង ។ រួចតាម រំពេ ឆ្លើយសុទ្ធតែបញ្ជូនទៅអមលាំងទៅបង្កប់សម្ងាត់នៅនុ៎ង។ ដូច្នេះសរុបមក ខ្ញុំចាប់អារម្មណ៍ថាចម្លើយមិនត្រឹមត្រូវទេ ខ្ញុំតែងតែរំឭកនិយាយអំពីកុនចិនមួយខ្សែ ជាកុនប្រឆាំងចារកម្មដែលចិនគេរៀបចំឡើងនោះ ដើម្បីឲ្យកម្មាភិបាលសួរចម្លើយគិតគូរពិចារណាឲ្យបានហ្មត់ចត់ ។ ប៉ុន្តែ លទ្ធភាពនៅកម្ពុជាគេមិនគិតគូរទៅរកបច្ចេកទេសវិទ្យាសាស្ត្រខាងប៉ូលិសដើម្បីធ្វើការងារទេ ។ ត្រង់ហ្នឹងដែលយើងត្រូវធ្វើការងារតាមគេបង្គំ ។ ដឹងហើយថា ឆ្លើយទៅវាខុស មនុស្សដែលគេឆ្លើយដាក់នោះពាសណាពាសណីចៀសមិនរួច ។ នេះជារឿងដែលយើងដឹងក៏ប៉ុន្តែចៀសពីធ្វើវាមិនរួច ។ ដល់និយាយៗណាស់ៗទៅ ពួននួន គាត់ថា អ្ហឺ! មិត្តឯងគេ គេចេះធ្វើការរបស់គេដែរណា ។

សរុបមកវិញឯកសារនៅមាន គឺឯកសារថ្ងៃ៩ តុលា ឆ្នាំ១៩៧៥ គឺអង្គប្រជុំអចិន្ត្រៃយ៍នៅថ្ងៃ ៩ តុលា ឆ្នាំ១៩៧៥ ដែលយើងខ្ញុំលើកម្សិលមិញនេះ នៅពេលដែលបង ប៉ុល គឺ ប៉ុល ពត គាត់និយាយអំពីមិត្តមាន ឈ្មោះដើម ចាន់ ចក្រី គាត់ថា កុំទៅជឿអាសន្តិសុខនោះពេកនោះ យើងគិតតាមខ្សែបក្ស ។ គាត់លេងចេញអ៊ីចឹងទៅវិញ ដូច្នេះព្រះរាជអាជ្ញាគង់ឃើញបញ្ហានេះនៅនេះ ។

ដូច្នេះសរុបមក ការងារដែលសន្តិបាលនេះវាពាលដាល ខ្ញុំជឿថាវាពាលដាល ចាប់មនុស្សក្រៅ

ច្បាប់ជាបញ្ហាដែលយើងខ្ញុំចូលមកឱនក្បាលទទួលទោសទណ្ឌនៅចំពោះមុខអង្គជំនុំជម្រះ គឺចាប់មនុស្សក្រៅប្រព័ន្ធច្បាប់ ទាំងខុសទាំងត្រូវ ។

ត្រឡប់ទៅវិញ ស-២១ វាកម្ទេចអចិន្ត្រៃយ៍មជ្ឈិមក៏មាន សមាជិកពេញសិទ្ធិក៏មាន អចិន្ត្រៃយ៍មជ្ឈិម គឺបងវន ។ សមាជិកមជ្ឈិមពេញសិទ្ធិគឺ ជូ ជេត ហៅ ស៊ី, រស់ ញឹម ភូមិភាគពាយ័ព្យអីហ្នឹង យើងខ្ញុំមិនគិតថានេះជាសាគុណរបស់ស-២១ចំពោះជាតិប្រជាជនទេ ។ ខ្ញុំទុកថាជាបញ្ហាពាលស៊ីពាល។ ដូច្នេះ វាមានលក្ខណៈមួយប្លែកអំពីស-២១ ចាប់អ្នកស្លូតត្រង់ដូចយ៉ាងសាស្ត្រាចារ្យ ភីង តុន គ្រូខ្ញុំ ដូចយ៉ាងបង រ័ត្ន គត់ ដុកទ័រពេទ្យ រ័ត្ន គត់ ដូចយ៉ាងឯកឧត្តម ចៅ សេង ខុសគ្នា មានសារជាតិខុសគ្នាៗ ។ ដូច្នេះ ស-២១ ហ្នឹង វាច្របូកច្របល់ ។ សរុបមកវិញ ជាឧបករណ៍ផ្តាច់ការវណ្ណៈអធនរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ខ្ញុំជាឧបករណ៍ផ្តាច់ការរបស់គេ ។ នេះជាទោសទណ្ឌដែលខ្ញុំឱនក្បាលមកទទួលអង្គជំនុំជម្រះ មុខជាតិប្រជាជនកម្ពុជាទាំងមូលនៅថ្ងៃនេះ ។

**ស៖** ខ្ញុំចង់សួរលោកយ៉ាងសាមញ្ញមួយថា តើលោកគិតថាការងារសន្តិសុខហ្នឹងជាការងារដែលលោកចាប់អារម្មណ៍ ឬក៏មិនចាប់អារម្មណ៍? នេះជាសំណួរយ៉ាងសាមញ្ញបំផុត ។

**ឆ៖** សូមជម្រាបលោកព្រះរាជអាជ្ញា ។ ការងារសន្តិសុខនេះខ្ញុំអត់ចាប់អារម្មណ៍ទេ ខ្ញុំចូលធ្វើបដិវត្តន៍ប្រាថ្នាគ្រូៗ ប្រាថ្នាគរុកោសល្យ ខ្ញុំមកនៅភ្នំពេញហ្នឹងចេះតែដើររើសដែរ ឥវ៉ាន់យកទៅទុកនៅនុំង *អង់ស៊ីក្លូប៉េឌីបារាំង* ១១ក្បាលប៉ុនៗណាណី ខ្ញុំប្រមូលយកទៅទុក ។ ប្រដាប់សម្រាប់ពិសោធន៍អារីកមាឌ ក៏ខ្ញុំយកទៅទុករហូតដល់មេខ្ញុំគាត់សើច ។ ដូច្នេះ ការដែលខ្ញុំចាប់អារម្មណ៍មែនទែន គឺគ្រូ ប៉ុន្តែមិនបានទៅគ្រូ វាមកអាចង្រៃយក៏ឯណាឯណេះទៅវិញ ។ សុំជម្រាបប៉ុណ្ណឹង ។

**ស៖** នៅក្នុងខែក្តៅ ឆ្នាំ១៩៧៥ គឺខែមិថុនា និងកក្កដា និងសីហា ឆ្នាំ១៩៧៥ តើលោកបានឮថាបុរសម្នាក់ ដែលមានឈ្មោះ *អាឡិន ដាលីស* ដែរ ឬទេ?

**ឆ៖** ខ្ញុំមិនដែលឮទេ ។ សូមលោកនិយាយពីប្រវត្តិបុរសនុំងបន្តិចមើល ។

**ស៖** គាត់គឺជានាយក អតីតនាយករបស់ *ស៊ីអាយអេ* (CIA) គឺលោក អាឡិន ដាលីស ។

**ឆ៖** យល់ៗៗ ខ្ញុំធ្លាប់អាន *អាឡាំង ឌីឡូស* ។

**ស៖** នោះជាសំណួររបស់ខ្ញុំបន្ទាប់ទៀត ថាលោកដឹងថា គាត់បានសរសេរសៀវភៅជាភាសាអង់គ្លេសមានចំណងជើងថា “ការកម្ទេចភ្នាក់ងារស៊ើបអង្កេតសិល្បៈនៃការសួរចម្លើយ” ។ ហើយគឺគាត់បានសរសេរទៅលើបញ្ហានេះ ដូច្នេះសំណួររបស់ខ្ញុំគឺថា តើលោកធ្លាប់បានអានឯកសារនេះដែរ ឬទេ មុន

ពេលដែលលោកចាប់ផ្តើមបំពេញការងារនៅស-២១?

**ឆ៖** ខ្ញុំសូមជម្រាបលោកព្រះរាជអាជ្ញាដោយត្រង់ថា សៀវភៅ*តិចនិក ឌីវ៉ង់ សែងអាម៉ង់* របស់ *អាឡាំង ដូឡូស* ខ្ញុំប្រមូលបានពីរក្បាល មួយក្បាលខ្ញុំជូនទៅមេខ្ញុំ លោកគ្រូ សុន សេន។ មួយក្បាលខ្ញុំទុក ប៉ុន្តែអត់មានពេលបានអាន ។ ទន្ទឹមនេះ ខ្ញុំក៏រកបានសៀវភៅមួយទៀតដែរ ប៉ុន្តែ មិនដឹងពីផ្ទះអ្នកណាទេដូចជា ពីផ្ទះ វ៉ាន់ ស ក៏មិនដឹង *កាហ្សេបេ* (KGB) ខ្ញុំអត់ទុកទេ តែមួយក្បាលហ្នឹង ខ្ញុំជូនទៅមេខ្ញុំបាត់ទៅ ដូច្នេះ សៀវភៅមាន ប៉ុន្តែខ្ញុំអត់បានអាន ។

**ស៖** ដូច្នេះ លោកប្រមូលសៀវភៅទាំងអស់នោះ មុនពេលដែលលោកចាប់ផ្តើមបំពេញការងារនៅស-២១ សៀវភៅមួយក្នុងចំណោមសៀវភៅទាំងអស់នោះគឺវាទាក់ទងទៅនឹងស៊ីអាយអេ ។ ហើយមួយទៀត គឺទាក់ទងទៅនឹងកាហ្សេបេ ហើយលោកបានប្រាប់ថា លោកមិនបានអានសៀវភៅទាំងពីរនោះហើយ គឺសៀវភៅនោះ គឺមិនមានអ្វីធ្វើឲ្យលោកចាប់អារម្មណ៍ នេះជាអ្វីដែលលោកលើកឡើងឬយ៉ាងម៉េច?

[១២:០៣:៣៨]

**ឆ៖** មែន បើនិយាយពីមិនចាប់អារម្មណ៍ មែន។ អាឡាំង ដូឡូស គាត់សរសេរពីរឿងថា អ្នកយកព័ត៌មាន បើបរាជ័យវិញ មនុស្សស្រែកជេរពាសវាលពាសកាល ហ្នឹងចំណុចមួយ ។ មើលចុះមើលឡើងដូចមិនចាប់អារម្មណ៍ គាត់និយាយពីការណ៍សម្ងាត់ ។ ដល់តែខ្លាំងពេក សូម្បីតែប្រធានាធិបតី *អ៊ីសិនហោវ័រ* ក៏ដើររកទីស្នាក់ការ *"សេអ៊ីអា"* ដំបូងដែល អាឡាំង ដឺឡូស ធ្វើមិនឃើញដែរ ។ ដូចជាមិនមានប្រយោជន៍អីសម្រាប់ខ្ញុំ ខ្ញុំក៏មិនបានអាន ហើយអា *"កាហ្សេបេ"* ហ្នឹងក្រាស់បន្តិចជាង *"តិចនិកដឺវ៉ង់សែងញ៉ើម៉ង់"* របស់ *អាឡាំង ដឺឡូស* ខ្ញុំដល់រាយការណ៍ប្រាប់មេទៅ មេថាផ្ញើមកនេះមក។ ខ្ញុំក៏ជូនទៅ ។ ហើយសំខាន់ការងារនៅនុំង វាមិនអនុញ្ញាតឲ្យខ្ញុំអានអីច្រើនពេកទេ ។

**ស៖** ខ្ញុំវាហាក់ដូចជាច្រឡំទៅលើព័ត៌មានទៅលើព័ត៌មានទាំងអស់នេះ ប្រសិនបើលោកនិយាយថា លោកមិនអានសៀវភៅរបស់លោក អាឡាំង ដូឡូស ថាតើហេតុអ្វីបានជាលោកអាចដកស្រង់សម្តីរបស់គាត់នៅក្នុងសៀវភៅទាក់ទងនឹងសម្តីរបស់គាត់ ខ្ញុំដូចជាមិនសូវយល់ចំពោះការលើកឡើងដូច្នេះ ។

**ឆ៖** ដែលខ្ញុំនិយាយមិញនេះ ដូចជានៅខាងដើមៗ ខ្ញុំបាទ អត់បានអានចប់ ហើយមិនយកចិត្តទុកដាក់ទេ ។ សម្តីមានមែន សម្តី អាឡាំង ដូឡូស និយាយហ្នឹង មានខ្ញុំចាំ បើកាលណាបរាជ័យមនុស្សឡើងទៅលើដំបូលផ្ទះហើយ ស្រែកជេរ *សេអ៊ីអា* នោះ ។

**ស៖** លោកប្រាប់យើងកាលពីព្រឹកមិញ លោកបានរកឃើញសៀវភៅធ្វើទារុណកម្ម នៅខាងអគ្គនាយកដ្ឋានប៉ូលិស ថាលោកអាចជម្រាបយើងខ្ញុំដែរឬទេ ថាសៀវភៅនោះមានសរសេរអ្វីខ្លះ?

**ឆ៖** សៀវភៅហ្នឹង ខ្ញុំក៏មិនបានអានដិតដល់ដែរ ដូចអាចតែដំបូងបន្តិច ហើយដល់ចុងបញ្ចប់ខ្ញុំឃើញគេដាក់រូបប៉ាប ដូចជា ប៉ាប អ្នី មិនដឹងឈ្មោះស្អីទេ ។ ហើយ ប៉ាប ហ្នឹងនិយាយថា ម្នាក់យើងវ៉ៃសួរចម្លើយ ឆ្លើយដាក់ម្នាក់ទៀត ដល់ចាប់ខុស តើនរណាទទួលខុសត្រូវ? នេះបញ្ហាមួយ ខ្ញុំក៏ទុកចោលទៅ វាអត់មានពេលជម្រាបលោកដោយត្រង់ អត់មានពេលអានទេ ។ ហើយសូមបញ្ជាក់ថា ខ្ញុំឧស្សាហ៍ប្រមូលសៀវភៅដែរ សូម្បីតែសៀវភៅមកពីស្រុកចិន ដែល *លេនីន* សរសេរតែម្តង ក៏អានមិនអស់ "*ម៉ាឡាឌីអង់ហ្វង់ទីលឌឺកុម្មុយនិស្ត*" ក៏ខ្ញុំអត់បានអាន។ មាន១នៅនុ៎ង ។ ខ្ញុំបានអានតែបន្តិច សៀវភៅថា "*លេនីនិស្តហ្ស៊ីម*" ស្នាដៃរបស់*ស្តាលីន* ហើយខ្ញុំចាំបានតែមួយឃ្លាទេ អានេះ គឺខ្ញុំបានអានមែន ដូច្នេះវាអត់មានពេល ។ ម៉្ងៃៗរវល់តែមេប្រើ អត់មានពេលអាន ។

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ពេលត្រូវពិសាអាហារថ្ងៃត្រង់ហើយ ។ អង្គជំនុំជម្រះសាលាដំបូង ប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ។ ហើយអនុរក្សមន្ទីរឃុំឃាំង ឲ្យនាំជនជាប់ចោទ ទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់មកវិញ នៅឲ្យបានមុនម៉ោងមួយកន្លះនៅរសៀលនេះ ។

*[សវនាការសម្រាកពីម៉ោង ១២:០៧នាទី ដល់ម៉ោង ១៣:៣៧នាទី ]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

កិច្ចពិភាក្សាដេញដោលលើអង្គហេតុដែលបានកំណត់ទុក ហើយមុននឹងប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីសួរសំណួរជាបន្តដល់ជនជាប់ចោទ អង្គជំនុំជម្រះសូមប្រកាសអំពីសេចក្តីសម្រេចរបស់ខ្លួន ដូចតទៅ៖

អង្គជំនុំជម្រះសាលាដំបូង ទទួលយកសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ដើម្បីណែនាំដល់ភាគីទាំងឡាយឲ្យបញ្ជាក់ឲ្យបានច្បាស់លាស់អំពីសំណើណាមួយ ដែលត្រូវធ្វើឡើងត្រូវដាក់លើឯក-សារនោះថា ធ្វើក្នុងនាមនរណា ។

សំអាងហេតុដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ បានដាក់សំណើនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩ ស្នើសុំសេចក្តីសម្រេចបង្គាប់ទៅមេធាវីជនជាប់ចោទ ឲ្យប្រាប់ទៅជនជាប់ចោទឲ្យឈប់ធ្វើកាយវិការទៅកាន់ពួកគាត់ ។ ពួកគាត់បានបញ្ជាក់ថា សំណើនេះត្រូវបានធ្វើឡើងបន្ទាប់ពីមានកិច្ចប្រជុំមួយជាមួយដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៣រូប ដែលពួកគាត់បានបង្ហាញនូវភាពមិនស្រួលក្នុងចិត្តនៅពេលឃើញជនជាប់ចោទ ធ្វើកាយវិការជាក់លាក់មួយចំនួន ដែលកាយវិការទាំងនោះ ពួកគាត់បកស្រាយថា ធ្វើឡើងដើម្បីសុំក្តីអាណិតអាសូរពីដើមបណ្តឹងរដ្ឋប្បវេណី ។ មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ បានស្នើសុំកុំឲ្យខ្លួនមានជាប់ពាក់ព័ន្ធនឹងសំណើនេះ ត្បិតខ្លួនកត់សម្គាល់ឃើញថា សំណើនេះទំនងជាត្រូវបានដាក់ក្នុងនាមភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ។

អង្គជំនុំជម្រះសាលាដំបូងបានស្តាប់ដោយផ្ទាល់មាត់នូវសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរកាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ គ្មានភាគីណាផ្សេងទៀតស្នើសុំឲ្យអង្គជំនុំជម្រះស្តាប់ខ្លួនទេ ។ សម្រេចសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ មានភាពមិនច្បាស់លាស់ដែលថា សំណើត្រូវបានធ្វើឡើងក្នុងនាមក្រុមដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ។ សំណើគប្បីបញ្ជាក់ឲ្យបានច្បាស់លាស់ថា សំណើនោះត្រូវបានធ្វើឡើងក្នុងនាមនរណា? សម្រាប់ជាប្រយោជន៍ដល់តុលាការផង និងដល់សាធារណជនទូទៅផង ។

បញ្ហាទី២ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីពាក់ព័ន្ធ ដែលចូលរួមនៅក្នុងដំណើរការសវនាការ ដែលបានសួរដល់អង្គជំនុំជម្រះពីព្រឹកមិញថា អង្គជំនុំជម្រះនឹងមិនធ្វើសវនាការទេ ចាប់ពីថ្ងៃទី១ ដល់ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៩ ខាងមុខនេះ ដោយហេតុអង្គបុរេត្រូវធ្វើសវនាការនៅក្នុងសាលសវនាការនេះ ដែលអង្គបុរេបានមានគម្រោងរួចហើយ ។

[១៣:៤១:០៩]

ម្តងទៀត អង្គជំនុំជម្រះជម្រាបដល់ភាគីថា អង្គជំនុំជម្រះសាលាដំបូង នឹងមិនធ្វើសវនាការទេ ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៩ ដោយមូលហេតុអង្គបុរេជំនុំជម្រះ ត្រូវធ្វើសវនាការនៅក្នុងសាលសវនាការនេះ ដែលអង្គបុរេបានរៀបចំគម្រោងផែនការរួចហើយ ។ ហើយអង្គជំនុំជម្រះសាលាដំបូងមិនមានគម្រោង មិនធ្វើសវនាការនៅក្នុងខែកក្កដា ឬខែសីហា ឡើយ ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះមានគម្រោងយកថ្ងៃទី២៧ ដល់ថ្ងៃទី៣១ ខែកក្កដា ធ្វើសវនាការរបស់ខ្លួននៅក្នុងសាលសវនាការ

នេះ ។ បញ្ហានេះអង្គជំនុំជម្រះសាលាដំបូង និងអង្គបុរេជនុំជម្រះនឹងពិភាក្សាគ្នាលើបញ្ហានេះ និងក្រោយពីពិភាក្សារួចហើយ អង្គជំនុំជម្រះសាលាដំបូងនឹងជូនដំណឹងដល់ភាគីពាក់ព័ន្ធជាក្រោយ ។

សូមអញ្ជើញលោកស្រី ខាតវ៉ាយថ៍ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំសូមធ្វើការបំភ្លឺជាភាសាអង់គ្លេស នៅក្នុងផ្នែកទី២នៃសេចក្តីសម្រេចនេះ ដោយសារតែមិនមានលក្ខណៈច្បាស់លាស់នៅពេល-- អង្គជំនុំជម្រះសាលាដំបូង គឺមិនមានគម្រោងក្នុងការសម្រាកនៅក្នុងខែកក្កដា និងសីហា នោះទេ ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា អង្គបុរេជំនុំជម្រះមានបំណងបើកសវនាការនៅក្នុងអំឡុងអាទិត្យ ថ្ងៃទី២៧ ដល់ថ្ងៃទី៣១ នៃខែកក្កដា ។ ដូច្នេះ លោកប្រធាននឹងធ្វើការពិភាក្សាទៅលើបញ្ហានោះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រូ ។

[១៣:៤៣:២៩]

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំទាញចំណាប់អារម្មណ៍អង្គសវនាការ ចំពោះការបកប្រែពេលខ្លះគឺមានលក្ខណៈផ្ទុយចំពោះការបកប្រែ ។ ខ្ញុំទើបតែឮថា អង្គជំនុំជម្រះមិនមានបំណងធ្វើការផ្អាកសវនាការនៅក្នុងខែកក្កដា និង ខែសីហា នោះទេ ។ គឺពីដំបូង ខ្ញុំឮថាអង្គសវនាការនឹងបើកសវនាការនៅក្នុងខែកក្កដានិងខែសីហា ហើយខ្ញុំសូមទាញចំណាប់អារម្មណ៍ទៅលើបញ្ហានេះ នេះជាដំណើរការនីតិវិធី ។ លោក លោកស្រីចៅក្រម និងភាគី អាចឃើញអំពីផលលំបាកទាក់ទងទៅនឹងបញ្ហានេះដែរឬទេ? ចំពោះការផ្តល់សក្ខីកម្ម និងចម្លើយរបស់សាក្សីនិងជនជាប់ចោទនៅពេលដែលមានបកប្រែ ។ យើងឃើញមានអត្ថន័យមានលក្ខណៈផ្ទុយទៅនឹងបំណងនៃសេចក្តីសម្រេច ឬក៏សក្ខីកម្មនិងចម្លើយផ្សេងៗ ។ ដូច្នេះ ខ្ញុំចង់ទាញចំណាប់អារម្មណ៍អង្គសវនាការឲ្យចាប់អារម្មណ៍ទៅលើបញ្ហានេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រី ខាតវ៉ាយថ៍ ។

[១៣:៤៤:៥៩]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

លោក រូ នេះគឺជាអ្វីដែលខ្ញុំបានកែប្រែជាភាសាអង់គ្លេសហើយ ហើយខ្ញុំដឹងថា លោក លោកស្រី ចៅក្រមនឹងភាគីទាំងអស់យល់ស្របថា មេធាវីផ្សេងៗគឺ យល់ឃើញមានកំហុសដូចគ្នានេះដែរ ដែលយើងត្រូវតែជូនដំណឹងភ្លាមៗទៅលើកំហុសនិងកែប្រែទៅលើកំហុសនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត សូមអញ្ជើញលោកសហព្រះរាជអាជ្ញាដើម្បីបន្តសំណួរដល់ជនជាប់ចោទ ។

សូមអញ្ជើញ ។

**សួរដោយ លោក អាឡិចសាន់ឌឺ ប៊ែត៖**

**ស៖** អរគុណលោកប្រធាន ។ ជាថ្មីម្តងទៀត ខ្ញុំនឹងរៀបចំសំណួររបស់ខ្ញុំឲ្យបានខ្លីបំផុតតាមតែអាចធ្វើទៅបាន ហើយខ្ញុំនិយាយឲ្យច្បាស់ៗ ដើម្បីឲ្យអ្នកបកប្រែបំពេញការងារបកប្រែរបស់ខ្លួន ដោយត្រឹមត្រូវ ។ ខ្ញុំដឹងថា ការងារនេះវាលំបាក ហើយដឹងថាភាគីគួរតែជួយសម្រួលបញ្ហានេះចំពោះអ្នកបកប្រែ ។

មុនពេលអាហារថ្ងៃត្រង់លោក កាំង ហ្កេកអ៊ាវ យើងនិយាយអំពីសៀវភៅ ដែលលោកប្រមូលបានមុនពេលដែល ស-២១ ចាប់ផ្តើមដំណើរការនៅក្នុងខែតុលា ឆ្នាំ១៩៧៥ ។ ដើម្បីបញ្ជាក់ខ្ញុំឲ្យបានច្បាស់ទៅលើបញ្ហានេះ ភស្តុតាងដែលបានលើកឡើងគឺមុនពេលដែលស-២១ ចាប់ផ្តើមដំណើរការលោកដោយខ្លួនឯងបានប្រមូលសៀវភៅរបស់អតីតប្រធាន ស៊ីអាយអេ គឺលោក *ដាឡឹស* ហើយមួយទៀត គឺលោកប្រមូលសៀវភៅស្តីអំពី *"ការហ្សេប"* ហើយទីបីគឺ សៀវភៅមួយក្បាល ឬក៏សៀវភៅទាំងឡាយ ស្តីអំពីការធ្វើទារុណកម្មនៅក្នុងរបប លន់ នល់ ។ ហើយលោកមិនដែលបានអានឯកសារសៀវភៅទាំងអស់នោះទេ តើខ្ញុំយល់ដូច្នេះត្រឹមត្រូវដែរ ឬទេចំពោះចម្លើយដែលលោកបានឆ្លើយបញ្ជាក់?

[១៣:៤៧:៥៤]

**ឆ៖** ការយល់របស់លោកត្រឹមត្រូវតាមចម្លើយខ្ញុំហើយ ពីព្រោះខ្ញុំសូមបញ្ជាក់អំពីហេតុផលខ្លះខ្ញុំចង់អាន ក៏ប៉ុន្តែវាអត់មានពេល ។ ប៉ុន្តែ សៀវភៅខ្លះវាអត់ជក់ចិត្តដែរ ។

**ស៖** ដូច្នេះ បន្ទាប់ពីស-២១ ចាប់ផ្តើមដំណើរការគឺចាប់ពីខែតុលា ឆ្នាំ១៩៧៥ រហូតមក គឺថាវាបង្ហាញថាលោកមិនបានអានសៀវភៅទាំងអស់នោះពីសម័យនោះ ។ ហើយនៅក្នុងអំឡុងដែលលោកធ្វើជាប្រធាននោះថា តើលោកបានអានសៀវភៅ ឬក៏លោកមិនដែលបានអានសៀវភៅទាំងអស់នោះ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ការអានសៀវភៅ ឧទាហរណ៍ដូចជា *"តិចនិចដឺវ៉ង់សែងញ៉ឺម៉ង់"* របស់ អាឡាំង ដឺឡូស ខ្ញុំចង់អានក៏ប៉ុន្តែសមត្ថភាពបារាំងរបស់ខ្ញុំនៅខ្វះខាត ។ ខ្ញុំបានឲ្យគេបកប្រែ ។ ប្រហែលជាសល់សំណៅបកប្រែនៅផ្ទះខ្ញុំ ខ្ញុំក៏មិនបានអានទៀត ។ សៀវភៅដែលខ្ញុំចង់អានបំផុត គឺទ្រឹស្តីកុម្មុយនីស្ត ។ ឧទាហរណ៍ សៀវភៅរបស់ ស្តាលីន ស្តីអំពី *"ឡឺ លេនីនីស្ត"* ខ្ញុំអត់បានអានទៀត អានបានមួយភ្លែត រវល់ចោលទៅទៀត ។ ដូច្នេះ រវល់ការងារទីមួយរវល់ ក៏ប៉ុន្តែការងារខ្លះវាទើសនឹងភាសាបន្តិចដែរ ។ ភាសាក៏ដោយ ក៏ប៉ុន្តែទ្រឹស្តីកុម្មុយនីស្ត ខ្ញុំចូលចិត្តអាន ក៏ប៉ុន្តែទៅវាមិនរួចទៅទៀតនេះសូមជម្រាបដោយត្រង់ចុះ ។ អត់មានពេល ។

[១៣:៥០:០០]

**ស៖** ប្រហែលជាការយល់ខុសរបស់ខ្ញុំ គឺថាលោកមិនបានអានសៀវភៅទាំងបីនោះទេ គឺត្រឹមត្រូវដែរឬទេ? សូមលោកបញ្ជាក់ទៅលើសំណួរមួយនេះ ។

**ឆ៖** សូមជម្រាបលោកថា មិនមែនមិនបានៗអានសោះទេណា បោះភ្នែកមួយភ្លែកឃើញ ។ បើ កាហ្សេបេ អត់បានអានសោះហ្នង គ្រាន់តែឃើញតែក្រប បញ្ជូនទៅលើបាត់ ។ ហើយបើ *"តិចនិចដឺវ៉ង់សែងញ៉ឺម៉ង់"* របស់ អាឡាំង ដឺឡូស បានអានខាងដើមពីរបីទំព័រ ចប់ ។ ឯចំណែក *"ឡាព័កខ្លូស"* ខ្ញុំបានអាននៅអាចុងនោះ សម្តីរបស់ ប៉ាប ទីប៉ុន្មានទេ ខ្ញុំភ្លេចអស់ហើយ មិនតិច ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សម្រាប់ការបកប្រែឲ្យបានត្រឹមត្រូវ តើយើងអាចមានឈ្មោះរបស់អ្នកនិពន្ធឲ្យបានពិតប្រាកដទេ ទាក់ទងទៅនឹងបច្ចេកទេសនៃការធ្វើទារុណកម្ម? ពីព្រោះអ្វីដែលនិយាយហ្នឹង គឺដូចចេញមកពីភាសាបារាំង ហើយអ៊ីចឹងប្រហែលជាអាចខុសពីអ្វីដែលជាចំណងជើងមែនទែន ឬក៏ឈ្មោះរបស់ អាឡាំង ដឺឡូស ឬក៏យ៉ាងម៉េចនោះ? ហើយទាក់ទងទៅនឹងសៀវភៅ ១ *"ស៊ីអាយអេ"* ផងដែរ ។

**លោក អាឡិចសាន់ឌឺ ប៊េត៖**

បាទ, អ៊ីចឹង ខ្ញុំចង់ប្រកបនូវឈ្មោះហ្នឹង ជាភាសាអង់គ្លេស A-L-L-E-N-D-U-N-L-L-E-S ។ បើនេះមិនមែនជាឈ្មោះជាភាសាបារាំង ឬក៏ខ្មែរទេ ជាអង់គ្លេស ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

អ៊ីចឹង នេះក៏ជាទាក់ទងទៅនឹងអ្នកនិពន្ធមួយទៀតហើយ ទាក់ទងសៀវភៅរបស់លោក ប៉ាប នោះ? អ៊ីចឹងទាល់តែយើងសួរជនជាប់ចោទ គាត់អាចដឹងបានពីអ្នកនិពន្ធរបស់សៀវភៅនោះ ។

**សួរដោយ លោក អាឡិចសាន់ឌឺ ប៊ែត៖**

ខ្ញុំមិនដឹងទេ លោកស្រីចៅក្រម ខ្ញុំមានសៀវភៅនេះ គឺរបស់ អាឡាំង ដឺឡូស បើសិនជាលោក លោកស្រីចៅក្រមចង់អានសៀវភៅនោះ ។ ពីព្រោះអីគ្រាន់តែនេះជាចំណុចតូចមួយនៅក្នុងការសួររបស់ខ្ញុំតែប៉ុណ្ណោះ ។ សូមអរគុណ ។

**ស៖** អ៊ីចឹង ខ្ញុំនិយាយពីប្រធានបទមួយផ្សេងទៀត លោក កាំង ហ្គេកអ៊ាវ គឺទាក់ទងនឹងលក្ខណៈសមស្របរបស់លោកទៅនឹងការងារនៅមន្ទីរស-២១ ។ អ៊ីចឹង នៅពេលដែលលោកបានជួបប្រជុំគ្នាជាមួយ សុន សេន នៅកាលពីខែសីហា ឆ្នាំ៧៥ តើជាការត្រឹមត្រូវទេ បើខ្ញុំនិយាយថា នៅពេលហ្នឹង គឺលោកជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជានៅពេលនោះ ។ តើជាការត្រឹមត្រូវទេ?

[១៣:៥៣:២៨]

**ឆ៖** បាទ, ត្រឹមត្រូវ ។ ខ្ញុំចូលបក្សពេញសិទ្ធិ ជាបក្ខជនពេញសិទ្ធិ នៅថ្ងៃ២០ កក្កដា ១៩៦៩ នៅគុកធំ ។ អ៊ីចឹងបានជាខ្ញុំព្រឹកមិញខំជម្រាបបញ្ជាក់លោកថា មេខ្ញុំមិនមែនជាបក្ខជនធម្មតាទេ ជាសមាជិកអចិន្ត្រៃយ៍មជ្ឈិមត្រៀម ។ ខ្ពស់ណាស់ ។ ខ្ញុំគ្រាន់តែជាសមាជិកមជ្ឈិមពេញសិទ្ធិ (សូមទោស) ជាសមាជិកធម្មតាជាសមាជិកពេញសិទ្ធិមួយរូបរបស់បក្ស ។ សូមបញ្ជាក់ឡើងវិញឲ្យច្បាស់ពាក្យ ខ្ញុំជាសមាជិកបក្សពេញសិទ្ធិ ចំណែកមេខ្ញុំនៅកំពូលដឹកនាំនោះ ជាអចិន្ត្រៃយ៍មជ្ឈិមត្រៀម ជាសមាជិកត្រៀម នៃអចិន្ត្រៃយ៍មជ្ឈិម ។ ដូច្នេះ ពីរនេះខុសគ្នា ។

[១៣:៥៤:២៤]

**ស៖** ដូចអ្វីដែលលោកបាននិយាយអ៊ីចឹងៗ បក្សហ្នឹងហើយនិងមេរបស់លោកចាត់ទុកលោកថា គឺជាកម្មាភិបាលមួយដែលស្មោះត្រង់ដែលពិតប្រាកដ ដែលជឿជាក់ទៅលើបក្សបំផុត? តើលោកអាចបញ្ជាក់ពីចំណុចនេះបានទេ?

**ឆ៖** តាមការធ្វើការងារក្រោមបង្គាប់គាត់ ហើយខ្ញុំពិចារណាឡើងវិញពីពេលឥឡូវ ខ្ញុំជឿថា គាត់ជឿលើភាពស្មោះត្រង់របស់ខ្ញុំចំពោះគាត់ ក៏ដូចជាចំពោះបក្ស ។

**ស៖** អ៊ីចឹង តើជាការត្រឹមត្រូវដែរឬទេ? បើសិនជាខ្ញុំនិយាយថា លោកមានរកកំណត់ដែលអាចជឿជាក់ច្បាស់អំពីការសួរចម្លើយខ្លាំង ដែលបានធ្វើអស់រយៈពេលជាច្រើនឆ្នាំនៅមន្ទីរម-១៣ នោះ តើត្រឹមត្រូវទេ?

**ឆ៖** សូមទោសលោកព្រះរាជអាជ្ញា ខ្ញុំសូមឲ្យលោកឲ្យគេបកប្រែម្តងទៀត ការបកប្រែដូចជាពិបាកស្តាប់ណាស់ ។

**ស៖** តើជាការត្រឹមត្រូវទេ រហូតមកដល់ខែសីហា ឆ្នាំ៧៥នោះ គឺថាយ៉ាងហោចណាស់គឺលោកមានបទពិសោធន៍ចំនួនបួនឆ្នាំដែលលោកបានមានទាក់ទងទៅនឹងការសួរចម្លើយនោះ? តើជាការត្រឹមត្រូវទេ?

[១៣:៥៦:២៦]

**ឆ៖** មែន ខ្ញុំមានបទពិសោធន៍ ។ ពិសោធន៍ខុស ពិសោធន៍ត្រូវនៅម-១៣ មានក្នុងរយៈកាលបួនឆ្នាំ ។

**ស៖** អ៊ីចឹង តើចំណុចមួយទៀត ជាការត្រឹមត្រូវទេលោក កាំង ហ្គេកអ៊ាវ ដែលថា ដែលលោកធ្លាប់មាន ហើយឥឡូវលោកក៏នៅតែមានការចង់ចាំដ៏ប្រសើរបំផុត បើការចងចាំឈ្មោះ ទីកន្លែង និងថ្ងៃខែនោះ? តើលោកទទួលស្គាល់នូវការពិតនេះទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ខ្ញុំមានការចងចាំច្រើនមែន ក៏ប៉ុន្តែខ្ញុំមិនដឹងថា ចងចាំនេះវាត្រឹមត្រូវមួយរយភាគនោះ ឬយ៉ាងម៉េច? បានប៉ុន្មានភាគរយ? ខ្ញុំអត់ហ៊ានធានាទេ ។ ក៏ប៉ុន្តែ ដោយដឹងខ្លួនឯង ដោយប្រៀបធៀប ខ្ញុំពិតជាមានការចងចាំលើរឿងរ៉ាវច្រើន ។

**ស៖** តើអ៊ីចឹងយើងអាចនិយាយបានទេថា ទាក់ទងទៅនឹងបក្សនោះកាលពីខែសីហា ឆ្នាំ៧៥ លោកគឺជាសមាជិកមួយដ៏ត្រឹមត្រូវបំផុតសម្រាប់ត្រួតពិនិត្យហើយនិងធ្វើការសួរចម្លើយនៅមន្ទីរស-២១នោះ?

**ឆ៖** សូមជម្រាប--

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមទោស! តើលោកអាចប្រាប់ឲ្យទៅខាងសហព្រះរាជអាជ្ញា ធ្វើការជៀសវាងសំណួរផ្សេងៗដែលទាក់ទងទៅនឹងចម្លើយ ដែលខាងសហព្រះរាជអាជ្ញាទុំង គាត់ចង់បានរួចទៅហើយនោះ ។ ឧទាហរណ៍ ថាតើលោកព្រមព្រៀងជាមួយខ្ញុំបែបនេះទេ? ឬក៏បែបនោះទេ? សំណួរអស់ទាំងហ្នឹងហាក់បីដូចជាគឺថាជាសំណួរបិទ ។ ហើយខ្ញុំគិតថា នេះមិនមែនជាចំណុចធម្មតាទេនៅក្នុងច្បាប់ខំមិនឡូ នោះ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

លោកប្រធានជាទីគោរព! ខ្ញុំចង់លើកឡើងនូវសំណួរសាមញ្ញៗ ហើយដាក់ចំៗតែម្តងសម្រាប់

ជនជាប់ចោទ ។ ដូចជាគាត់អ៊ីចឹង គាត់មានបទពិសោធន៍ហើយ ដែលគាត់បានផ្តល់ចម្លើយមកដល់នូវក្នុងអង្គសវនាការនេះជាមួយនឹងការកត់សម្គាល់ផ្សេងៗ ដែលមានន័យថា បើសិនជាសំណួរវែងចម្លើយក៏វែងដែរ ។ ហើយអ្វីដែលខ្ញុំព្យាយាម តំណាងឲ្យផ្នែកអយ្យការហ្នឹង គឺធ្វើការទទួលយកនូវព័ត៌មានយ៉ាងសាមញ្ញ ហើយច្បាស់លាស់បំផុតបើសិនជាខ្ញុំអាចធ្វើទៅបាន ។ ខ្ញុំមិនធ្វើសុំទោសទៅលើរបៀបដែលខ្ញុំធ្វើសំណួរនោះទេ ។ ហើយខ្ញុំគិតថា ខាងមេធាវីការពារក្តីដែលបានលើកឡើងបែបហ្នឹងគឺជាការមិនត្រឹមត្រូវទេ ។ ខ្ញុំចង់លើកឡើងប្រាប់លោកប្រធានថា ការលើកឡើងរបស់មេធាវីការពារហ្នឹង គឺមិនត្រឹមត្រូវទេ ។

[១៤:០០:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ជំទាស់របស់មេធាវីការពារក្តីគ្មានប្រសិទ្ធភាពទេ ។ អ៊ីចឹងសហព្រះរាជអាជ្ញាអាចបន្តសំណួរតទៅទៀតបាន តាមទម្រង់ដែលលោកបានមានរួចហើយនោះទេក៏បាន ឬក៏ទម្រង់ផ្សេងក៏បាន ។

**លោក អាឡិចសាន់ឌឺ បេ៊ត៖**

សូមអរគុណលោកប្រធាន ។ អ៊ីចឹង ខ្ញុំត្រឡប់ទៅសំណួរចុងក្រោយរបស់ខ្ញុំវិញ ។ ហើយប្រហែលជាខ្ញុំអាចផ្តល់នូវជម្រើសផ្សេងៗ ដើម្បីឲ្យជនជាប់ចោទធ្វើការឆ្លើយតបនូវជម្រើសណាមួយដែលគាត់យល់ថាសមស្របនោះ ។

បើអ៊ីចឹងគឺថា យើងបានដឹងថា ហើយលោកក៏បានទទួលស្គាល់ដែរថា លោកគឺជាកម្មាភិបាលជាសមាជិករបស់បក្សកុម្មុយនីស្តដ៏ស្មោះត្រង់ម្នាក់ ។ ហើយបក្សបានចាត់ទុកលោកថា ជាមនុស្សស្មោះត្រង់នឹងបក្ស ។ ហើយពីមុនមកគឺថា លោកមានបទពិសោធន៍ដ៏ល្អប្រសើរទាក់ទងទៅនឹងការសួរចម្លើយ ហើយលោកក៏មានផងដែរនូវការចងចាំដ៏ល្អបំផុត ប្រសើរបំផុត ។ គឺការចងចាំឈ្មោះ ទីកន្លែង និងថ្ងៃខែ ។

**ស៖** ហើយសំណួររបស់ខ្ញុំនៅពេលនេះគឺថា តើយើងអាចនិយាយបានទេថា សម្រាប់បក្សនោះលោកគឺជាបក្ខជនមួយល្អប្រសើរបំផុតដើម្បីមកធ្វើការនៅមន្ទីរស-២១? គឺថាលោកមានសេរីភាពក្នុងការឆ្លើយនូវចំណុចណាមួយដែលលោកចង់ឆ្លើយនោះ ប្រសិនជាលោកព្រមព្រៀងឯកភាព ឬមិនឯកភាព នេះជាជម្រើសរបស់លោក គ្រាន់តែលោកឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំនេះទៅបានហើយ ។

**ឆ៖** ទីមួយ ខ្ញុំសូមបញ្ជាក់ថា ធាតុពិតរបស់ខ្ញុំជាបក្ខជនខ្ញុំជាបក្ខជនពិតមែន តែជាបក្ខជនសាមញ្ញ ។ ត្រង់គុណភាពដែលលោកវិនិច្ឆ័យថា ខ្ញុំជាបក្ខជនដ៏ល្អ ដ៏ស្មោះត្រង់ ខ្ញុំសូមទុកដោយឡែកទុកឲ្យបក្សគេវិនិច្ឆ័យខ្ញុំចុះ ។ យើងពេលនេះនិយាយគ្នា ខ្ញុំមិនអាចឲ្យគុណភាពខ្លួនឯង ទៅលើខ្លួនឯងបានទេ នេះមួយ ។

ទីពីរ ខ្ញុំពិតជាមានការចងចាំច្រើន ក៏ប៉ុន្តែសួរថា ចងចាំបានទាំងស្រុងគ្រប់រឿងគ្រប់រ៉ាវទេ? ខ្ញុំមិនធានាជូនលោកទេ ។

ទីបី កាលដែលគេជ្រើសរើសខ្ញុំដោយសារខ្ញុំមានពិសោធន៍ក្នុងរឿងសួរ ។ តើបើប្រៀបធៀបពិសោធន៍ខ្ញុំនិងអ្នកផ្សេងទៀត គេមានការប្រៀបធៀបហើយនៅ? ខ្ញុំជឿថា ខ្ញុំមិនដឹងជារឿងគេ មិនដឹងជារឿងគេ ក៏ប៉ុន្តែដោយឡែកស-២១ ខ្ញុំអាចប្រៀបធៀបដោយវិនិច្ឆ័យទៅលើអតីតកាលរវាងខ្ញុំនិងណាតថាគេជឿទុកចិត្តខ្ញុំជាង ណាត ។ ខ្ញុំឆ្លើយប៉ុណ្ណឹង ។

ដូច្នេះ*កាលុយហ្វយកាស្យុង* ដែលគេឲ្យមកលើខ្ញុំ គឺគេទេ ។ ខ្ញុំគ្រាន់តែវិនិច្ឆ័យ ថាតើគេឈរស្អីដែលគេៗ តែងតាំងខ្ញុំធ្វើជាប្រធានតបន្តពី ណាត ។ ហើយក៏ប៉ុន្តែអាហ្នឹងជារឿងមើលទៅក្រោយរួចទៅហើយទេ យើងវិនិច្ឆ័យចិត្តគំនិតរបស់គេ ។ អ៊ីចឹង មិនទាន់ប៊ានធានាថាម៉េចទេ ។ ដូច្នេះ វាចូលទៅក្នុងការពិភាក្សាគ្នាបែបវិនិច្ឆ័យ បែបវិភាគចិត្តគំនិតគេ ។ មិនទាន់ប៊ានទៅថាយ៉ាងម៉េចជាប្រាកដ យើងនាំគ្នាវិភាគ វិនិច្ឆ័យទៅលើចិត្តគំនិតរបស់អ្នកដឹកនាំ ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ចិត្តគំនិតអ្នកដឹកនាំផ្សេង យើងរៀនវិភាគ ខ្ញុំ (សូមទោស) ខ្ញុំរៀនវិភាគចិត្តគំនិតគេផ្សេង ត្រូវឬមិនត្រូវអាហ្នឹងម្យ៉ាងទៀត ។

[១៤:០៥:៣៧]

**ស៖** កាលពីម្សិលមិញ លោកបានប្រាប់តុលាការថា តើលោកសុខចិត្តស្លាប់ ហើយគឺថាមិនចង់កុហក ភរកុហកអ្នកដទៃទេ ។ តើនោះគឺជាអ្វីដែលលោកចង់និយាយមែនទេ? ថានេះគឺជាសេចក្ដីសង្ខេបត្រឹមត្រូវនូវអ្វីដែលលោកនិយាយប្រាប់ចៅក្រម និងតុលាការកាលពីម្សិលមិញនោះ?

**ឆ៖** ពិត ខ្ញុំមិនដែលប៊ានកុហកគេទេ ។ មេខ្ញុំ ខ្ញុំអត់ដែលប៊ានកុហកគាត់ទេ ។ សូមលើកឧទាហរណ៍សាមញ្ញមួយ មុននឹងខ្ញុំមានកូន ខ្ញុំមិនដែលដើរចោលកន្លែងទេ ។ ដល់កាលណាខ្ញុំមានកូនល្ងាចឡើងម៉ោងបួន ម៉ោងប្រាំ ខ្ញុំច្រើនតែទៅមន្ទីរពេទ្យ ។ ហើយប៉ុន្តែ មុននឹងទៅខ្ញុំតេទូរស័ព្ទទៅប្រាប់ហើយស្រេច ឲ្យកន្លែងទូរស័ព្ទហ្នឹងគេជម្រាបបងផង បើបងសួររកខ្ញុំ ខ្ញុំនៅមន្ទីរពេទ្យណោះ ។

ដូច្នេះ គឺ សុទ្ធតែប្រាប់អ៊ីចឹង ។ ខ្ញុំទៅហូបចុកផ្ទះបង ហុក ខ្ញុំប្រាប់ថា ខ្ញុំនាំប្រពន្ធទៅហូបចុកផ្ទះបង ហុក (ឆាយ គឹមហ៊ា ឈ្មោះដើម ឆាយ គឹមហ៊ា) ខ្ញុំប្រាប់ រឿងអ៊ីចឹងៗខ្ញុំអត់ដែលទុកទេ ។ ដូចការពិភាក្សារវាងខ្ញុំជា មួយនឹងបង គឹមហ៊ា ។ បង គឹមហ៊ា ហ៊ឺ! កាលនោះនិយាយអំពីស្មារតី តា ឈឹង វង្វេងហើយ ដល់ខ្ញុំនិយាយអ៊ីចឹងវង្វេងហើយ ចូលសភាពការណ៍ ។ តាឈឹង នេះគឺរឿងអណ្តូងប្រេងកាតរបស់ចិន ដែលចិនគេលើកជាអង្គភាពគំរូមួយនៅស្រុកគេនោះ គេថា អ៊ូ!ស្មារតី តាឈឹង ល្អណាស់ ។ ដល់និយាយពី ស្មារតី តាឈឹង អ៊ីចឹងឡើង បង គឹមហ៊ា គាត់ថា ហ៊ឺប្រេងកាតចិនមានសំណាច្រើនណាស់ បើប្រេងកាតអាមេរិកកាំងល្អជាង ។ ខ្ញុំថ្ងៃមួយប៉ះដដែកគ្នាជាមួយមេ តាមទូរស័ព្ទ ខ្ញុំភ្លាត់អានិយាយរឿងហ្នឹង ។ ដូច្នេះ ដល់ភ្លាត់និយាយរឿងហ្នឹងមេដាក់មកភ្លួច ដូច្នេះអារឿងកំប៉ិកកំប៉ុកហ្នឹងខ្ញុំ ក៏អត់ដែលទុកដែរ យកទៅនិយាយជាមួយមេ ។ ដូច្នេះ អារឿងស្អីក៏ដោយ ខ្ញុំនិយាយ ។ ក៏ប៉ុន្តែត្រឡប់មកវិញលោកព្រះរាជអាជ្ញាអាចសួរខ្ញុំថា ចុះបើអ្នកឯងស្អីក៏និយាយៗអ៊ីចឹង រឿងអ្នកឯងមិនចង់ធ្វើការងារនគរបាល អ្នកឯងនិយាយដែរឬទេ? ភាសិតខ្មែរគេថា “កុំបកក្តាមបង្ហាញអាចម៍” ។ យើងមិនចង់ធ្វើតែត្រូវរកមធ្យោបាយសុំគេចេញ ត្រូវរកមធ្យោបាយសុំគេចេញ ហើយទៅថាហ៉ាៗខ្ញុំស្អប់ណាស់ការងារនគរបាល វាប៉ះលើសាច់ឯង ឈាមឯង កំបុតករឥឡូវហ្នឹង ល៉មើលជំនាន់នោះ ។ ហ្នឹងខ្ញុំសូមជម្រាបបញ្ជាក់អ៊ីចឹង ។ អំពីនិយាយការពិត និងសេចក្តីស្លាប់ ។ បញ្ចប់ ។

[១៤:០៨:២១]

**ស៖** នៅពេលលោកចាប់ផ្តើមឆ្លើយនូវចម្លើយដ៏វែងនេះ លោកបាននិយាយថា លោកមិនដែលកុហកប្រាប់ដល់មេរបស់គាត់ទេ ទាក់ទងនៅមន្ទីរ ស-២១ នោះតើជាការត្រឹមត្រូវទេ?

**ឆ៖** កិច្ចការនគរបាលនៅមន្ទីរស-២១ នោះរឿងរ៉ាវជាក់ស្តែងខ្ញុំមិនដែលប៊ានភរទេ អត់ដែលប៊ានភរសោះ រឿងអីដែលខ្ញុំដឹង ខ្ញុំរាយការណ៍ភ្លាម ទុកខ្លាចគ្រោះថ្នាក់ថ្ងៃក្រោយ ។ នេះមែន ។

**ស៖** តើលោកមានបានចាំថា លោកបានប្រាប់សហចៅក្រមស៊ើបអង្កេត ដែលថាលោកមិនជឿទេ ថាចម្លើយសារភាពដែលបានយកមកពីជនរងគ្រោះទាំងអស់នោះ គឺជាចម្លើយសារភាពពិតនោះ?

បើអ៊ីចឹង ខ្ញុំអាចអាននូវឃ្លានៃបទសម្ភាសន៍ដែលចុះធ្វើនៅថ្ងៃ១ ខែ៤ ឆ្នាំ២០០៨ គឺឯកសារ D67 ដែលមានលេខ ERN 0017634 ហើយសំណួររបស់ខាងសហចៅក្រមស៊ើបអង្កេតនោះគឺថា បាទនេះគឺនាំឲ្យដល់សំណួរមួយទាក់ទងទៅនឹងតម្លៃ ឬក៏បាទ អ្វីដែលមាននៅក្នុងចម្លើយសារភាព ។

តើលោកគិតថា ចម្លើយសារភាពទាំងអស់ហ្នឹងបង្ហាញនូវការពិតទេ? តើគំនិតរបស់លោកហ្នឹង

គឺវាកើតមានឡើងបន្ទាប់ពីលោកធ្វើការជាច្រើនឆ្នាំនោះឬ?

ហើយចម្លើយរបស់លោកនៅពេលហ្នឹងគឺថា តាមពិតខ្ញុំមិនជឿចម្លើយសារភាពនោះទេ ។ នៅករណី កុយ ធួន ជាឧទាហរណ៍ គឺឈ្មោះគាត់ K-O-Y នោះ T-H-O-U-N នោះ ។ នៅក្នុងសំណុំរឿងរបស់ កុយ ធួន នោះគឺថាចម្លើយហ្នឹងវាមិនស៊ីគ្នា ទៅនឹងការពិតទេ ។ ប៉ុន្តែ ខ្ញុំគ្មានភស្តុតាងដើម្បីបង្ហាញនូវចំណុចនេះទេ ទោះបីជាគណៈអចិន្ត្រៃយ៍ក៏ដោយ នៅក្នុងគំនិតរបស់ខ្ញុំគឺថា មិនជឿទៅលើចម្លើយសារភាពទាំងនោះទេ ។ នេះគឺដើម្បីជាការរកលេសដើម្បីកំចាត់អ្នកទាំងអស់នោះ ដែលជាឧបសគ្គ ។ ហើយក្រោយនោះបន្តិចទៀតនៅក្នុងចម្លើយរបស់លោកនោះ លោកបាននិយាយថា ជាការពិត តាមការពិតនោះ តាមពិតនៅម-១៣ ខ្ញុំបានដឹងថា ចម្លើយសារភាពទាំងនោះ គឺមិនបង្ហាញ មិនឆ្លុះបញ្ចាំងពីការពិតទេ ។

អ៊ីចឹង ចំណុចទីមួយ តើលោកព្រមទទួលទេនៅថ្ងៃនេះដែលថា នេះគឺជាអ្វីដែលលោកចង់និយាយប្រាប់តុលាការនោះ? នេះគឺជាភស្តុតាងរបស់លោកទាក់ទងទៅនឹងការពិតដែលមាននៅក្នុងចម្លើយសារភាពនោះ តើលោកអាចនិយាយប្រាប់តុលាការបានទេ ទាក់ទងទៅនឹងចំណុចនេះ?

[១៤:១១:១៩]

**ឆ៖** លោកព្រះរាជអាជ្ញា ខ្ញុំអត់យល់សំណួរលោកទេ ជម្រាបឲ្យត្រង់ហ្វូវហែណាស់? ហើយដល់ ឥឡូវចុងបញ្ចប់លោកសួរ តើលោកចង់សួរអី មានប្រសាសន៍ឲ្យបានច្បាស់មក?

**ស៖** ខ្ញុំបានអានអត្ថបទដែលលោកបានឆ្លើយតបជូនសហចៅក្រមស៊ើបអង្កេត ជាបឋមគឺ ខ្ញុំគ្រាន់តែសួរថា តើលោកទទួលយកអ្វីដែលលោកបញ្ជាក់ចំពោះសហចៅក្រមស៊ើបអង្កេតដែរឬទេ? ឬក៏លោកចង់ផ្លាស់ប្តូរចម្លើយនោះ សូមឲ្យឆ្លើយថា ចង់បញ្ជាក់ ឬក៏មិនយល់ព្រមទៅលើបញ្ហានោះ?

**ឆ៖** ឥឡូវសូមលើកមួយៗ ឥឡូវនិយាយអំពីចម្លើយ កុយ ធួន ដើម្បីឲ្យច្បាស់យើងនិយាយអំពីបញ្ហាមួយៗកុំឲ្យវែងពេក ។ សូមនិយាយអំពីចម្លើយ កុយ ធួន ។

**លោក អាឡិចសាន់ឌឺ បេ៊ត៖**

សូមអភ័យទោសលោកប្រធាន ។ ខ្ញុំលើកឡើងចំណុចទូទៅ ថាតើជនជាប់ចោទទទួលស្គាល់ចំពោះករណីដែលថា ចម្លើយសារភាពនោះ គឺជាការឆ្លុះបញ្ចាំងទៅលើការពិត ឬក៏មិនការពិត ហើយខ្ញុំគ្រាន់តែដកទៅលើសម្តី ឬឧទាហរណ៍មួយដើម្បីបញ្ជាក់តែប៉ុណ្ណោះ យើងបានស្តាប់ចម្លើយច្រើនមក

ហើយទៅលើករណីទាំងអស់នោះ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវអ៊ីចេះ ដើម្បីឲ្យងាយស្រួល សូមលោកចាត់ចែងយកកំណត់ហេតុនៃការប៉ុនប៉ងសួររបស់សហព្រះរាជអាជ្ញាហ្នឹងជូនជនជាប់ចោទ ដើម្បីពិនិត្យថា តើឃ្លាចំណុចណាមួយដែលលោកសហព្រះរាជអាជ្ញាចង់សួរបញ្ជាក់នេះ? ដើម្បីឲ្យច្បាស់ ។

ក្រឡាបញ្ជីចាត់ចែងនូវចម្លើយអម្បាញ់មិញនេះ យកទៅជូនគាត់ ហើយឲ្យគាត់កត់សម្គាល់ឲ្យបានច្បាស់លាស់ចំណុចណាមួយនៃចម្លើយនៅក្នុងឯកសារ D67 ដែលមានការប៉ុនប៉ងសួរបញ្ជាក់ទៅលើជនជាប់ចោទ ហើយឲ្យជនជាប់ចោទឆ្លើយតបនោះ ។

អញ្ជើញជនជាប់ចោទ អាចយល់បានទេ? អាចឆ្លើយបានទេ?

[១៤:១៣:៥៨]

**ឆ៖** លោកប្រធានជាទីគោរព! បើសិនជាលោកអនុញ្ញាតក្នុងការចង់លើកពីចម្លើយរបស់ខ្ញុំបាទពីរយៈពេលស៊ើបអង្កេត មិនបាច់យកមកបញ្ចាំងតាមអេក្រង់នេះទេ ។ ខ្ញុំសូមអញ្ជើញលោកព្រះរាជអាជ្ញាខ្មែរលោកអានកំណត់ហេតុរបស់ខ្ញុំ ដែលខ្ញុំឆ្លើយចំពោះចៅក្រមស៊ើបអង្កេត ហើយលោកព្រះរាជអាជ្ញាខ្មែរក៏បាន លោកអាឡិច ខ្លួនលោកក៏បានសួរខ្ញុំ តាមកំណត់ហេតុដែលមាននៅក្នុងសេចក្ដីសារភាពរបស់ខ្ញុំជូនសហចៅក្រមស៊ើបអង្កេត ។

**ប្រធានអង្គជំនុំ៖**

ចាត់ចែងបានទេ? ធ្វើដូច្នេះបានទេ? ដើម្បីឲ្យច្បាស់ពីព្រោះហាក់ដូចជាការសួរហ្នឹងមិនច្បាស់ ឬក៏មិនចំនឹងចំណុចណាមួយជាក់លាក់ដើម្បីសួរឲ្យច្បាស់ ដើម្បីឲ្យឆ្លើយហ្នឹងមកចំនឹងសំណួរតែម្ដងអាចអានបានទេ លើចំណុចដែលមានការប៉ុនប៉ងសួរនេះដើម្បីឲ្យជនជាប់ចោទស្ដាប់នូវបញ្ហាសិនមុននឹងឆ្លើយ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

**ស៖** ខ្ញុំអាចធ្វើដូច្នោះបាន គឺខ្ញុំនឹងបញ្ជាក់ ហើយសួរដោយងាយៗជាងមុន ហើយខ្ញុំសួរជនជាប់ចោទនៅថ្ងៃនេះ ដែលគាត់អង្គុយនៅក្នុងរង្វង់ក្រចកសេះនៅមុខអង្គសវនាការ ថាតើគាត់ជនជាប់ចោទជឿទេ នៅពេលនោះ នៅពេលដែលគាត់ធ្វើការនៅស-២១ គាត់ជឿដែរឬទេ ថាចម្លើយសារភាពគឺជា

ការពិត ឆ្លើយបញ្ជាក់ទៅលើការពិត ឬក៏ចម្លើយសារភាពនោះ គឺមិនមែនជាការពិត ។

ដូច្នេះ ខ្ញុំចង់ឲ្យជនជាប់ ចោទបញ្ជាក់ទៅលើបញ្ហាហ្នឹង ។

**ឆ៖** ចម្លើយសារភាពទាំងអស់ ខ្ញុំបានរាយការណ៍ជូនអង្គសវនាការច្រើនលើកហើយ ។ ហើយក៏បានជម្រាបបញ្ជាក់ជូនសហចៅក្រមស៊ើបអង្កេតច្រើនលើកដែរ ថាវាមិនបញ្ជាំងនូវការពិតទេ ។ នេះជាពាក្យដែលខ្ញុំបានរាយការណ៍ ខ្ញុំនៅរក្សាពាក្យនេះ វាមិនបញ្ជាំងនូវការពិតទេ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន សូមអភ័យទោសចំពោះការកាត់សម្តីនៅពេលនេះ ។ សូមឲ្យភាគីគាត់សួរសំណួរដែលមិនសួរដេញដោលពីមុន ហើយចំពោះសំណួរទាក់ទងទៅនឹងបញ្ហានៃការសារភាព គឺជាហូរហែជនជាប់ចោទ គាត់បានលើកឡើងម្តងហើយម្តងទៀត ហើយព្រឹកមិញក៏គាត់លើកឡើងផងដែរ ។ គាត់ជឿថា ចម្លើយសារភាពនោះមានតែហាសិបភាគរយទេដែលជាការពិត ។

ដូច្នេះហើយ វាជាការចំណាយពេលឥតប្រយោជន៍ក្នុងការចោទសួរសំណួរដដែលៗទាំងអស់នោះ ។

[១៤:១៧:២៧]

លោកប្រធានជាទីគោរព! លោក លោកស្រីចៅក្រម ប្រហែលជាពេលនេះ គឺជាពេលវេលាចំពោះការចោទសំណួរពីខាងសហព្រះរាជអាជ្ញា និងលោក លោកស្រីចៅក្រម ។ សហព្រះរាជអាជ្ញា គឺបានចោទសួរជនជាប់ចោទ ហើយបានបញ្ជូនឯកសារយ៉ាងច្រើនទាក់ទងទៅនឹងការទទួលស្គាល់ អំពីការពិត ។ ជនជាប់ចោទបានចំណាយច្រើនម៉ោងធ្វើការវិភាគទៅលើឯកសារទាំងអស់នោះ ហើយបានពិចារណា និងលើកឡើងអំពីឯកសារទាំងអស់នោះ ។ វាជាឯកសាររបស់សហព្រះរាជអាជ្ញាទាំងអស់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយស្តីអំពីការបង្កើតស-២១ ។ ឯកសារនោះ គឺវាមានផ្នែកដែលមាន២០វាក្យខណ្ឌ ហើយនៅក្នុងមួយវាក្យខណ្ឌមួយនោះជនជាប់ចោទ គាត់បានឆ្លើយថា គាត់មិនយល់ស្រប ។ ហើយវាក្យខណ្ឌចំនួន២ ជនជាប់ចោទ គាត់បាននិយាយថា គាត់យល់ស្របដោយខ្លួនគាត់ ។ ហើយវាក្យខណ្ឌចំនួនបី គាត់ជនជាប់ចោទបានលើកឡើងថា មិនមានការជំទាស់ ។ ហើយចំពោះកថាខណ្ឌដទៃៗ ទៀត គឺជនជាប់ចោទគាត់បានយល់ស្រប ។

ដូច្នេះហើយ ចំពោះខ្ញុំបើសិនជាយើងចង់ឲ្យដំណើរការកាត់ក្តី ដំណើរការទៅមុខបន្ទាប់ពីសំណួរមួយចំនួនបានសួរទៅលើជនជាប់ចោទហើយនោះ អំពីអង្គហេតុផ្សេងៗ សំណួររបស់សហព្រះរាជ

អាជ្ញាគួរតែផ្អែកទៅលើកថាខណ្ឌទាំងឡាយដែលជនជាប់ចោទគាត់តវ៉ា ។ ជាពិសេស ទៅលើកថាខណ្ឌចំនួនពីរដែលគាត់ ជនជាប់ចោទនោះ គឺគាត់យល់ស្របមួយផ្នែក ។ បើសិនមិនដូច្នោះទេ គឺយើងនឹងចំណាយពេលច្រើនខែផ្តោតលើឯកសារទាំងអស់ ដែលសហព្រះរាជអាជ្ញាបញ្ជូនមកជនជាប់ចោទ ។

ដូច្នេះ ដោយសារតែយើងមិនមានពេលវេលាទៀតទេ យើងមិនគួរធ្វើការពិចារណាដដែលៗទៅលើឯកសារទាំងអស់នោះទេ ។ សូមអរគុណលោកប្រធាន ។

[១៤:២០:០៥]

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

គឺទាក់ទងនឹងអង្គហេតុដែលបានព្រមព្រៀងគ្នា គឺប្រហែលជា វាជាលក្ខណៈមួយមិនសមរម្យ ឬក៏សមរម្យក្នុងការលើកសំណួរងាយៗ ។ សហព្រះរាជអាជ្ញានៅតែយល់ ។ យើងមានកាតព្វកិច្ច ក្នុងការបង្ហាញភស្តុតាងនៅក្នុងរឿងក្តី ។ ហើយចំពោះអង្គហេតុដែលបានយល់ស្របគ្នានោះ គឺមិនបានដោះបន្ទុករបស់សហព្រះរាជអាជ្ញានោះទេ ហើយខ្ញុំទទួលដឹងអំពីចំណុចរបស់មេធាវីការពារក្តី ហើយយើងមិនចង់ចំណាយពេលច្រើនទៅលើអង្គហេតុនោះទេ ។ ដោយខ្ញុំសូមអនុញ្ញាតពីអង្គសវនាការ គឺខ្ញុំសូមចូលទៅដល់ចំណុចមួយទៀត បន្ទាប់ទៀតទាក់ទងទៅនឹងបញ្ហាទាំងអស់នេះ ។ សូមការអនុញ្ញាតពីលោក លោកស្រីចៅក្រមជាទីគោរព ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការជំទាស់របស់មេធាវីការពារក្តីលើចំណុចនៃការតាំងសំណួរច្រំដែលជាការត្រឹមត្រូវ ។ ដូច្នេះ សូមសហព្រះរាជអាជ្ញាមានការប្រយ័ត្នប្រយែងបញ្ចៀសនូវការសួរនូវសំណួរច្រំដែល ។ ហើយសំណួរច្រំដែលនេះមិនត្រឹមតែអង្គហេតុនេះទេ អង្គហេតុម-១៣ ដែលយើងបានធ្វើសវនាការរួចហើយ ហើយជនជាប់ចោទបានឆ្លើយបំភ្លឺរួចហើយនោះចាត់ទុកថា បើសួរទៀតមានន័យថា សួរច្រំដែលហើយ ។ ទីពីរ គឺអង្គជំនុំជម្រះរំឭកម្តងទៀត សូមឲ្យភាគីមានព្យាយាមក្នុងការសួរទៅតាមអង្គហេតុដែលបានកំណត់ទុក ដើម្បីយើងពន្លឿននូវដំណើរការពិភាក្សាដេញដោល ។

ដោយឡែក បញ្ហានៃការលើកឡើងរបស់មេធាវីការពារក្តីអំពីអង្គហេតុដែលបានព្រមព្រៀង អង្គហេតុដែលមិនជំទាស់នឹងអង្គហេតុជំទាស់មួយផ្នែកៗ និងអង្គហេតុជំទាស់ទាំងស្រុងនោះ អង្គជំនុំជម្រះបានពិភាក្សាលើបញ្ហានេះហើយ គឺមិនអាចជៀសវាងឲ្យផុតពីការយកមកបញ្ហានោះមកពិភាក្សាដេញដោលទេ ពីព្រោះនេះជារឿងព្រហ្មទណ្ឌដែលត្រូវតែមានការពិភាក្សាដេញដោលលើបញ្ហាទាំងនោះ គ្រាន់

តែកំហិតនៃបច្ចេកទេសក្នុងការពិភាក្សាដេញដោល យើងរកច្រកណាដែលងាយក្នុងការប្រព្រឹត្តិទៅ ។ បើសិនជាមិនមានជំទាស់នឹងការជជែកវែកញែកពិភាក្សាដេញដោយក៏ប្រហែលជាយើងប្រើពេលវេលាខ្លីជាងករណីធម្មតាដែរ ។

ហើយបន្តទៀតសូមអញ្ជើញសហព្រះរាជអាជ្ញាបន្តសំណួរទៀត ។

[១៤:២៣:០២]

**សួរដោយលោក អាឡិចសាន់ឌឺ ប៊េត៖**

**ស៖** អរគុណលោកប្រធាន ។ ចំពោះចម្លើយសារភាពដែលលោកជឿថា មិនមានការផ្ទុះបញ្ចាំងការពិត ឬក៏អ្វីដែលលោកបានប្រាប់កាលពីព្រឹកមិញថាលោកជឿហាសិបភាគរយ ។ តើលោកធ្លាប់ប្រាប់មេរបស់លោកដែរឬទេ ឬក៏ធ្លាប់ប្រាប់បុគ្គលដែលលោកធ្វើការជាមួយហ្នឹងនៅស-២១ ថាលោកមិនជឿចម្លើយសារភាពទាំងអស់នោះ ថាវាផ្ទុះបញ្ចាំងការពិតទេ?

**ឆ៖** ចំពោះការប្រាប់បុគ្គលិក ខ្ញុំគិតថា មេរៀនដែលខ្ញុំបង្រៀនកូនចៅខ្ញុំដែលគេមានការកត់ត្រាទុក ប្រហែលជាអាចសំដែងឲ្យឃើញថាយើងត្រូវតែយកចិត្តទុកដាក់ ។ ពាក្យថា "*យើងត្រូវតែយកចិត្តទុកដាក់*" មួយម៉ាត់នេះដែលយើងខ្ញុំបង្រៀនកូនចៅ វាបង្ហាញថាចម្លើយនេះវាមិនមែនពិត។ នេះមួយ ។ ពីរទៀតនៅសល់ឯកសារជាភស្តុតាងដែរ ។ សូមលោកព្រះរាជអាជ្ញាទៅមើលក្នុងឯកសារកំណត់ហេតុរបស់បង ម៉ម ណៃ ខ្ញុំរាប់រៀបអំពីខ្សែកុន ខ្សែភាពយន្តរបស់ចិន ។ ក្នុងនោះលោកក៏ឃើញដែរ ឡូតគ្រាប់កាំភ្លើង ឡូវអាវជ្រុះពីខ្ញុំ អធិប្បាយអំពីរឿងហ្នឹង ។

ដូច្នេះ ការងារសួរចម្លើយ ខ្ញុំបានបង្រៀងថាជាការងារពិបាក ទាំងអស់នេះយើងខ្ញុំមិនប៉ានប្រាប់ត្រង់ទៅកូនចៅថា ចម្លើយវាសុទ្ធតែមិនពិត ពិតហាសិបភាគរយទេអីៗ មិនដែលនិយាយទេ ក៏ប៉ុន្តែក្នុងការជាអ្នកបង្រៀន ក្នុងការជាអ្នកដឹកនាំគេ ក្នុងការជាអ្នកចង់បានឲ្យមានការពិតច្រើនគួរសម យើងបង្រៀនអីចឹង ។ ត្រូវប្រយ័ត្ន ត្រូវទៅមុខទៀត ។

ឯចំណែកជាមួយមេ យើងខ្ញុំមិនដែលប៉ាននិយាយថា អ៊ូ! ចម្លើយនេះមិនពិតទេ វាឃើវាចេះតែឆ្លើយ យើងខ្ញុំមិនដែលប៉ាននិយាយទេ នេះជម្រាបឲ្យត្រង់ ។ ក៏ប៉ុន្តែមានពាក្យមួយ ខ្ញុំនិយាយញឹក នៅពេលដែលចាប់អ្នកណាម្នាក់ទេ ខ្ញុំសាកល្បងតវ៉ាជាមួយនឹងមេ ។ ខ្ញុំសាកល្បងតវ៉ាជាមួយនឹងមេ ខ្ញុំថាអានេះដូចជាមិនអី ដូចមិនមែនទេបទ? យ៉ឺ ឌុច នេះចម្លើយ អាឃ្មួន ណ៎ា ។ ខ្ញុំនិយាយជាមួយនឹងចៅក្រមស៊ើបអង្កេតរួចហើយបញ្ហានេះ ។ ពាក្យនេះវាស្ដែងចេញពីខ្ញុំទៅគាត់ ពីគាត់មកខ្ញុំ ជាបទសន្ទនា ក៏ប៉ុន្តែ

ទាំងពីរនាក់សុទ្ធតែដឹងថាចម្លើយមួយចំនួនមិនពិត ។ លោកយកពាក្យហ្នឹងមកផ្ទុះបញ្ចាំងមើល ខ្ញុំថាមនុស្សនេះដូចមិនអីទេបង ឯគាត់ៗឆ្លើយមក ចម្លើយអាឃួន ណា៎ ។

ដូច្នេះ ក្រៅពីចម្លើយ អាឃួន គាត់មានទទួលស្គាល់អាចម្លើយផ្សេងទៀតវាមិនពិត ។ នេះជាសភាពការណ៍ជាក់ស្តែងដែលខ្ញុំសូមយកមកវិភាគ ប៉ុន្តែបើសិនជាលោកចង់ឲ្យខ្ញុំ *អះហៀម៉េ* ថាខ្ញុំបានប្រាប់មេទេ? សូមជម្រាបដោយត្រង់ ខ្ញុំអត់ប៊ានទេណ៎ា កំបុតក ។ ខ្ញុំប៊ានប្រាប់ កូនចៅចំហទេ ខ្ញុំអត់ប៊ានទេ រឿងឥឡូវហ្នឹងដឹងដល់មេ ។

ដូច្នេះក្នុងឋានៈខ្ញុំជាអ្នកដឹកនាំ ត្រូវតែខំធ្វើទោះពេញចិត្តក៏ដោយមិនពេញចិត្តក៏ដោយ បង្រៀនអំពីបច្ចេកទេស ដោយបង្ហាញគេថា ត្រូវខំតទៅទៀត ដើម្បីឲ្យបានសេចក្តីពិតជាអតិបរមា ។ នេះជាកិច្ចការដែលយើងខ្ញុំធ្វើ ហើយយកមក *អះហៀម៉េ* ម៉ាជ្រុង ហើយធ្វើឲ្យបាន *អះហៀម៉េ* មួយរយភាគរយ ខ្ញុំអត់ទៅរួចទេ ខ្ញុំអត់ដែលប៊ានទេ ។

នេះសូមបញ្ជាក់ប៉ុណ្ណឹង ។

**ស៖** ខ្ញុំសូមបន្តចំពោះគណៈកម្មាធិការនៅស-២១ ។ នៅពេលដែលលោកជាអនុស-២១ ក្នុងការបង្កើតស-២១ គឺវាត្រឹមត្រូវដែរទេ ដែលថាមានការបង្កើតគណៈកម្មាធិការនៅក្នុងហ្នឹង? ដែលការបង្កើតហ្នឹងវាមានទម្រង់ និងបែបបទនៅក្នុងជួរបក្សកុម្មុយនីស្ត គឺយើងមានប្រធាន និងអនុប្រធាន និងសមាជិក ។ ប្រធានគឺ ណាត ហើយអនុគឺលោក ហើយនិងសមាជិកគឺ ហ៊ ។ ដូច្នេះ សំណួររបស់ខ្ញុំគឺថាថាតើគណៈកម្មាធិការនៅក្នុង ស-២១ នេះជួបគ្នាញឹកញយប៉ុនណា ក្នុងពេលដែលលោកជាអនុប្រធាននៅពេលនោះ?

**ឆ៖** សូមជម្រាបលោកព្រះអាជអាជ្ញា នៅពេលដែលខ្ញុំជាអនុប្រធាន ការជួបជុំគ្នាទាំងបីនាក់ដូចជាអត់ យ៉ាងច្រើនណាស់ម្តង ដូចជាអត់ទៅទៀត ។ ក៏ប៉ុន្តែខ្ញុំជាប់ជាមួយនឹង ណាត ។ គេប្រើខ្ញុំខាងបច្ចេកទេសសុទ្ធ ពីដំណាក់មួយទៅដំណាក់មួយគេប្រើយ៉ាងម៉េច? អាហ្នឹងបើសិនជាលោកព្រះរាជអាជ្ញាលោកត្រូវការខ្ញុំរាប់រៀបជូន ។

**ស៖** ខ្ញុំមានការចាប់អារម្មណ៍ក្នុងការចោទសួរទៅលើការប្រជុំយ៉ាងហោចណាស់ម្តងរបស់គណៈកម្មាធិការនៅក្នុង ស-២១ ថាវាកើតឡើងនៅពេលនោះការប្រជុំនោះ ហើយបានពិភាក្សាទៅលើចំណុចអ្វីខ្លះ?

**ឆ៖** សូមជម្រាបលោកសហព្រះរាជអាជ្ញា ការប្រជុំម្តងដែលជៀសមិនរួចត្រូវតែធ្វើគឺសន្និបាតប្រចាំឆ្នាំរបស់មន្ទីរ ស-២១ ដែលខ្ញុំបានរាយការណ៍ជូនទៅក្រុម ឡាវែន៍ រួចហើយ ជុំគ្នាតែម្តង ។ ខ្ញុំបានជម្រាបថា ណាត គាត់ប្រធានមែន ក៏ប៉ុន្តែ ដល់ដឹកនាំប្រជុំដល់ដែលមានទ្រឹស្តីកុម្មុយនីស្ត ទ្រឹស្តីរបស់បក្សកុម្មុយនីស្តដូច្នេះ គាត់ឲ្យខ្ញុំចេញមុខ នេះគឺជុំគ្នាមែន ។ កាលនោះយើងពិភាក្សាគ្នាថា ត្រូវបន្តធ្វើបដិវត្តន៍សង្គមនិយមនិងកសាងសង្គមនិយមតទៅទៀត ។

បញ្ហាចោទឡើងថា តើត្រូវធ្វើម៉េច? ទាំងអស់គ្នាជជែកគ្នាមួយយប់ ដើម្បីយកបញ្ហា ។ នេះជាការជុំគ្នាទាំងបួននាក់ ទូលាយតែម្តង បើកទូលាយតែម្តង បក្សជនទាំងអស់នៅក្នុងស-២១ ហ្នឹងទៅស្តាប់ទាំងអស់ នេះគឺជុំគ្នា ។ ក្រៅពីនោះមកច្រើនពីរនាក់ ខ្ញុំហើយនិងគាត់ ។ ច្រើនតែគាត់ប្រើខ្ញុំឲ្យធ្វើការងារបច្ចេកទេស បែបនេះ បែបនោះហូរហែ ។

ដូច្នេះ ការជុំម្តងនេះច្បាស់ណាស់ សន្និបាតបក្ស សូមទោស សន្និបាតគណៈកម្មាធិការបក្សមន្ទីរ ស-២១ ប្រចាំឆ្នាំ១៩៧០ ចុងឆ្នាំ៧៥ ។ ដូច្នេះ ប្រចាំ៧៦ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

បើអឺចឹងលោកប្រធាន ខ្ញុំនឹងចូលដល់ប្រធានបទថ្មី តើលោកប្រធានចង់ឲ្យខ្ញុំបន្តទៅក្នុងប្រធានបទថ្មី ឬក៏យើងចង់សម្រាបន្តិចសិន?

**ប្រធានអង្គជំនុំ៖**

បន្តទៀត មិនទាន់ដល់ម៉ោងត្រូវសម្រាកទេ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

**ស៖** សូមអរគុណលោកប្រធាន ខ្ញុំចង់សួរលោកបន្តិចទៀត អំពីការបណ្តុះបណ្តាលរបស់ខ្លួនលោកផ្ទាល់ និងអ្នកដែលលោកបានរៀនជំនាញសួរចម្លើយ និងធ្វើទារុណកម្មហ្នឹងរៀនពីណា នរណាគេមក? លោកបានប្រាប់យើងថា វន វ៉េត បានបង្រៀនលោកនៅម-១៣ អំពីវិធីនៃការប្រើច្រកចង់ផ្តាស្ទីកពីលើក្បាល ហើយដើម្បីរកមើលសរសៃជីពចរនៅចំហៀងករបស់ជនជាប់ទោស ដើម្បីដឹងថា តើគេនិយាយប្រាប់ការពិតឬក៏អត់នោះ ។ ខ្ញុំមិនដឹងឲ្យបានច្បាស់ថា តើលោកបានរៀនទម្រង់ ឬក៏វិធីផ្សេងៗនៃការសួរចម្លើយ និងការធ្វើទារុណកម្មពីនរណាមក? តើលោករៀនមកពីនរណា? តើលោករៀនពីសៀវភៅណា? លោកអាចជម្រាបប្រាប់អង្គសវនាការបានទេ?

**ឆ៖** សូមជម្រាបលោកសហព្រះរាជអាជ្ញា ថាការរៀនធ្វើទារុណកម្មដែល បងវន គាត់បង្រៀនខ្ញុំមានពីរបែបហ្នឹងឯង ។ ទីមួយគឺរបៀបធ្វើទារុណកម្មច្រកថង់ផ្លាស្ទីក ហើយខ្ញុំជម្រាបតុលាការជាហូរហែមកហើយថា ផ្ទាល់ខ្លួនខ្ញុំ ខ្ញុំគ្មានថង់ផ្លាស់ស្ទីកអីច្រកទេកាលពីនៅម-១៣ នោះ ។ ហើយមកដល់មន្ទីរ ស-២១ វារកថង់ផ្លាស្ទីកបាន ក៏ខ្ញុំគ្រាន់តែបង្រៀនជាគោលការណ៍អ៊ីចឹង មិនបញ្ជាថាត្រូវតែច្រកទេនេះមែន ។

រីឯចំណែកវិធីមើលអានេះ មើលអាជីពចរគល់កនេះ បើជីពចរហ្នឹងវាលោតខ្លាំង បានន័យថាមនុស្សហ្នឹងវាមានខ្លួន ។ ពាក្យខ្មែរយើងហៅថា មានខ្លួន បើពាក្យច្បាប់គេហៅថា អាហ្នឹងមានពិរុទ្ធភាពហើយ ព្រោះវាភ័យក្តុកក្តួលខ្លាំងណាស់ ។ ខ្ញុំមើលទៅមិន-- តាមពិសោធន៍របស់ខ្ញុំ ខ្ញុំមើលទៅមិនៗវិធានបែបហ្នឹងមិនមានប្រសិទ្ធភាពទេ ។ មិនត្រូវ ។

**ស៖** សូមទោស អ៊ីចឹងខ្ញុំសូមនិយាយពីសំណួររបស់ខ្ញុំម្តងទៀតឲ្យបានខ្លី ក្រៅពី វន វ៉េត តើមាននរណាគេផ្សេងដែលបានបង្រៀនខ្លួនលោកផ្ទាល់នូវវិធីនៃការសួរចម្លើយ និងធ្វើទារុណកម្មនោះ ។ ខ្ញុំមិនចង់និយាយពីប្រភេទនៃការធ្វើទារុណកម្ម ឬក៏សួរចម្លើយទេ ខ្ញុំចង់និយាយពី តើនរណាគេជាអ្នកបង្រៀនលោកឲ្យធ្វើទារុណកម្មនោះ?

**ឆ៖** អ្នកដែលបង្រៀនខ្ញុំឲ្យធ្វើទារុណកម្មគឺរបប លន់ នល់ ។ ទីមួយ អធិការអ្នកសួរចម្លើយនៅប៉េហ្ស៊ី បង្រៀន អ៊ូន៉ែ! វ៉ៃខ្មែរក្រម ។ ខ្ញុំដឹង ថ្វីត្បិតតែប៉ូលិសរបស់សម្តេច សីហនុ នៅទួលគោកគេមិនបានវ៉ៃខ្ញុំ ក៏ប៉ុន្តែអធិការ ឈិត អ៊ុំ ហើយនិង អធិការ ហំ វ៉ៃខ្មែរក្រហមគ្រប់តែគ្នាហ្នឹង ។ នេះទីមួយគឺរបប លន់ នល់ បង្រៀនខ្ញុំ ។ ទីពីរ របបបារាំងតែម្តង វាធ្វើទារុណកម្មពួកសមាជិកបក្សពលកវៀតណាម គេមានសរសេរសៀវភៅមួយ ប្រែមកជាខ្មែរថា "ពីគុកទៅកោះត្រឡាច" ប៉ុន្តែចំណងជើងគេជាភាសាបារាំង គេថា *"ដឺឡាប្រេហ្សង់ អូបាញ"* ។ អាហ្នឹងធ្វើទារុណកម្មបែបម៉េច អីម៉េចហ្នឹង ។ នេះនិយាយពីរបៀបធ្វើទារុណកម្ម វាទុកអ៊ីចងមក ។ បើយើងដឹងហើយ អាហ្នឹងគឺវាជារបស់ដែលគេបង្រៀនយើងហ្នឹង ។

សរុបមក នៅម-១៣ របៀបសួរចម្លើយ ខ្ញុំជម្រាបព្រះរាជអាជ្ញាដោយត្រង់ ចុងបញ្ចប់ដែលខ្ញុំមើលទៅបរាជ័យក្នុងការរុករកកាំភ្លើងអង្កាល់ក្នុងឆ្នាំ១៩៧៣ ដែលប៉ះពាល់ដែលអាយុជីវិតអ្នកមូលដ្ឋានបង្អែកនៅអមលាំងហាហុកសិបនាក់ ។ ខ្ញុំមានការពិបាកចិត្តណាស់ ។ ដូច្នេះ ត្រូវតែគិតគូរពីបញ្ហាសួរចម្លើយឲ្យស្រួលបួលមើល ។ ខ្ញុំយកទ្រឹស្តី ដែល ម៉ៅ សេទុង គាត់សរសេរនៅក្នុងសៀវភៅរបស់

គាត់ ។ ទ្រឹស្តីហ្នឹងជាទ្រឹស្តីរបស់ សឺន ស៊ុយ ឧកញ៉ាពីជ័យសង្គ្រាមចិនធំបំផុតហើយ ។ គាត់ថា “អ្នកឯងត្រូវស្គាល់ខ្លួនឯងឲ្យច្បាស់ ហើយស្គាល់ខ្មាំងឲ្យច្បាស់ ។ បើអ្នកឯងស្គាល់ខ្លួនឯងច្បាស់ ហើយស្គាល់ខ្មាំងច្បាស់ អ្នកឯងរ៉ៃមួយរយសមរភូមិ អ្នកឯងអត់ស្គាល់បរាជ័យមួយសមរភូមិណាទេ” ។ នេះយកអាបញ្ហានេះមកដកពិសោធន៍ ។

ដូច្នេះ ខ្ញុំរៀនដកពិសោធន៍ខ្លួនឯង ។ ក្នុងការដកពិសោធន៍ដូច្នេះហើយ ដែលខ្ញុំតែងតែនិយាយម្តងហើយម្តងទៀតថា ខ្ញុំសួរចម្លើយឈ្មោះ ង៉ែត សំបុន ហៅ រំពេ ខ្ញុំយកបានលទ្ធផលខ្លះ ដែលការពិតអាចឡើងដល់ហាសិបភាគរយ ដោយឡែកក្នុងរឿងសាច់រឿង ។ ខ្ញុំសូមបញ្ជាក់ម្តងទៀតណា ក្នុងរឿងសាច់រឿង ។ ឯចំណែកគ្រូដែលបង្រៀននោះ គេថា បាញ់ សាង ខ្ញុំថា ខ្ញុំមិនសូវជឿទេ ។ មានត្រឹមសាមសិបភាគរយ ឯចំណែកអ្នកដែលបញ្ចេញទៅជនបទហើយជំនាន់នោះ ខ្ញុំថា សូន្យភាគរយ អត់មានពិតទេ ។ ហើយមែន ។

ដូច្នេះ ការដកពិសោធន៍ក្នុងរឿងសួរចម្លើយចេះគិតគូរពិចារណាយ៉ាងម៉េច ស្អីយ៉ាងម៉េច ខ្ញុំរៀនពិសោធខ្លួនឯងៗ ។ ប៉ុន្តែ ក្មេងៗគ្មានបានធ្វើបានដូចតាមខ្ញុំទេ ។ មិត្តប៉ុន ដែលបានល្អជាងគេ ដែលខ្ញុំបង្វឹកគេទៅខាងអាបទឧក្រិដ្ឋហ្នឹង គេចេះស្ទាត់ ក៏មិនបានដូចខ្ញុំដែរ ។ ប៉ុន្តែ ខ្ញុំវាអត់មានពេលទៅសួរ ។ នេះជម្រាបដោយត្រង់ ។ អត់មានអ្នកណាបង្រៀនខ្ញុំទេ ។ អត់មានទៅរៀនពីគ្រូពីចិន ពីអាមេរិក ពីបារាំងអីមកទេ ។ ហើយអារឿងរ៉ៃ ប៉ូលិសរបស់ លន់ នល់ ហើយនិងប៉ូលិសរបស់បារាំង ។

[១៤:៣៨:១៧]

**ស៖** កាលពីព្រឹកមិញនេះ ក្នុងការឆ្លើយទៅនឹងសំណួររបស់សហសេវិករបស់ខ្ញុំ លោក តាន់ សេណារ៉ុង នោះ លោកបានរៀបរាប់អំពីឯកសារទាំងបីប្រភេទ ដែលត្រូវបានប្រើក្នុងការបណ្តុះបណ្តាលលោក នៅក្នុងប៉ុន្មានខែមុនមានស-២១ ។ ហើយឯកសារទាំងបីនោះ គឺឯកសារទាក់ទងទៅនឹងនយោបាយ មនោគមវិជ្ជា ហើយនិងភារកិច្ច ដែលផ្តល់ឲ្យ ។ នេះទៅតាមការបកប្រែ ដែលខ្ញុំទទួលបាន ។ តើលោកអាចប្រាប់បានទេ លោកអាចនិយាយអំពីប្រភេទឯកសារទាំងបីហ្នឹង គឺទាក់ទងទៅនឹងនយោបាយ ទាក់ទងទៅនឹងមនោគមវិជ្ជា ហើយនិងទាក់ទងទៅនឹងភារកិច្ចនោះ តើលោកអាចឲ្យឧទាហរណ៍ទាក់ទងទៅនឹងប្រភេទនៃឯកសារនីមួយៗបានទេ?

**ឆ៖** លោកព្រះរាជអាជ្ញាជាទីគោរព! មិនបញ្ហានេះមិនពិបាកអីនឹងជម្រាបលោកសាថ្មីឡើងវិញទេ ខ្ញុំក៏ចង់ជម្រាបដែរ ពីព្រោះរបបរៀនសូត្ររបស់កុម្មុយនីស្តវាប្លែក ។ រាល់ឆ្នាំ តាំងពីខ្ញុំចេះទៅរៀន

មក គឺចាប់តាំងពីឆ្នាំ១៩៧១ នេះខ្ញុំមិននិយាយអំពីវគ្គសម្ងាត់ ដែលខ្ញុំរៀននៅផ្ទះឈ្នួលមួយ នៅផ្លូវ១៦៣ នោះទេ ។ តាំងពីឆ្នាំ១៩៧១ មកឲ្យតែទៅរៀន ឯកសារសុទ្ធតែបីជំពូកហ្នឹង ។ ជំពូកទីមួយ ឯកសារនយោបាយ ។ ស្អីទៅឯកសារនយោបាយ? ទស្សនៈសភាពការណ៍ ឆ្នាំនេះខ្មាំងវាយ៉ាងម៉េច? យើងវាយ៉ាងម៉េច? ឧទាហរណ៍ឆ្នាំ១៩៧១ ឆ្នាំនេះខ្មាំងគឺ លន់ នល់ សម័យធ្វើរដ្ឋប្រហារបាន។ ក៏ប៉ុន្តែ ប្រជាជនមិនគាំទ្រ យើងមានតំបន់រំដោះប៉ុននេះភាគរយ យើងដណ្តើមបានព្រះនរោត្តម សីហនុ ។ បានព្រះនរោត្តម សីហនុ ជាឱកាសមាសសម្រាប់យើង ។ ហ្នឹងឯកសារនយោបាយ គឺគេនិយាយរបៀបហ្នឹង ។

ស្អីឯកសារសតិអារម្មណ៍? ឯកសារសតិអារម្មណ៍ អាម៉េចស្លូនត្លូ? យើងក្នុងឋានៈជាបក្ខជន យើងត្រូវនឿយហត់មុនមហាជន តែទទួលផលក្រោយមហាជន ។ គេណែនាំអ៊ីចឹង ។ អានេះម្យ៉ាង ។ ហើយខ្ញុំសូមនិយាយម្យ៉ាងទៀត អានេះក៏ជាឯកសារសតិអារម្មណ៍ក៏ថាបាន យុទ្ធភណ្ឌ និងជយភណ្ឌជារបស់បក្ស ។ មិត្តឯងកុំទុកថាអាហ្នឹងជារបស់ខ្លួនឯង កាំភ្លើងដែលមិត្តឯងកាន់ប្រើប្រាស់ជារបស់បក្ស បក្សត្រូវការយកទៅប្រើ បក្សមិនត្រូវការ ទុកឲ្យអ្នកកាន់កាប់ អ្នកត្រូវការ អ្នកប្រើ ។ អាហ្នឹង ជាឯកសារមួយខាងសតិអារម្មណ៍ ។

សូមនិយាយតទៅទៀត ។ កាលណាយើងទំនាស់គ្នា មានទំនាស់ជាមួយនឹងគ្នានៅក្នុងនុ៎ង យើងយកចាញ់ឈ្នះគ្នា ខុសហើយ ។ យើងឲ្យស្លូនត្លូ បើខ្លាំងជាងផលប្រយោជន៍របស់បក្ស ត្រូវតែខំសម្រួលគ្នា ទាំងអស់គ្នាស្តាប់បក្ស ហើយនាំគ្នាពួតដៃគ្នាវ៉ៃខ្មាំងជាចក្រពត្តិតទៅទៀត ។ នេះគេហៅថា ឯកសារសតិអារម្មណ៍ ។

[១៤:៤២:០១]

ឯកសារចាត់តាំងយ៉ាងម៉េច?

ឥឡូវនេះ ឆ្នាំ១៩៧៣ ចេញមាគ៌ាមួយហើយ ខ្ញុំតែងនិយាយញឹកមាគ៌ាហ្នឹង មានលក្ខណៈឧក្រិដ្ឋមែនទែន ។ មាគ៌ាវណ្ណៈណា កម្មាភិបាលវណ្ណៈនុ៎ង ។ បានន័យថា មាគ៌ាវណ្ណៈអធន ពីឆ្នាំ១៩៧៣ ទៅបក្សអនុវត្តមាគ៌ាវណ្ណៈអធន ដូច្នេះកម្មាភិបាល តែមិនមែនអធន អ្នកឯងជ្រុះហើយ ។ ដូច្នេះ អ្នកឯងពីដើមមកមិនមែនអធនក៏ដោយ ត្រូវខំៗធ្វើខ្លួនឲ្យទៅមានលក្ខណៈអធន មិនគិតគូរចង់បានបុណ្យស័ក្តិ មិនគិតគូរចង់ស្រណុកម្នាក់ឯង ប្រជាជនលំបាកវេទនា អ្នកឯងចង់ស្រណុក ។ អាហ្នឹងចាប់ផ្តើមគិតហើយ អាហ្នឹងគេហៅថាឯកសារចាត់តាំង ។ អ្នកឯងវណ្ណភាពដើមស្អីក៏ដោយ ក៏ប៉ុន្តែត្រូវរៀនឲ្យទៅជាអធន ។ បើអ្នកឯងមិនអធនទេ យើងដេញអ្នកឯងចេញ ។ នេះឯកសារចាត់តាំង ឆ្នាំណាក៏ដូចឆ្នាំណា

ដែរ ឯកសារវាមានបីប្រភេទហ្នឹង ។ ទីមួយឯកសារនយោបាយ ទីពីរឯកសារសតិអារម្មណ៍ ទីបីឯកសារចាត់តាំង ។ អត់ដែលចោលទេ រហូតដល់ថ្ងៃ៧ មករា (សូមទោស) រហូតដល់វគ្គសិក្សាឆ្នាំ ១៩៧៨ ចប់ ។ ឯកសារលែងមានហើយចាត់តាំងសតិអារម្មណ៍នយោបាយអី ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងសម្រាក ។ អង្គជំនុំជម្រះសាលាដំបូងសូមប្រកាសសម្រាកម្ភៃនាទីរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តដំណើរការសវនាការ ។

*[សវនាការសម្រាកពីម៉ោង ១៤:៤៣ នាទីដល់ម៉ោង ១៥:២០នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចពិភាក្សាដេញដោលបន្តទៅទៀត ។ ដោយអម្បាញ់មិញនេះ ដល់វេទិការបស់សហព្រះរាជអាជ្ញា ដែលមិនទាន់ចប់សំណួរ អ៊ីចឹងសូម អញ្ជើញសហព្រះរាជអាជ្ញាបន្តសំណួររបស់ខ្លួនតទៅទៀត ។ សូមអញ្ជើញ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

អរគុណលោកប្រធាន។ កាលពីសប្តាហ៍មុន ជនជាប់ចោទបានលើកឡើងអំពី សរ ភន ជាអនុជាអភិបាលរងទីក្រុងភ្នំពេញនៅសម័យ លន់ នល់ ។ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីដាក់ឯកសារនៅលើអេក្រង់បញ្ចាំង ដើម្បីឱ្យភាគីបានមើលឃើញ ។ ហើយនេះ គឺជាឯកសារដែលមាននៅក្នុងបញ្ជី ដែលខ្ញុំចែកជូនលោក លោកស្រីចៅក្រម និងភាគីកាលពីម្សិលមិញពេលព្រឹក ។

ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកចៅក្រម ធ្វើការបញ្ចាំងឯកសារនោះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមចាត់ការ ។ លោកបញ្ចាំងដោយខ្លួនឯង? ឯកសារ? សូមអញ្ជើញ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

លោក ហ្វូដ គឺគាត់អាចដោះស្រាយជាមួយបញ្ហាកុំព្យូទ័របាន ឬក៏ខ្ញុំសូមឱ្យខាងវីដេអូ ខាងរូបភាព និងសំឡេងធ្វើការប្តូរចរន្តកុំព្យូទ័រ បញ្ជូលមកកុំព្យូទ័រខាងនេះវិញ ។ ហើយឯកសារដែលខ្ញុំចង់

បង្ហាញជនជាប់ចោទនោះ ជាភាសាខ្មែរ មានលេខ ERN00227634 គឺយើងមានឯកសារជាភាសាបារាំង ដែលបានបកប្រែរួចហើយ និងភាសាអង់គ្លេសក៏បានបកប្រែរួចហើយផងដែរ ។

**ស៖** ប្រសិនបើខ្ញុំសូមឲ្យជនជាប់ចោទធ្វើការពិនិត្យឯកសារ 00227634គឺលេខERN ។ លោក កាំង ហ្កេកអ៊ាវ តើលោកអាចមើលសំណេរនេះនៅក្នុងអេក្រង់ ដែលនៅចំពោះមុខលោកបានដែរទេ? ហើយជាបឋម សូមឲ្យលោកបញ្ជាក់ថា តើបុគ្គលណាជាអ្នកសរសេរទៅលើសំណេរនេះ? សូមឲ្យលោកជនជាប់ចោទធ្វើការបញ្ជាក់?

[១៥:២៣:០៨]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម-- សូមទោសលោកព្រះរាជអាជ្ញា អក្សរនេះជាអក្សរដៃរបស់ខ្ញុំ ។

**ស៖** សូមឲ្យលោកអានទៅលើសំណេរនេះឲ្យបានយឺតៗ ថាតើលោកបានសរសេរអ្វីខ្លះនៅក្នុងកំណត់ចំណារ និងសម្គាល់មួយនេះ សូមឲ្យលោកអាន?

**ឆ៖** វត្ថុបំណងដែលយើងចង់បានគឺ ទី១ កន្លែងពិតប្រាកដរបស់វា ពាក្យទី១នេះ គឺខ្ញុំបញ្ចូលទេណា!

វត្ថុបំណងដែលយើងចង់បាន គឺកន្លែងពិតប្រាកដរបស់វា និងឈ្មោះ និងភិនភាគគ្នាវា និងផែនការវា ។ សេចក្តីសារភាពនេះ គឺវាបង្វែងដានហើយ ។ ព្រោះរៀបសរសេរ យើងកំណត់ឲ្យវាច្បាស់ណាស់ ។ ស្នើបងម្ចាស់ការ សង្កត់វាឲ្យជាប់ ទារុណកម្មជាមូលដ្ឋាន តែតាមដានសេចក្តីសារភាពវាជានិច្ច ។ តម្រង់ឲ្យជាប់ ឲ្យទាន់ពេល យ៉ាងណាកុំឲ្យងាប់ ។

**ស៖** ខ្ញុំសូមអនុញ្ញាតឲ្យលោក ហ្វូដ ទៅទំព័រមុនហ្នឹង មួយទំព័រ គឺយើងអត់មានការបកប្រែជាភាសាអង់គ្លេសនោះទេ ។ ប៉ុន្តែ ខ្ញុំសូមឲ្យជនជាប់ចោទ ធ្វើការបញ្ជាក់ថា មានលើកឡើងឈ្មោះបុគ្គលណាមួយនៅលើក្បាលទំព័រ និងមានការកត់បញ្ជាក់ទៅលើថ្ងៃខែដែរឬទេ?

**ឆ៖** ខ្ញុំជឿថា ទោះបីមិនមានបកប្រែជាអង់គ្លេស ក៏ដោយ ក៏លោកព្រះរាជអាជ្ញាជ្រាបហើយ អក្សរនៅលើក្បាលទំព័រ អក្សរ សរ ភន (សរ ភន) ហើយអក្សរដែលសរសេរហ្នឹង គឺ៩/៩/៧៥ បានន័យថា ថ្ងៃ៩ ខែកញ្ញា ១៩៧៥ ។

**ស៖** ខ្ញុំសូមឲ្យលោក ហ្វូដ ធ្វើការបញ្ចាំងទំព័រមួយទៀត ដែលយើងចង់បញ្ជាក់ជនជាប់ចោទ គឺលេខ ERN00227723 យើងឃើញមាននៅក្នុងទំព័រនេះ ចែងចេញជាពីរផ្នែក។ ជាបឋម ខ្ញុំសូមឲ្យជន

ជាប់ចោទជម្រាបយើងខ្ញុំថា សំណេរផ្ទាល់ដៃខាងលើ ផ្នែកខាងលើគឺជាសំណេររបស់អ្នកណា? នៅសំណេរនេះបានបញ្ជាំងនៅក្នុងអេក្រង់នេះ សូមឱ្យជនជាប់ចោទធ្វើការបញ្ជាក់?

**ឆ៖** អក្សរនេះ ជាអក្សរខ្ញុំ ។ អត់សំណេរទេ អក្សរខ្ញុំតែម្តង ។

**ស៖** សូមអនុញ្ញាតឱ្យជនជាប់ចោទធ្វើការអានថា លោកបានសរសេរអ្វីខ្លះនៅទីនេះ?

**ឆ៖** នេះជាសេចក្តីលម្អិត សំបុត្ររបស់-- មិនហៅសំបុត្រទេ អាហ្នឹងជាសេចក្តីដែលខ្ញុំសរសេរទៅជនរងគ្រោះកំពុងតែត្រូវសាកសួរថា--

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

សូមទោសលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ចង់មានយោបល់អីហ្នឹង?

[១៥:២៨:១៥]

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

តាងនាមឱ្យខាងការពារក្តី ខ្ញុំស្នើសុំមិនអនុញ្ញាតឱ្យធ្វើការស្នើសុំជនជាប់ចោទអានទូវអ្វីដែលសរសេរនៅក្នុងនោះ គឺគាត់ជនជាប់ចោទ អាចធ្វើការផ្តល់យោបល់ទៅលើសំណេរនោះ ដែលសរសេរយូរមកហើយ ប៉ុន្តែការឱ្យគាត់អាននៅថ្ងៃនេះ ការអានទូវអ្វីដែលគាត់បានសរសេរជាង៣០ឆ្នាំមុននោះ គឺមិនមែនជាការត្រឹមត្រូវ និងពេញចិត្តនោះទេ ហើយគាត់មិនចង់អាននោះទេ ។ ហើយប្រសិនបុគ្គលណាចង់អាន ហើយចង់បកប្រែ គឺខ្ញុំអត់មានបញ្ហា ។ ប៉ុន្តែ ខ្ញុំមានបញ្ហានៅពេលដែលស្នើសុំឱ្យគាត់អានខ្លួនគាត់ ។ ដូច្នេះហើយ គឺគាត់ផ្តល់ការចាប់អារម្មណ៍មួយចំពោះបញ្ហាដែលគាត់បានសរសេរកាលពី៣០ឆ្នាំមុន មកដល់ពេលនេះ ។

**លោក អាឡិចសាន់ឌឺ ប៊េត៖**

ខ្ញុំរីករាយក្នុងការអានទៅលើការបកប្រែ ដែលយើងបានទទួលបានពីខាងបកប្រែ គឺសហព្រះរាជអាជ្ញាយល់ឃើញថា អ្នកដែលមានការយល់ច្បាស់លាស់ទៅលើចំណុចនេះ គឺជនជាប់ចោទ ។ ហើយបើសិនជាមានបញ្ហា គឺខ្ញុំសូមអនុញ្ញាតអានជាភាសាខ្មែរ ហើយជនជាប់ចោទអាចធ្វើការកែប្រែ ប្រសិនបើខ្ញុំអានទៅលើចំណុចនេះខុស ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំសូមឲ្យ ខ្ញុំចង់ឲ្យក្រឡាបញ្ជីធ្វើការអាន ។ ហើយយើងអាចចោទសំណួរណាមួយ ដែលយើងចង់សួរទៅជនកាន់ជនជាប់ចោទ ។ ប៉ុន្តែ ខ្ញុំមិនចង់ឲ្យខាងសហព្រះរាជអាជ្ញា ឬក៏ជនជាប់ចោទធ្វើការអានដោយខ្លួនគាត់ផ្ទាល់នោះទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់លោក ហ្វ្រង់ស្វ័រ រូ គឺជាការត្រឹមត្រូវ ដែលថាតម្រូវឲ្យជនជាប់ចោទអាននូវសំណេរដែលជាឯកសាររបស់គាត់នោះ ។ ការកំណត់ថា គាត់បញ្ជាក់ត្រឹមតែឯកសារនោះ ជាឯកសារដែលសរសេរដោយខ្លួនគាត់ ជាការគ្រប់គ្រាន់ហើយ ។ ទី២ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា បញ្ហាការអានឯកសារ អង្គជំនុំជម្រះមានក្រឡាបញ្ជីសវនាការ ដែលបានត្រៀមទុកសម្រាប់ឯកសារទាំងអស់ដើម្បីគ្រប់គ្រងនូវដំណើរការសវនាការនេះ ។ អ៊ីចឹងសំណើនេះ ក៏ជាការត្រឹមត្រូវដែរ ។ អ៊ីចឹងសហព្រះរាជអាជ្ញាក្តី ភាគីដទៃទៀតក្តី បើមានការប៉ុនប៉ងអាននូវឯកសារណាមួយ សូមលើកមកសំណើនោះមកអង្គជំនុំជម្រះ អង្គជំនុំជម្រះនឹងចាត់ក្រឡាបញ្ជីអានទៅតាមអ្វីដែលជាឯកសារសម្រេចដាក់ពិភាក្សាដេញដោលនៅក្នុងសវនាការនេះ ចាប់ពីពេលនេះទៅ រហូតដល់ដំណើរការសវនាការចាប់ ។ អ៊ីចឹងគឺអាចធ្វើបាន ។

អ៊ីចឹងគឺក្រឡាបញ្ជី លោក ឌុច សុផារី អាននូវឯកសារអម្បាញ់មិញនេះ ដែលសហព្រះរាជអាជ្ញាមានបំណងចង់ស្តាប់នូវខ្លឹមសារនៃឯកសារ ដែលសរសេរដោយជនជាប់ចោទ ដែលជនជាប់ចោទបានទទួលស្គាល់រួចហើយ ។

**លោក អាឡិចសាន់ឌឺ ប៊េត៖**

សូមអភ័យទោស ដើម្បីផ្តល់ជាជំនួយទៅដល់ក្រឡាបញ្ជី យើងចង់ឲ្យក្រឡាបញ្ជីអានផ្នែកពាក់កណ្តាលខាងដើមនៅក្នុងឯកសារទាំងនោះ ។ ដូច្នេះ លោកក្រឡាបញ្ជី លោកនឹងឃើញអត្ថបទនៅក្នុងហ្នឹង គឺវាមានចំណុចមួយ ចំណុចពីរ ចំណុចបី ចំណុចបួន ហើយមានប្រយោគពីរជួរទៀត ហើយនិងដែលមានការគូសបញ្ជាក់នៅទីនោះ ហើយជួរនោះទាំងពីរនោះហើយ ដែលយើងចង់ឲ្យលោកធ្វើការអាន និងលេខទាំងអស់នោះ ។

**លោក ឌុច ផារី៖**

ចំណុចពីរ វាបានបញ្ជូនមនុស្សទៅអមលាំង វាឆ្លើយលើកមុន៤នាក់ គឺ១) នៅ មារឌី ២) ណុប

សុន ៣) ជ័យ ណារិទ្ធិ ៤) ម្នាក់ទៀតភ្លេចឈ្មោះ ។

ចំណុចបី វាថា ធ្លាប់ពាក់ព័ន្ធនឹង នួន នៅឆ្នាំ១៩៧០ ដឹកនាំសិល្បៈជាមួយគ្នានៅភ្នំពេញ ។ ក្រោយមក នួន ចេញទៅតំបន់២៥ វាអត់បានបញ្ជូនទៅទេ ។ សូមអរគុណ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

គឺខ្ញុំគិតថា លោកក្រឡាបញ្ជីអានអត្ថបទ ដែលមិនមែនជាអត្ថបទនោះទេ គឺអត្ថបទដែលខ្ញុំបានបញ្ចាំងទៅលើអេក្រង់ ហើយធ្វើយ៉ាងណាឲ្យក្រឡាបញ្ជីអានឲ្យចំទៅលើឯកសារ ។ ដូច្នេះ ខ្ញុំសូមឲ្យ ហ្វដ ធ្វើការដាក់បញ្ចូលឯកសារនោះសាជាថ្មីនៅក្នុងអេក្រង់ ។ សូមអរគុណ ។

[១៥:៣៤:០៧]

**លោក ឌុច ផារី៖**

ស្នើបញ្ជាក់ចំណុចដូចតទៅ៖

១) ទីស្នាក់ការ J K A C I មានទេ? បើមាននៅត្រង់ណា? ស្នើបញ្ជាក់ផ្លូវ លេខផ្ទះ ជាន់ ល្វែងឲ្យច្បាស់តាមដែលដឹង?

២) ជំរំនៅបឹងត្របែក ក៏ដូចនោះ បញ្ជាក់នៅត្រង់ណាឲ្យច្បាស់ តាមដែល ភន ឯងដឹង?

៣) មនុស្សប្រាំពីរនាក់ទៅក្រៅប្រទេសអស់ប៉ុន្មាន? នៅក្នុងប្រទេសប៉ុន្មាន? នរណាខ្លះ?

៤) ចំពោះមនុស្សម្នាក់ស្នើបញ្ជាក់ ឈ្មោះឪពុក ទីលំនៅឪពុកម្ដាយឲ្យច្បាស់តាមដែលដឹង ។ ចំពោះអ្នកមានប្ដី មានប្រពន្ធ ស្នើបញ្ជាក់ទីលំនៅឪពុកម្ដាយក្មេក ។

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត៖**

**ស៖** អរគុណលោកប្រធាន ហើយផ្នែកចុងក្រោយនៅក្នុងចម្លើយសារភាពរបស់ សរ ភន ដែលយើងចង់អាននោះ ។ ជាដំបូង ខ្ញុំសូមឲ្យជនជាប់ចោទធ្វើការពិនិត្យមើលទៅលើទំព័រនេះ ដែលមានលេខ 00227729 ហើយនៅក្នុងនោះគឺមានការគូសបញ្ជាក់នៅក្នុងប្រអប់ គឺសុំឲ្យជនជាប់ចោទបញ្ជាក់ថា តើអក្សរនេះជាអក្សររបស់នរណា?

**ឆ៖** អក្សរនេះមិនជាអក្សរខ្ញុំទេ អាចអក្សរបង ម៉ម ណៃ ។

**ស៖** អរគុណ ។ ខ្ញុំសូមឲ្យលោកធ្វើការពិនិត្យទៅលើប្រអប់ខាងក្រោម ដែលខ្ញុំគូសបញ្ជាក់នៅខាងក្រោមនេះ ក្នុងទំព័រដូចគ្នានេះដែរ ហើយសូមលោកឲ្យធ្វើការកត់សម្គាល់បញ្ជាក់អក្សរនេះសាជាថ្មី ថាតើជាអក្សររបស់នរណាគេ?

**ឆ៖** ខ្ញុំក៏នៅតែយល់ថា នេះជាអក្សរ បង ម៉ម ណៃ ដដែល ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

អរគុណ ។ ដូច្នេះ លោកក្រឡាបញ្ជី សូមឲ្យលោកអានអក្សរនៅក្នុងប្រអប់ទាំងពីរនោះ ដែលចាប់ផ្ដើមពីប្រអប់ដំបូងនៅខាងលើ ។ ហើយជាថ្មីម្ដងទៀត សូមឲ្យលោកធ្វើការអានទៅលើផ្នែកដែលមានការគូសពណ៌ខៀវ ។ សូមឲ្យលោកក្រឡាបញ្ជីធ្វើការអាន ។

**លោក ឌុច ផារី៖**

ជាអក្សរកាត់គឺ ទ.ទ និង ចាប់ ណាងិន *ស៊ីអាយអេ* តាមរយៈ អាងិន ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

អរគុណលោកក្រឡាបញ្ជី សូមឲ្យលោកក្រឡាបញ្ជីអានទៅលើចំណារនៅក្នុងប្រអប់ខាងក្រោមនេះទៀត ។

**លោក ឌុច ផារី៖**

សកម្មភាពឲ្យក្មេងទៅ *យូអេសអេ* ដើម្បីរៀងធ្វើ *ស៊ីអាយអេ* ។

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត៖**

**ស៖** សំណួររបស់ខ្ញុំចង់សួរទៅកាន់ជនជាប់ចោទ គឺពាក់ព័ន្ធទៅនឹងថ្ងៃខែ នៅក្នុងឯកសារមួយនេះ គឺយើងបានឃើញរួចហើយនៅក្នុងទំព័រទី១ គឺថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៥ តើជនជាប់ចោទអាចបញ្ជាក់ដែរឬទេ? ថាលោកនៅទីនោះជាមួយនឹងសហសេវិក និងបុគ្គលិកក្រោមបង្គាប់របស់ ហើយធ្វើការសួរចម្លើយលោក សរ ផន រួមទាំងធ្វើចំណារនៅក្នុងឯកសារនេះផង ។

[១៥:៣៩:៤២]

**ឆ៖** លោកព្រះរាជអាជ្ញា ខ្ញុំសង្ឃឹមថាលោកបានអានឯកសារ សរ ភន នេះ ហូរហែគ្រប់ទំព័រ ហើយបានពិចារណាច្បាស់លាស់ ក៏ប៉ុន្តែខ្ញុំសូមនិយាយបញ្ជាក់បន្ថែមមួយម៉ាត់ ប្រហែលជាលោកអាចយល់បន្ថែមពីករណី សរ ភន នេះបាន ។ ឆ្នាំ១៩៧៣ ឬក៏៧៤ ខ្ញុំភ្លេចទៅហើយ មិនច្បាស់ទេ ឈ្មោះ សរ ភន នេះ មិនមែនជាអភិបាលរងក្រុងភ្នំពេញទាំងមូលទេ ជាអភិបាលរងខណ្ឌដូនភ្នំពេញ សរ ភន នេះជាអភិបាលរងខណ្ឌដូនពេញ ។ បានបញ្ជូនក្មេងម្នាក់ទៅអមលាំង កូនចៅអ្នកអមលាំង ឈ្មោះ នៅ មារឌី ។ ក្នុងសេចក្ដីសារភាពដែលបង ម៉ម ណៃ គាត់កត់ត្រានេះមាន ឈ្មោះ នៅ មារឌី ។ នៅពេលដែលខាងភូមិភាគនិរតីគេចាប់ នៅ មារឌី ប្រគល់មកឲ្យម-១៣ ខ្ញុំឲ្យមិត្ត ប៉ុន សួរចម្លើយ ខ្ញុំក៏បានត្រួត

ពិនិត្យចម្លើយនោះហូរហែប្រចាំថ្ងៃរបស់ខ្ញុំដែរ ។ វាចម្លើយថា សរ ភន អភិបាលរងខណ្ឌដូនពេញបញ្ជូនវាឲ្យមកធ្វើការនៅជនបទ ពីព្រោះវាមានបងប្អូននៅអមលាំង ។

**ស៖** លោកប្រធាន សហព្រះរាជអាជ្ញាបានលើកឡើង ខ្ញុំមិនមែនបញ្ឈប់ជនជាប់ចោទមិនឲ្យលើកឡើងទៅលើករណីនេះទេ ។ សំណួររបស់ខ្ញុំគឺសាមញ្ញ ។ ថាតើគាត់មានពាក់ព័ន្ធជាមួយនឹងបុគ្គលិកក្រោមបង្គាប់របស់លោកក្នុងការសួរចម្លើយដែរឬទេ លើកលែងតែអង្គសវនាការមានការចាប់អារម្មណ៍ឲ្យធ្វើការដេញដោលទៅលើអត្ថបទ ។ ប៉ុន្តែនៅពេលនេះ គឺខ្ញុំចង់សួរបញ្ជាក់ថា គាត់មានពាក់ព័ន្ធជាមួយនឹងបុគ្គលិកក្រោមបង្គាប់របស់គាត់ ក្នុងការធ្វើចំណារនឹងសួរចម្លើយដែរឬទេ? ហើយខ្ញុំគឺមិនមានការចាប់អារម្មណ៍ក្នុងការឲ្យពិភាក្សាដេញដោល ទៅលើខ្លឹមសាររួមទាំងអស់នៃឯកសារនោះទេ ។

[១៥:៤២:៣២]

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទស្តាប់សំណួរបានទេ? ហើយបើស្តាប់បាន សូមអញ្ជើញឆ្លើយ បើស្តាប់មិនបានអាចសួរបញ្ជាក់ម្តង ដើម្បីសហព្រះរាជអាជ្ញាតាំងសំណួរសាជាថ្មី ។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំស្តាប់បាន ក៏ប៉ុន្តែគោលបំណងខ្ញុំចង់ឲ្យយល់បញ្ហារួម ហើយសឹមចូលមកដល់សំណួររបស់ព្រះរាជអាជ្ញា ដើម្បីយល់ទាំងអស់គ្នា អ្នកស្តាប់នៅក្នុងសវនាការនេះ ។ តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំធ្វើអីចឹង ឬយ៉ាងម៉េច? ឬឲ្យឆ្លើយចំមួយម៉ាត់ទៅនឹងសំណួរព្រះរាជអាជ្ញា?

**ប្រធានអង្គជំនុំ៖**

សូមឲ្យឆ្លើយចំនឹងសំណួរតែម្តងទៅ ។

**ជនជាប់ចោទ៖**

**ឆ៖** នៅពេលដែលមកដល់ភ្លាមហ្នឹង ថ្ងៃ១ ខែ៩ ៧៥ ហ្នឹង សរ ភន មកជាប់គុកនៅវីឡាស្តេចក្រុមព្រះមុន្នីរ៉េត រួចទៅហើយ ។ មេលោកគ្រូ សុន សេន ចង់ឲ្យសួរចម្លើយ ប៉ុន្តែ ខ្ញុំអត់មានពេលទៅសួរ រវល់តែដើរប្រមូលអាឯកសារហ្នឹង ហើយរៀបចំឯកសារតាមផ្ទះហ្នឹង ។ ដូច្នេះ ណាត ហ្នឹង គាត់ពេញចិត្តនិង ម៉ម ណៃ យកបង ម៉ម ណៃ មកប្រើសួរចម្លើយ សរ ភន ហើយខ្ញុំមកពិនិត្យណែនាំការសួរចម្លើយនេះទៀត ។

ដូច្នេះខ្ញុំ ហើយនិងបង ម៉ម ណៃ គឺពិតជាខ្ញុំជាអ្នកបញ្ជា ។ ហើយឯកសារនេះ បង ម៉ម ណៃ

អ្នកសួរ នៅពេលដែលស-២១ មិនទាន់កើតជារូបរាងនៅឡើយទេ ។ ណាត ខ្ចីបង ម៉ម ណៃ យកមកប្រើ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណ ដូច្នេះខ្ញុំអាចធ្វើការចូលទៅដល់ឯកសារមួយទៀត ដែលបានយើងបានដាក់ជូនអង្គសវនាការទាក់ទងនៅនឹង អ៊ុំ សឿន ។ ដូច្នេះហើយ សូមឲ្យខាងរូបភាព និងសំឡេងធ្វើការប្តូរចរន្តកុំព្យូទ័រ ហើយសុំអភ័យទោសលោកប្រធាន គឺខ្ញុំអម្បាញ់មិញ មិនបានធ្វើសុំការអនុញ្ញាតពីលោកប្រធាន ដូច្នេះ តើខ្ញុំសុំការអនុញ្ញាតពីលោកប្រធានបានទេ ឲ្យធ្វើការបញ្ចាំងទៅលើឯកសារមួយទៀត?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត តាមការស្នើសុំ ។ សូមអញ្ជើញ ។

[១៥:៤៥:០៨]

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត៖**

ដូច្នេះ ខ្ញុំសូមអនុញ្ញាតខាងរូបភាព និងសំឡេងធ្វើការប្តូរមុខខាងកុំព្យូទ័ររបស់លោក ហ្វង នៅខាងស្តាំដៃខ្ញុំ ដើម្បីឲ្យយើងអាចបញ្ចាំងទៅលើឯកសារនោះ ។

ដូច្នេះ សូមឲ្យយើងមើលនៅក្នុងលេខ ERN ជាភាសាខ្មែរគឺ ឯកសារថតចម្លងនូវឯកសារដើមគឺលេខ ERN00172779 ។

**ស៖** សំណួរដំបូងរបស់ខ្ញុំជូនជនជាប់ចោទ ថាតើជនជាប់ចោទអាចមើលឃើញចំណាររជាពណ៌ក្រហមនេះដែរ ឬទេ? សូមលោកអាចបញ្ជាក់ថាជាចំណាររបស់នរណាគេ?

**ឆ៖** របស់ខ្ញុំ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ហើយខ្ញុំសូមឲ្យលោកក្រឡាបញ្ជីធ្វើការអានចំណារជាពណ៌-- ដែលមានពណ៌ក្រហមនេះ ។

**ប្រធានអង្គជំនុំ៖**

លោក ឌុច ផារី, អញ្ជើញ ។

**លោក ឌុច ផារី៖**

មិនទាន់សារភាពទេ ទារុណកម្ម ។

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណ ហើយយើងពិនិត្យមើលទៅលើដំណកស្រង់ចេញពីចម្លើយសារភាពរបស់លោក អ៊ុំ សឿន ដែលមានលេខ ERN00172779 ហើយវាមានលក្ខណៈពិបាកក្នុងការមើលអ្វីដែលមានការគូរបញ្ជាក់ពណ៌នៅទីនេះ ។

**ស៖** សូមឱ្យជនជាប់ចោទធ្វើការបញ្ជាក់ថា តើលោកស្គាល់ទៅលើចំណារ និងអក្សរនេះដែរឬទេ?

**ឆ៖** ស្គាល់ អក្សរខ្ញុំ ។

[១៥:៤៧:៣១]

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ហើយសូមអនុញ្ញាតឱ្យលោកក្រឡាបញ្ជី ធ្វើការអានទៅលើអ្វីដែលរៀបរាប់នៅក្នុងចំណារនេះ ប្រសិនជាលោកមិនទំនាស់ទៅនឹងសំណើនេះ ។

**ប្រធានអង្គជំនុំ៖**

លោក ឌុច ផារី អញ្ជើញឡើងអាន ។

**លោក ឌុច ផារី៖**

ប្រហែលជាឈ្មោះ មាស តេង ទេ ។ បើឈ្មោះ មាស តេង មែន សូមសមមិត្ត ឆយ ក្រោមការដឹកនាំរបស់ "ប" វាយឱ្យបែកមុខហើយ បញ្ជាក់ចំពោះបញ្ហានារីនេះ ដូចពួក អោម សែម ដែរ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

លោកប្រធានដើម្បីជាកំណត់ត្រា គឺយើងនឹងអានសំណេរជាភាសាអង់គ្លេស ប្រហែលជាឈ្មោះ មាស ថេង-- មាស តេង គឺឋិតនៅក្រោមការដឹកនាំរបស់ មាស សេង វាយឱ្យចំមុខ-- វាយឱ្យបែកមុខ បញ្ជាក់ចំពោះបញ្ហានារីនោះ ដូចពួក អោម សែម ដែរ ។

ដូច្នេះហើយ គឺខ្ញុំអាននេះដើម្បីជាកំណត់ត្រានៅក្នុងកំណត់ហេតុសវនាការ ។ ហើយផ្នែកមួយទៀតនៅក្នុងចម្លើយសារភាពរបស់លោក អ៊ុំ សឿន គឺមានលេខ ERN00172800 ។

**ស៖** ហើយជាថ្មីម្តងទៀត សូមឱ្យជនជាប់ចោទ ថាតើជនជាប់ចោទអាចមើលចំណារនៅក្នុងនេះចំនួនបី តើលោកជនជាប់ចោទអាចបញ្ជាក់ថា ជាចំណាររបស់នរណាគេ?

**ឆ៖** ចំណារទាំងបីនេះ ជារបស់ខ្ញុំ ។

**ស៖** ហើយជាថ្មីម្តងទៀត សុំការអនុញ្ញាតពីក្រឡាបញ្ជីអានជាភាសាខ្មែរ ប្រសិនបើមិនអាចទេ យើងនឹងអានឯកសារនេះភាសាអង់គ្លេស និងបារាំង ហើយសុំឲ្យការអនុញ្ញាតថា តើលោកក្រឡាបញ្ជីអាចធ្វើការអានចំណារទាំងបីនេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ឌុច ផារី អានឲ្យបានច្បាស់ ។

**លោក ឌុច ផារី៖**

សូមបញ្ជាក់ឲ្យច្បាស់ដើម្បីស្តាប់ជំហរស្គាល់សកម្មភាព លើកសំណូមពរជាវិធានការខាងចាត់តាំង ។ គ្រូអានេះ បើវាមិនស្គាល់នាមត្រកូលទេ សូមសួរភិនភាគទាំងគ្រូ អៀង តាំង, ជាប៊ាង ទាំងអ៊ុក យើង ត្រូវសង្កត់ឲ្យល្អិត ។

[១៥:៥១:៥៧]

**ប្រធានអង្គជំនុំ៖**

លោក ហ្សង់ម៉ាក តើលោកមានលើកឡើងអំពីបញ្ហាអ្វីទៅ? សូមអញ្ជើញលោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំចង់ចោទសួរដើម្បីធ្វើការកត់ត្រានៅក្នុងកំណត់ហេតុ នឹងចង់ឲ្យធ្វើការបំភ្លឺ ហើយគឺមានការបកប្រែនៅក្នុងភាសាបារាំង ហើយនិងអង់គ្លេស ។ ដូច្នេះហើយខ្ញុំសូមឲ្យមានការអានទៅលើលេខ ERN ជាភាសាបារាំង និងអង់គ្លេស ។ ចំពោះ អ៊ុំ សួន លេខ ERN ជាភាសាអង់គ្លេស គឺ 00223147 ហើយនិង 00234676 ហើយក្នុងភាសាបារាំងលេខ ERN គឺ 00296037 ដល់លេខ 00296038 ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធានជាទីគោរព! ខ្ញុំកត់សម្គាល់ឃើញថា ការបកប្រែដែលយើងទទួលបានជាភាសាបារាំង គឺវាខុសពីការបកប្រែដែលយើងស្តាប់នៅក្នុងសវនាការនេះ ។ ដូច្នេះ ខ្ញុំចង់ដឹងថា តើបុគ្គលណាគាត់បានបកប្រែឯកសារនេះ? ប្រហែលជាខាងសហព្រះរាជអាជ្ញាអាចធ្វើការបញ្ជាក់បំភ្លឺទៅលើករណីនេះ ហើយខ្ញុំហាក់ដូចជា វាការបកប្រែនេះហាក់ដូចជាខុសគ្នាទៅនឹងអ្វីដែលយើងបានស្តាប់ពីការលើក

ឡើងនៅក្នុងសវនាការនេះ ។

[១៥:៥៤:០៨]

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាអាចឆ្លើយតបនឹងសំណើរបស់មេធាវីការពារក្ដីបានទេ?

**លោក អាឡិចសាន់ឌឺ បេ៊ត៖**

ខាងមេធាវីការពារក្ដី គឺត្រូវដឹងថា ការបកប្រែនេះធ្វើឡើងដោយខាងការិយាល័យរបស់សហ-ព្រះរាជអាជ្ញា ហើយប្រសិនបើមេធាវីមានការពិបាកក្នុងការយល់ទៅលើបញ្ហាបកប្រែ គឺគាត់ត្រូវលើកបញ្ហាចោទហ្នឹងឡើង ហើយនៅខាងយើងគឺយើងមានអ្នកបកប្រែជាភាសាខ្មែរ ហើយជាបញ្ហានេះ គឺថាយើងបកប្រែចេញពីភាសាខ្មែរ ហើយនៅក្នុងការស្ដាប់ចេញពី*កាស* របស់យើង គឺវាមិនដូចទៅនឹងអត្ថន័យជាភាសាអង់គ្លេសនៅក្នុងឯកសាររបស់យើង ហើយជាពិសេសនៅក្នុងឃ្លាចុងក្រោយ ដែលគ្រូអៀ, ជ័យ ហាន និង អ៊ុក យ៉េង ត្រូវតែកម្ទេចឲ្យហ្មត់ ។ ប្រសិនបើមានការពិបាកចំពោះការបកប្រែនោះ ឬក៏មានបញ្ហាខ្វែងជំទាស់ណាមួយនៅក្នុងការបកប្រែ គឺខាងសហមេធាវីការពារក្ដីគឺគាត់តែលើក បញ្ហានេះ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តទៀត បញ្ហាការបកប្រែយើងគិតថា អាចមានបញ្ហាខ្លះមែនហើយ ប៉ុន្ដែ ដូចជាបញ្ហាលម្អៀងគ្នានេះ ដូចជាមិនច្រើនទេ ។ អាចបញ្ហាកើតមកពីការអាននូវអក្សរដែលសរសេរយូរហើយ ហើយមិនមែនអក្សររបស់ខ្លួនទៀត អ៊ីចឹងការអានរបស់ក្រឡាបញ្ជីសវនាការក៏អានមិនត្រូវដែរ នែ៎មិនត្រូវដែរ ។ អ៊ីចឹងវាអាច បញ្ជាក់សាជាថ្មីម្ដងទៀត សូមក្រឡាបញ្ជីអានឲ្យបានច្បាស់លាស់ទៅតាមអក្សរហ្នឹង ហើយអាចជំនួយដោយក្រឡាបញ្ជី សែ កុលវុឌ្ឍី ដើម្បីជួយឲ្យការអានអក្សរហ្នឹងត្រឹមត្រូវ បានត្រឹមត្រូវ ។ ហើយក្នុងករណីចាំបាច់ គឺអាចក្រឡាបញ្ជីអង្គុយអានក៏បានដែរ តាមយើងពិនិត្យមើល ពេលដែលឈរអានទៅនៃទីតាំងហ្នឹង វាអាចមើលមិនចំពីមុខនៃអក្សរនៅក្នុងអេក្រង់ទូរទស្សន៍ទេ ។ នេះអាចជាកត់សម្គាល់មួយ ។ អ៊ីចឹង យើងតទៅទៀតដែលអាចនឹងទទួលលទ្ធផលល្អជាងមុន ។

សូមអញ្ជើញសហព្រះរាជអាជ្ញា ។

អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

អរគុណលោកប្រធាន ។ ខ្ញុំសូមអភ័យទោស ដែលខ្ញុំបានកាត់សម្តីនេះទៀត។ បញ្ហារបស់ខ្ញុំគឺវាទាក់ទងទៅនឹងខ្លឹមសារ។ ខ្ញុំយល់ថាឯកសារនេះត្រូវបានបកប្រែដោយការិយាល័យសហព្រះរាជអាជ្ញា។ ប៉ុន្តែ អ្វីដែលខ្ញុំយល់មិនខុសនោះទេ ឯកសារទាំងអស់នេះ គឺចេញមកពីការិយាល័យរបស់សហចៅក្រមស៊ើបអង្កេត ដូច្នេះឯកសារនេះ គឺមិនមែនបកប្រែដោយខាងការិយាល័យរបស់សហព្រះរាជអាជ្ញានោះទេ ។

ជាថ្មីម្តងទៀត ហើយគឺភាគីរបស់សវនាការនេះ គឺមិនមានការជំទាស់ ហើយចម្លើយទាំងអស់នេះវាមានបញ្ហា ។ ប៉ុន្តែឯកសារនេះ តើបកប្រែខាងការិយាល័យរបស់សហព្រះរាជអាជ្ញា ឬក៏យ៉ាងម៉េច? ហើយបកប្រែដោយនរណាគេ? ហើយបកប្រែនៅផ្ទៃក្នុង ឬក៏បញ្ជូនចេញទៅបកខាងក្រៅ? យើងដឹងថា ឯកសារនេះគឺបានបញ្ជូនទៅខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីបកប្រែហើយយើងអាចយល់ថា បញ្ហានេះព្រួយបារម្ភធ្វើឲ្យការិយាល័យខាងមេធាវីការពារក្តីយល់ច្រឡំ ។ ហើយប្រសិនបើឯកសារនេះចេញមកពីការិយាល័យរបស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត គឺយើងអត់ដឹងទៅលើបញ្ហានេះ ។ ប៉ុន្តែ បើសិនជាទាក់ទងទៅនឹងការបកប្រែពីខាងការិយាល័យរបស់សហព្រះរាជអាជ្ញា គឺយើងអត់ដឹងទៅលើបញ្ហានេះ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

លោកប្រធាន, យើងកំពុងតែដោះស្រាយមិនចំទៅលើបញ្ហានេះទេ ហើយនៅព្រឹកថ្ងៃនេះ មេធាវីការពារក្តីតាមរយៈជនជាប់ចោទបានលើកឯកសារដែលមិនបានបកប្រែ ។ ហើយគាត់ស្នើសុំឲ្យធ្វើការផ្អែកទៅលើឯកសារហ្នឹង ហើយសុំដាក់ជូនអង្គសវនាការ ។ ហើយៗឯកសារនោះ គឺបកប្រែតាមរយៈផ្ទាល់មាត់ដោយក្រុមបកប្រែនៅក្នុងសវនាការនេះ ថាតើវាបានស្នើសុំយ៉ាងម៉េច? ចំពោះឯកសាររបស់សហព្រះរាជអាជ្ញានោះ លើកលែងតែយើងអាចធ្វើការលើកឡើងអំពីឯកសារដែលយើងបានដាក់នៅទីនេះ ។ ខាងសហមេធាវីការពារក្តីមានការយល់ខុសនៅពេលដែលលើកសម្តីដូច្នេះ ។

យើងមានបំណងក្នុងការដាក់ជូនឯកសារនៅមុខអង្គសវនាការ ហើយយើងធ្វើដូច្នេះដើម្បីផ្តល់ជាជំនួយទៅដល់អង្គសវនាការ ហើយផ្តល់ឯកសារនេះជាបីភាសា ។ ដូច្នេះ ខ្ញុំគិតថា វាមិនមែនជាបញ្ហាចោទនៅទីនេះទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមឱ្យមានការបំភ្លឺបញ្ជាក់ ចំពោះអ្វីដែលសហព្រះរាជអាជ្ញាចង់ធ្វើការបង្ហាញ គឺមានការលើកឡើងថា មានចម្លើយសារភាព ដែលមានការបញ្ជាក់អំពីថ្ងៃបរិច្ឆេទ និងមានចំណាររបស់ជនជាប់ចោទ ឬក៏យើងចង់បញ្ជាក់អំពីខ្លឹមសារចំពោះចម្លើយសារភាពនេះ ឬយ៉ាងម៉េច? ខ្ញុំចង់ឱ្យមានការបំភ្លឺទៅលើបញ្ហានេះ ។ ប្រសិនបើយើងនិយាយអំពីការអាទិភាពនៃចំណារនេះ គឺវាមិនជាករណីទេ ប៉ុន្តែ ខ្ញុំចង់ឱ្យមានការបំភ្លឺច្បាស់លាស់ទៅលើករណីលើកឡើងនៅទីនេះ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកចៅក្រម សហព្រះរាជអាជ្ញាបានលើកឡើងមិនមែនតែចង់បង្ហាញថា ឌុច នៅពេលនោះបានបញ្ជា ធ្វើការចារទៅលើឯកសារនោះទេ ។ ដូចដែលយើងបានអាន គឺគាត់បានបញ្ជាឱ្យមានការធ្វើទារុណកម្ម ហើយគាត់បញ្ជាឱ្យមានការកម្ទេចខ្មាំង ។ ហើយនៅក្នុងដំណាក់កាលផ្តល់អង្គហេតុទៅលើស-២១ គឺមានចំណុចពីរយ៉ាង៖ ទី១ គឺគាត់នៅទីនោះ ហើយគាត់បានធ្វើចំណារ ។ ហើយទីពីរ ចំណារនោះបានបញ្ជាក់អំពីតួនាទីរបស់គាត់ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

អរគុណចំពោះសហព្រះរាជអាជ្ញា ដែលបានឆ្លើយតបទៅលើករណីនេះ ។ ជាការពិត គឺវាបានបញ្ជាក់ចំពោះយោបល់របស់ខ្ញុំ សហព្រះរាជអាជ្ញា គឺបានបញ្ជាក់ថា គាត់ចង់បង្ហាញជនជាប់ចោទថាមានការនិយាយអំពីការកម្ទេច ។ ហើយការបកប្រែ គឺផ្តល់ដោយខាងការិយាល័យរបស់សហព្រះរាជអាជ្ញា ហើយមុននឹង គឺនៅពេលដែលក្រឡាបញ្ជីបានអានអត្ថបទដូចគ្នានោះ គឺក្រឡាបញ្ជីបានលើកឡើងថា យើងត្រូវតែដេញតាមរហូតដល់ចុងក្រោយ ។ ដូច្នេះ ហើយគឺវាមិនមែនអ្វីដែលយើងយល់នោះទេ ប៉ុន្តែ ខ្ញុំសូមបន្ថែមនៅទីនេះ បន្ទាប់ពីសំណួររបស់លោកចៅក្រម ឡាវែន៍ គឺយើងមានចម្លើយសារភាពច្រើនដែលចំណារដោយជនជាប់ចោទ ។ ហើយប្រសិនបើសហព្រះរាជអាជ្ញាធ្វើការបញ្ជាក់អំពីចំណារនោះ គឺយើងនឹងចំណាយពេលរហូតទៅដល់បីខែទៅលើបញ្ហាហ្នឹង ។ គឺជនជាប់ចោទបានបញ្ជាក់

ហើយថា គាត់បានចារទៅលើចំណារសារភាពនេះ ហើយគាត់បានធ្វើការសុំទោសទៅលើជនរងគ្រោះចំពោះហេតុផលមួយចំនួនលើករណីនេះ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ជាថ្មីម្តងទៀត លោកប្រធាន, សហព្រះរាជអាជ្ញាមានភារកិច្ច ដើម្បីបង្ហាញនូវក្នុងសំណុំរឿងនេះ គឺដាក់បន្ទុកទៅលើជនជាប់ចោទ ។ យើងមិនមានគោលបំណងក្នុងការពិនិត្យមើលរាល់គ្រប់ចម្លើយសារភាពដែលមានចំណាររបស់ជនជាប់ចោទនោះទេ ។ ប៉ុន្តែ នៅដំណាក់កាលដំបូងនេះ នៅពេលដែលយើងធ្វើការវិភាគអំពីបញ្ហាលើការបង្កើតស-២១ ហើយចម្លើយសារភាពនេះច្បាស់ណាស់បង្ហាញអំពីពេលវេលានៃការបង្កើតនោះ គឺមានន័យថា ពីខែសីហា កញ្ញា តុលា ឆ្នាំ៧៥ ។ ហើយនេះគឺជាគោលបំណងរបស់សហព្រះរាជអាជ្ញាដើម្បីលើកបង្ហាញនូវឯកសារនេះដើម្បីធ្វើការបញ្ជាក់ពីជនជាប់ចោទ ដើម្បីជាការបង្ហាញថា បាទ,ពិតណាស់នៅពេលចាប់ផ្តើមដំបូងនោះ នេះគឺជាអ្វីដែលគាត់ចាប់ផ្តើមបានធ្វើដែរ ហើយដែលមានការអនុញ្ញាតពីលោកប្រធាននោះ ខ្ញុំនឹងចូលដល់ចំណុចមួយថ្មីទៀត ។

នេះជាចម្លើយសារភាពមួយទៀត ទាក់ទងនឹងដំណាក់កាលពេលនោះ ដែលខ្ញុំចង់បង្ហាញនៅចំពោះមុខអង្គសវនាការ ដែលមានការអនុញ្ញាតពីលោកប្រធាន ។ ខ្ញុំចង់លើកឡើងមួយទៀតទាក់ទងទៅនឹងចម្លើយសារភាពរបស់ ប៊ុន ណារ៉ាក់ ។ បាទ, សូមឱ្យផ្នែកសោតទស្សន៍ហ្នឹង បង្ហាញនៅលើអេក្រង់ បើយកចេញពីកុំព្យូទ័ររបស់លោក ហ្វូដ ។

**ស៖** សូមអរគុណ ។ នេះគឺជាចម្លើយសារភាពរបស់ ប៊ុន ណារ៉ាក់ ខ្ញុំសូមឱ្យជនជាប់ចោទពិនិត្យមើលលេខ 00220800 (សូមទោស) គឺលេខ 002268-80 ។ សូមឱ្យជនជាប់ចោទពិនិត្យមើលចំណារនេះ ហើយធ្វើការបញ្ជាក់ថា តើចំណារនេះជាចំណាររបស់អ្នកណាគេ?

**ឆ៖** អក្សរខ្ញុំ ។

[១៦:០៨:២៦]

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

គឺថាយើងមានការដាក់នូវការបកប្រែជាភាសាអង់គ្លេសនៅក្នុងសំណុំរឿង ទាក់ទងទៅនឹងចំណុចមួយនេះ ហើយខ្ញុំសូមស្នើឱ្យក្រឡាបញ្ជីអាន 008191 ភាសាបារាំង 0029491 ហើយសូមលោកក្រឡាបញ្ជីសូមអានចំណុចដែលមានលេខរ៉ូម៉ាំងទីបួនចុះមក ។ គឺនៅទំព័រ 00226270 ដែលមាននៅក្នុងប្រអប់ពណ៌ក្រហមនេះ ។

**ប្រធានអង្គជំនុំ៖**

សែ កុលវុឌ្ឍី អាននូវឯកសារនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

ចំណុច៤ សំណូមពរ៖

១) ស្នើចាប់ឈ្មោះ ចាន់ សំអឿន អតីតលេខាធិការធនាគារជាតិ សមាជិកគណបក្សប្រជាធិបតេយ្យសព្វថ្ងៃនៅខ្សុំ ឃុំបន្ទាយដែក ស្រុក១៦ ។

២) ស្នើតាមដាន ហ៊ុល ហ៊្សូរ និង លឹម សារ៉ុម ដែលជាឈ្មោះ ប៊ុន ណាវ៉ាក់ បានចាត់តាំង និងតាមដាន់ឈ្មោះ វួន ប៉ាង ប្រពន្ធឈ្មោះ ប៊ុន នុនណារី ដែលត្រូវជាបងថ្លៃ បងបង្កើតរបស់សាមីខ្លួនអ្នកសារភាព ដែលធ្លាប់ធ្វើមេព្រៃ ហើយបច្ចុប្បន្ននៅភូមិលេខ២ ឃុំដីឥដ្ឋ ស្រុក១៦ ។

៣) ស្នើម-១៥ ជួយល្បើចរកសមាជិកគណៈប្រជាធិបតេយ្យផ្សេងទៀតដែលសកម្មប្តូរប្តេជ្ញាប្រឆាំងយើង ។ ថ្ងៃទី២៧ ខែ១០ ឆ្នាំ១៩៧៥ ។

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត៖**

**ស៖** សំណួរសម្រាប់ជនជាចោទ ។ សូមអរគុណនូវក្រឡាបញ្ជីដែលអាន ។

នៅចំណុចទីបី នៅក្នុងសំណើដែលបានអានអម្បាញ់មិញនេះ ។ តើកាលពីខែតុលា ឆ្នាំ៧៥នុ៎ងគឺនៅដំណាក់កាលដំបូងនៃការបង្កើតស-២១ តើលោកមានអំណាចស្នើអង្គភាពផ្សេងៗឲ្យធ្វើការល្បើចរកសមាជិកផ្សេង ឬក៏ធាតុផ្សំដទៃទៀត សមាសភាពដទៃទៀតឬ?

**ឆ៖** សូមគោរពលោកប្រធាន! ឯកសារដែលអានទាំងប៉ុន្មាន ខ្ញុំសូមសរុបខ្លីជូនអង្គសវនាការនៅពេលនេះ ។ ទីមួយ សូមបញ្ជាក់ថា ខ្ញុំចូលរួមសកម្មភាពក្នុងស-២១ ប្រហែលជាក្នុងខែ១០ ពិតមែន ។ ឯចំណែករឿង សរ ភន ខ្ញុំចង់បញ្ជាក់វែងបន្តិចពីលើកមុននោះ ប៉ុន្តែឥឡូវ វាយល់ទាំងអស់គ្នាហើយ ។ ខ្ញុំគ្រាន់តែសូមបញ្ជាក់ថា ខ្ញុំមានចារទៅមែន តាមសំណូមពររបស់ ណាត ដែលឲ្យខ្ញុំចារលើឯកសារបង ម៉ម ណៃ ។ ក្នុងរយៈកាលនេះ យើងខ្ញុំមិនទាន់ចូលស៊ប់ទៅក្នុងស-២១ ដែលមានការចាប់គ្នារវាងខ្ញុំនិង ណាត ទេ ។

[១៦:១២:៤៦]

ឯចំណែក ឯកសារដែលលោកក្រឡាបញ្ជី លោកអានមិញហ្នឹងថា “កម្ទេច” ហ្នឹង គ្មានពាក្យ “កម្ទេច” ទេ ជាអក្សរខ្មែរចំណារខ្ញុំ ។ សូមបញ្ជាក់ថាឯកសារនេះ ខ្ញុំមានសរសេរនៅថ្ងៃ២៧ ខែ១០ ឆ្នាំ

១៩៧៥ សូមបញ្ជាក់ថា ខ្ញុំបញ្ជាក់ថា ពេលនោះជាអនុប្រធាន ។ ខ្ញុំជាអនុប្រធាន ។ ដូច្នេះ ប្រធានគេឲ្យសរសេរខ្លឹមសារគេដាក់ចេញមក ខ្ញុំសរសេរហើយ ។ ទីមួយ ស្នើចាប់ឈ្មោះ ចាន់ សំអឿន នៅឃុំបន្ទាយដែកបច្ចុប្បន្ននេះ មិនមែនស្រុក១៦ទេ ស្រុកបន្ទាយដែក ។ ហើយទីបីនេះ ស្នើម-១៥ សូមបញ្ជាក់ថាម-១៥ នេះ គឺមន្ទីរនគរបាលតំបន់-២៥ ដែលដឹកនាំដោយមិត្ត តេង ។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំចង់បញ្ជាក់ដែរ ពីការទាក់ទងរវាង ណាត ជាមួយនឹងម-១៥ ។ ណាត ឈានទៅរកក្តាប់មន្ទីរ១៥ នេះជាការពិត ។ ខ្ញុំសូមបញ្ជាក់ថា ឯកសារដែលសល់នៅស-២១ មានរបៀបសួរចម្លើយរបស់ម-១៥ ដែល ណាត យកមកប្រគល់ឲ្យខ្ញុំទុក បើវើឲ្យមែនទែនឃើញហើយ ។

សរុបមក រឿងទាំងនេះខ្ញុំសរសេរដៃខ្ញុំ មេខ្ញុំបញ្ជាគឺ ណាត ។

**លោក អាឡិចសាន់ឌឺ ប៉េត៖**

លោកប្រធានខ្ញុំមានសំណួរចុងក្រោយមួយទៀត បើខ្ញុំសូមស្នើឲ្យខាងផ្នែកសោតទស្សន៍ហ្នឹង ប្តូរមកបញ្ចាំងលើអេក្រង់កុំព្យូទ័ររបស់សហសេវិករបស់ខ្ញុំវិញ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកសោតទស្សន៍ ចាត់ការតាមសំណូមពររបស់សហព្រះរាជអាជ្ញា ។ អញ្ជើញលោកមេធាវីដូចជាមានបញ្ហាច្រើនណាស់មែនទេ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន យើងទើបតែស្ថិតនៅក្នុងដំណាក់ការសវនាការ ជនជាប់ចោទបាននិយាយថានៅក្នុងឯកសារដែលផលិតឡើងដោយផលិតនោះ គាត់មិនដែលបានប្រើពាក្យថា “កម្ទេច” ទេ ប៉ុន្តែយើងបានឮថា បានឃើញថា នៅក្នុងអត្ថបទបកប្រែរបស់សហព្រះរាជអាជ្ញានោះ គឺឃើញមានពាក្យថា “កម្ទេច” ហ្នឹង ដូច្នេះមេធាវីការពារសូមស្នើថា ចម្លើយដែលឆ្លើយៗទៅនឹងបញ្ហានោះថា តើអ្នកណាជាអ្នកបកប្រែឯកសារនោះ? ដែលអ្នកបកប្រែឲ្យខាងឲ្យសហព្រះរាជអាជ្ញាហ្នឹង ដើម្បីឲ្យជាក់លាក់ថាតើឯកសារហ្នឹងបកប្រែដោយ *ឌីស៊ីខែម* (DC-Cam) ឬក៏ដោយអ្នកណា?

[១៦:១៧:២៩]

**ប្រធានអង្គជំនុំ៖**

ម៉េចដែរ? អញ្ជើញមេធាវីមានយោបល់អីទៀតហើយ?

**លោក គង់ ពិសី៖**

ខ្ញុំបាទសូមឆ្លើយតបនឹងចំណុចនេះបន្តិច ព្រោះថា នៅពេលនោះខាងក្រឡាបញ្ជី គាត់អានកន្លែងនេះ គឺថាព្យួរឈ្មោះ ឈ្លួច ហើយបើដាក់បញ្ចាំងទៅក៏ដាក់ទៅ សូមទៅម-១៥ ហ្នឹងសូមឱ្យជួយឈ្លួច ។ ឯចំណែកជនជាប់ចោទ គាត់បានព្យួរថា "កម្ទេច" គាត់បានបន្ទោសក្រឡាបញ្ជីថា ក្រឡាបញ្ជីអានថាពាក្យ "កម្ទេច" អត់មានពាក្យ "កម្ទេច" ហ្នឹងទេ ។ ប៉ុន្តែក្រឡាបញ្ជីថា "ឈ្លួច" អ៊ីចឹងខ្ញុំគ្រាន់តែជួយលើកឡើងពីបញ្ហាប៉ុណ្ណេះ ។ ខ្ញុំបាទសូមអធ្យាស្រ័យ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។ ដើម្បីបញ្ជាក់បញ្ហានេះ អញ្ជើញជនជាប់ចោទចង់មានយោបល់អីទៅ?

**ជនជាប់ចោទ៖**

លោកប្រធាន! ខ្ញុំសូមអនុញ្ញាតជម្រាបលោក ពិសី ដែលខ្ញុំនិយាយពីពាក្យ "កម្ទេច" ហ្នឹង គឺឯកសារមុន ឯកសារទាក់ទង អ៊ុំ សឿន អាឯកសារដែលលោក ឌុច ផារី លោកអានពីលើកមុននោះ ។ ខ្ញុំគ្មានប្រើពាក្យសរសេរពាក្យ "កម្ទេច" ទេនៅក្នុងអត្ថបទហ្នឹង ឯចំណែកមិញនេះមែន "ឈ្លួច" របស់គេមែន ខ្ញុំសរសេរ "ឈ្លួចសួរ" អាហ្នឹងមែន ។ ដូច្នេះ អារឿង "កម្ទេច" ហ្នឹង ឯកសារមុនដែលគេបកប្រែឱ្យខ្ញុំថា "កម្ទេច" ប៉ុន្តែខ្ញុំអត់សរសេរ "កម្ទេច" ទេឯកសារហ្នឹង អ៊ុំ សឿន សូមលោកអានឯកសារ អ៊ុំ សឿន ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍សូមបង្វិលកិច្ចការនេះ ភ្ជាប់ជាមួយនឹងកុំព្យូទ័រខាងផ្នែកខាងរបស់សហព្រះរាជអាជ្ញា ហើយឱ្យសហព្រះរាជអាជ្ញាដាក់បញ្ចាំងឯកសារ អ៊ុំ សឿន ឡើងវិញ ដើម្បីបញ្ជាក់បញ្ហានេះឱ្យច្បាស់លាស់ថា តើកំហុសមកពីការអាន ឬក៏កំហុសមកពីការបកប្រែឯកសារ ។ សហព្រះរាជអាជ្ញាដាក់ឯកសារហ្នឹងសាឡើងវិញមុននឹងតទៅឯកសារមួយទៀត ។

[១៦:១៩:៥៨]

**លោក តាន់ សេណារ៉ុង៖**

លោកប្រធានអង្គជំនុំជម្រះ! តំណាងសហព្រះរាជអាជ្ញា សូមជម្រាបជូនអង្គជំនុំជម្រះថា ការបកប្រែពីភាសាខ្មែរមកជាភាសាអង់គ្លេសនៅក្នុងអត្ថបទរបស់សហព្រះរាជអាជ្ញានេះគឺថាត្រឹមត្រូវ ហើយមិនមានខុសទេ ។ ក៏ប៉ុន្តែប្រហែលជាការបកប្រែដែលអ្នកខាងស្តាប់នោះ ក្រឡាបញ្ជីហ្នឹងបានអាន

ទៅប្រហែលជាសំឡេង នុំងវាស្តាប់មិនបានធ្វើឲ្យមានការភាន់ច្រឡំ ។ ក៏ប៉ុន្តែ ការបកប្រែរបស់សហព្រះរាជអាជ្ញាគឺត្រឹមត្រូវ ។ ឯអង្គជំនុំជម្រះឲ្យក្រឡាបញ្ជីយកទៅបញ្ចាំងនៅនឹងស្លាយនោះ គឺឃើញថាការបកប្រែនោះក៏ត្រឹមត្រូវដែរ បើសិនជាអង្គជំនុំជម្រះអនុញ្ញាតដើម្បីឲ្យមើលឃើញទាំងអស់គ្នា ។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត ។ មន្ត្រីតុលាការនាំយកឯកសារនោះទៅបញ្ចាំងនៅស្លាយឲ្យបានឃើញទាំងអស់គ្នា ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

លោកប្រធាន សូមការបំភ្លឺចុងក្រោយមួយដើម្បីឲ្យយើងបានយល់ច្បាស់ឲ្យពិតប្រាកដ គឺថាឯកសារនោះត្រូវបានបកប្រែដោយបុគ្គលិកផ្ទៃក្នុងរបស់យើងនៅក្នុងការិយាល័យសហព្រះរាជអាជ្ញា មិនមែនជាឯកសាររបស់ *ឌីស៊ីខេម* ទេ មែនជាមជ្ឈមណ្ឌលឯកសារកម្ពុជាទេ ដែលបកប្រែនោះ ។

**ប្រធានអង្គជំនុំ៖**

នៅកន្លែងណាមួយដែលថាមានពាក្យ “កម្ទេច” ដូចជាចំណុចនេះ បើភាសាខ្មែរពិនិត្យទៅគ្មានពាក្យ “កម្ទេច” ឬក៏ពាក្យស្រដៀងនឹងពាក្យ “កម្ទេច” ទេ អត់មានទេ ។ ហើយចេញពីណាមកដែលពាក្យថា “កម្ទេច” អម្បាញ់មិញ? ឬក៏ឯកសារផ្សេង?

អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ យើងបានកត់សម្គាល់ឃើញថា នៅក្នុងឯកសារខ្មែរច្បាប់ដើមនោះពាក្យថា “កម្ទេច” នោះមិនមានទេ ។ ប៉ុន្តែ យើងគ្រាន់តែបានដឹងថា ការបកប្រែនោះបានធ្វើដោយការិយាល័យសហព្រះរាជអាជ្ញា ដែលជាអ្នកបកប្រែឯកសារច្បាប់ដើមនោះទៅជាភាសាអង់គ្លេស ដែលដាក់មានពាក្យថា “កម្ទេច” ជាអត្ថបទបកប្រែនោះ ។ ឥឡូវហ្នឹងខ្ញុំបានជូនឯកសារ បង្ហាញឯកសារហ្នឹង ហើយខ្ញុំគិតថា ឯកសារនេះចេញមកពីផ្នែកគ្រប់គ្រងតុលាការដែលបញ្ជាក់ថា ជាសេវាបកប្រែផ្លូវការក្នុងតុលាការ ហើយឯកសារនេះដែលដាក់លេខអនុក្រម ERNOO296038 ។ នៅក្នុងឯកសារនេះយើងបានឃើញជាថ្មីម្តងទៀត ពាក្យថាមានពាក្យថា “ស្មាស” ថា “កម្ទេច” នោះដែរ ។ ខ្ញុំសូមអនុញ្ញាតស្នើថា ភាគីមួយដែលបកប្រែឯកសារខ្លួន ក្នុងផ្ទៃក្នុងរបស់ខ្លួនសូមឲ្យឯកសារហ្នឹងជម្រាបមកអង្គជំនុំជម្រះហើយ ហើយបញ្ជាក់ថាជាការបកប្រែផ្ទៃក្នុង ។ អ៊ីចឹងហើយខ្ញុំលើកឡើងបញ្ហានេះបើសិនយើងជួបនឹងបញ្ហានៅក្នុងដំណាក់កាលស៊ើបអង្កេតហ្នឹង គឺច្រើនលើកច្រើនសាដូចដែលលោកអង្គជំនុំជម្រះ

ពិនិត្យឃើញហើយ នេះមិនមែនមានលក្ខណៈអព្យាក្រឹត្យទេ វាមានលក្ខណៈផលវិបាកដោយសារយើងដូរពីពាក្យមួយទៅពាក្យមួយ ។ អ៊ីចឹងខ្ញុំសូមកត់សម្គាល់ទុកជាមុនថា ជាដូចជាមេធាវីបានបញ្ជាក់ថាការបកប្រែនោះវាមានគុណភាពមិនល្អ ។ ប៉ុន្តែខ្ញុំសូមថ្លែងអំណរគុណទុកជាមុន ដើម្បីឲ្យមានការបញ្ជាក់ថា អ្នកណាជាអ្នកបកប្រែឯកសារហ្នឹងហើយសូមជូនដំណឹងមកខាងមេធាវីការពារជាមុន ។ ដែលថាអ្នកណាជាអ្នកបកប្រែឯកសារពីច្បាប់ដើមដំបូង ដែលសហព្រះរាជអាជ្ញាបានលើកឡើងហើយដាក់ជូនមកសវនាការនៅពេលនេះ ។ ហើយធ្វើឲ្យយើងគិតថាអាច យើងនឹងអាចនឹងចូលដល់ជំហានដើម្បីស្វែងរកការពិតឲ្យបានឃើញពិតប្រាកដនោះ ។

**ប្រធានអង្គជំនុំ៖**

ស្តាប់បានទេសហព្រះរាជអាជ្ញា? តើធ្វើដូច្នេះបានទេ? ដោយសារអម្បាញ់មិញនេះភាពមិនច្បាស់លាស់នេះការបង្ហាញអំពីអ្នកទទួលបន្ទុកក្នុងការបកប្រែឯកសារនេះ បានបង្កើតឲ្យជាបញ្ហា ។

ឥឡូវនេះ មេធាវីការពារក្តីបានលើកឡើងបញ្ជាក់អំពីបញ្ហានេះហើយ បំណងនៃការបញ្ជាក់នេះគឺឲ្យកំណត់នូវអត្តសញ្ញាណបុគ្គលច្បាស់លាស់អ្នកណាមួយដែលជាអ្នកបកប្រែឯកសារ? ដែលនៅការិយាល័យសហព្រះរាជអាជ្ញាលើកយកមកបង្ហាញនៅក្នុងសវនាការ ។ យល់ទេ? ហើយអាចឆ្លើយបញ្ហានេះបានទេ?

[១៦:២៦:៤០]

**លោក អាឡិចសាន់ឌឺ បេ៊ត៖**

គឺថាខាងសហព្រះរាជអាជ្ញា គឺថា អាចនឹងជម្រាបទៅអង្គជំនុំជម្រះក្នុងករណីដែលខ្លួនដឹងថាអ្នកណាជាអ្នកបកប្រែឯកសារហ្នឹង ក្នុងករណីដែលយើងបានបង្ហាញឯកសារហ្នឹងជូនអង្គជំនុំជម្រះ ។ ប៉ុន្តែមុននឹងខ្ញុំចូលទៅដល់ចំណុចនោះ យើងបានកត់សម្គាល់ឃើញថា គ្រប់ដំណាក់កាលនៃអង្គជំនុំជម្រះគឺថាជាបញ្ហា យើងត្រូវបកប្រែឯកសារជាច្រើនដែលថាភាគីទាំងអស់ត្រូវប្រើកិច្ចប្រឹងប្រែងឲ្យអស់ពីសមត្ថភាពជាក់ស្តែងជាមួយធនធានដែលខ្លួនមាន ហើយនិងឯកសារដែលត្រូវបកប្រែទាំងអស់ដែលមិនទាន់ចប់ហ្នឹង ។ គឺថាឯកសារមួយចំនួននោះ តាមពិតត្រូវបានបកប្រែនៅក្នុងផ្ទៃក្នុងរបស់ការិយាល័យសហព្រះរាជអាជ្ញា ហើយដោយសារថាការិយាល័យគ្រប់គ្រងតុលាការនោះរវល់ពេក ឬក៏មានការងារច្រើនពេក ។ ហើយតាមពិត ខ្ញុំពេញចិត្ត ហើយនិងសប្បាយចិត្តក្នុងការបញ្ជាក់ជូនខាងមេធាវីការពារថានេះជាការបកប្រែដោយឥតគិតថ្លៃទេ គឺថា ផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញាខ្ញុំ ។ សូមបញ្ជាក់ថា ក្នុង

គោលបំណងដែលយើងបកប្រែនេះ ។ ទាក់ទងទៅនឹងអត្តសញ្ញាណពិតប្រាកដអ្នកដែលបកប្រែ ឬក៏មន្ត្រីដែលបកប្រែនូវឯកសារនេះនោះ ប្រសិនជាតុលាការបើអនុញ្ញាតឲ្យខ្ញុំបញ្ជាក់ជូននៅទីនេះ ឬក៏មេធាវីចង់ឲ្យខ្ញុំធ្វើដូច្នោះ?

[១៦:២៨:១៩]

**ប្រធានអង្គជំនុំ៖**

មេធាវីចង់យ៉ាងម៉េចទៅ? និយាយឲ្យបានច្បាស់លាស់ ពីព្រោះដូចជាដំណើរការពិភាក្សាដេញដោលហ្នឹងគឺជួបប្រទះនូវរឿងបច្ចេកទេសជាងដែលៗ ។ ហើយរាល់ថ្ងៃពាក់ព័ន្ធជាមួយនឹងការបកប្រែ ហើយនិងកិច្ចការមួយចំនួនទៀតនៃការពិនិត្យឯកសារជាដើម ដែលនាំឲ្យមានការអូសបន្លាយពេលវេលានៃកិច្ចពិភាក្សា ។ អ៊ីចឹង សូមនិយាយឲ្យបានច្បាស់លាស់ដើម្បីរកដំណោះស្រាយឲ្យបានជាក់លាក់ដើម្បីប្រព្រឹត្តទៅ ចៀសវាងនូវបញ្ហាដដែលៗនេះសាជាថ្មីម្តងទៀត ។

**លោក ហ្រ្វង់ស្វ័រ រ៉ូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមិនបានស្នើឲ្យបញ្ជាក់ឈ្មោះអ្នកបកប្រែឲ្យបញ្ជាក់ជាសាធារណៈទេ ដែលវាជាការមិនសមស្រប ។ ខ្ញុំគ្រាន់តែស្នើថា ជាបឋមនោះសូមឲ្យសហព្រះរាជអាជ្ញាបញ្ជាក់ប្រាប់យើងនៅពេលដែលយើងជួបនៅអត្ថបទបកប្រែពីរ ឬបី ថាតើអ្នកណាជាអ្នកបកប្រែដោយអង្គភាពផ្លូវការរបស់តុលាការនៅពេលដែលយើងមានការបកប្រែដោយឥតគិតថ្លៃផ្ទៃក្នុងហ្នឹង ។ តើការបកប្រែហ្នឹងធ្វើផ្ទៃក្នុង ឬក៏ធ្វើឡើងដោយសារខាងមជ្ឈមណ្ឌលឯកសារកម្ពុជា? ខ្ញុំចង់ដឹងប៉ុណ្ណឹង ។ ខ្ញុំមិនចង់បានឈ្មោះអ្នកបកប្រែ ខ្ញុំគ្រាន់តែចង់ដឹងថា តើធ្វើឡើងដោយផ្ទៃក្នុងឬក៏ដោយ *ឌីស៊ីខេម* ខ្ញុំមិនចង់បានអ្វីលើសពីហ្នឹងទេ ។

**លោក អាឡិចសាន់ឌឺ ប៊េត៖**

ខាងផ្ទៃក្នុង ។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញា តើមានសំណួរច្រើនទៀតទេ? ឬក៏មានសំណួរតែមួយទៀតទេ? លោកសហព្រះរាជអាជ្ញាមានសំណួរទៀតទេ? ហើយបើមាន មានច្រើន ឬក៏តិច?

**លោក អាឡិចសាន់ឌឺ ប៊េត៖**

សំណួរបន្ទាប់ទៅទៀតគឺថា ទាក់ទងទៅនឹងការបង្ហាញជូននូវឯកសារ ។ ខ្ញុំគិតថា វាសមពេល

នឹងយើងសម្រាក ខ្ញុំមិនអាចនឹងធានាថា ចម្លើយហ្នឹងប្រើពេលប៉ុនណានោះទេ ។

**ប្រធានអង្គជំនុំ៖**

មកឥឡូវនេះយើងដល់ពេលកំណត់នៃការត្រូវឈប់សម្រាកនៅពេលល្ងាចហើយ ។ អង្គជំនុំជម្រះ -- មានបញ្ហាអីទៀតហើយ?

**លោក អាឡាំង វ៉ែនណឺ៖**

លោកប្រធាន ថាតើខ្ញុំប្រើពេលតែដប់*ស៊ីហ្គុង*ទេ ទាក់ទងទៅនឹងឯកសារ ដែលធ្វើឡើងដោយ *ឌីស៊ីខេម* ។ តើអនុញ្ញាតឲ្យខ្ញុំនិយាយបានពីរ-បីម៉ាត់ទេទាន?

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ងើបហើយន៎!

**លោក អាឡាំង វ៉ែនណឺ៖**

ដើម្បីបញ្ជាក់ គឺថាសហសេវិកខ្ញុំបានដឹង ខ្ញុំមិនបានបញ្ជាក់ថា បានបញ្ជាក់ពីខាងដើមនោះទេ ប៉ុន្តែមិនបានធ្វើនៅផ្ទៃក្នុង ឬខាងក្រៅនៅ *ឌីស៊ីខេម* ។ ប៉ុន្តែ យើងមានកិច្ចព្រមព្រៀងរវាង *ឌីស៊ីខេម* ហើយនិងតុលាការនេះ ទាក់ទងទៅនឹងកិច្ចព្រមព្រៀងដែលបញ្ជាក់ពីភាពត្រឹមត្រូវរវាងសាលាក្តីនេះ ហើយនិង *ឌីស៊ីខេម* ។ ហើយអង្គជំនុំជម្រះដឹង ហើយមេធាវីការពារបានប្រឆាំងនឹងមិនឯកភាពទៅនឹងកិច្ចព្រមព្រៀង ប៉ុន្តែហេតុនេះហើយ បើមានកិច្ចព្រមព្រៀងរវាង *ឌីស៊ីខេម* ។ តើគេចាត់ទុកថាការធ្វើហ្នឹងដោយផ្ទៃក្នុង ឬយ៉ាងម៉េច? បើសិនជាមានការបកប្រែដោយ *ឌីស៊ីខេម* មិនបានចាត់ទុកថា ជាការបកប្រែខាងក្រៅទេ ពីព្រោះ *ឌីស៊ីខេម* និង *ស៊ីអឹមអេស* (CMS) មានកិច្ចព្រមព្រៀងធ្វើការបកប្រែនោះហើយ ។ នេះហើយ ខ្ញុំចង់ឲ្យកត់ត្រានៅក្នុងសំណុំរឿង ។ សូមអរគុណ ។

[១៦:៣២:១៧]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ពេលដែលត្រូវឈប់សម្រាកនៅពេលរសៀលហើយ អង្គជំនុំជម្រះសាលាដំបូងសូមប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ។ ហើយសវនាការនឹងលើកបន្តទៅព្រឹកថ្ងៃស្អែក ថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៩ ចាប់ពីម៉ោងប្រាំបួនព្រឹកទៅ ។ ហើយអង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ កាំង ហ្គេកអ៊ាវ ទៅកាន់មន្ទីរឃុំឃាំងវិញ ។ ហើយឲ្យនាំគាត់ត្រឡប់មកកាន់សាលសវនាការឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំហិតនៅព្រឹកស្អែក ។ ហើយអង្គជំនុំជម្រះសូមជម្រាប

ដល់អ្នកចូលរួមទាំងអស់អញ្ជើញចូលរួមសវនាការនៅព្រឹកស្អែក សូមអញ្ជើញឲ្យបានមុនម៉ោងប្រាំបួនព្រឹក ៕

*[សវនាការផ្អាកនៅវេលាម៉ោង ១៦:៣៣ នាទី]*